مدرسة اهل البيت

صلوات الله عليهم

# សាលា
# អាស្ស៊ុល-បៃត៏

## សៀវភៅសិក្សា សីលធម៌ (أَخْلَاقٌ ) ថ្នាក់ទី ៩

(អាយុ ១៣-១៤ ឆ្នាំ)

قَالَ اَلنَّبِيُّ صَلَّى اللَّهُ عَلَيْهِ وَ آلِهِ : طَلَبُ اَلْعِلْمِ فَرِيضَةٌ عَلَى كُلِّ مُسْلِمٍ وَ مُسْلِمَةٍ (بحار الأنوار ج ١ ص ١٧٧)

ព្រះសាស្តាﷺមានព្រះវចនៈថា៖ "ស្វែងរកចំណេះវិជ្ជាជាកាតព្វកិច្ចលើមុស្លីមប្រុសស្រីគ្រប់រូប ។"

## សិក្សាសាសនា

# បញ្ជីមាតិកា


មេរៀនទី ១ គោរពឪពុកម្ដាយ ........................................ ៥
មេរៀនទី ២ ករណីយកិច្ចចំពោះកូនៗ ........................................ ១០
មេរៀនទី ៣ ហាក្ង អាន់-ណាស់ ........................................ ១៩
មេរៀនទី ៤ ផ្សះផ្សាគេឲ្យសះជានឹងគ្នា ........................................ ២១
មេរៀនទី ៥ បម្រើមនុស្សជាតិ ........................................ ២៣
មេរៀនទី ៦ ក្ង៏រ៉ដ្ង អាល់-ហាសាណាស់ ........................................ ២៥
មេរៀនទី ៧ ការចម្លងប្រកបដោយវិនាសន្ធូវប្បធម៌ប្រទេសខាងលិច ........................................ ២៨
មេរៀនទី ៨ ហ៊ុសនុស្ល-ស្លាន់ និង ស៊ូអ៊ុស្ល-ស្លាន ........................................ ៣២
មេរៀនទី ៩ កាស្ល់មុល-កុយ៉ស្ល៍ ........................................ ៣៥
មេរៀនទី ១០ អ៊ិះខ៌ុទ្បាស្ល់ ........................................ ៣៨
មេរៀនទី ១១ រស់នៅដោយមានសីលធម៌ ........................................ ៤២
មេរៀនទី ១២ ការអត់ធ្មត់ ........................................ ៤៧
មេរៀនទី ១៣ គោរពបរិស្ថាន ........................................ ៥១
មេរៀនទី ១៤ តាកាប់ប៊ូរ, រីយ៉ាអ៍, អ៊ុយ្ចូប ........................................ ៥៤
មេរៀនទី ១៥ សម្ដីអាក្រក់, ការប្រមាថ, ការបញ្ឈឺនិងសេចក្ដីព្រហើន ........................................ ៥៩
មេរៀនទី ១៦ ទម្លាយអាថ៌កំបាំងគេ ........................................ ៦១
មេរៀនទី ១៧ កំហឹង ........................................ ៦៥
មេរៀនទី ១៨ គ្រប់អាយុ (បាលិក៍ بالغ) ........................................ ៦៨
មេរៀនទី ១៩ ការបណ្ដែតបណ្ដោយ ........................................ ៧២
មេរៀនទី ២០ ព្រហ្មចារិយភាព ........................................ ៧៦

## មេរៀនទី ១

# គោរពឪពុកម្ដាយ

យើងបានអធិប្បាយរឿងនេះ នៅក្នុងច្រើនមេរៀនកន្លងមកហើយ ។ មកដល់ពេលនេះ អ្នកបានសិក្សាការគោរពមាតាបិតាច្រើនដងហើយ តែនៅក្នុងមេរៀននេះ គេនឹងពន្យល់អ្នកឲ្យដឹងថា ឪពុកម្ដាយមានតួនាទីសំខាន់បំផុតក្នុងការអប់រំអ្នកដែលជាមនុស្សម្នាក់ និងក្នុងការអប់រំសង្គមមនុស្សទូទៅ ។

អល់ឡោះហ្ ﷻ ចែងអំពីការទន់ភ្លន់ចំពោះឪពុកម្ដាយ ៧ ដងក្នុងព្រះគម្ពីរគួរអាន ។

អល់ឡោះហ្ ﷻ បានព្រះបន្ទូលនៅក្នុងព្រះគម្ពីរគួរអាន ស៊ូរ៉ោះត៍ 17 អាយ៉ាស់ 23-24 ថា៖

﴿وَقَضَىٰ رَبُّكَ أَلَّا تَعْبُدُوٓاْ إِلَّآ إِيَّاهُ وَبِٱلْوَٰلِدَيْنِ إِحْسَٰنًاۚ إِمَّا يَبْلُغَنَّ عِندَكَ ٱلْكِبَرَ أَحَدُهُمَآ أَوْ كِلَاهُمَا فَلَا تَقُل لَّهُمَآ أُفٍّ وَلَا تَنْهَرْهُمَا وَقُل لَّهُمَا قَوْلًا كَرِيمًا ﴿٢٣﴾ وَٱخْفِضْ لَهُمَا جَنَاحَ ٱلذُّلِّ مِنَ ٱلرَّحْمَةِ وَقُل رَّبِّ ٱرْحَمْهُمَا كَمَا رَبَّيَانِى صَغِيرًا ﴿٢٤﴾

*23. ព្រះម្ចាស់អ្នកបានដាក់បញ្ជាថាឲ្យពួកអ្នក (មនុស្សទាំងឡាយ) គោរពបូជាតែព្រះអង្គមួយគត់ ឲ្យពួកអ្នកប្រព្រឹត្តល្អចំពោះឪពុកម្ដាយពួកអ្នក ។ បើអ្នកណាម្នាក់ ឬអ្នកទាំងពីរមានវ័យជរានៅជាមួយអ្នក ចូរអ្នកកុំនិយាយស្ដីថា "ថ្វីយ! (ជាពាក្យពោលចេញមក សម្ដែងឲ្យឃើញថាមានការធុញទ្រាន់ រំខាន ឬ ស្អប់)" ឡើយ ចូរអ្នកកុំគំហកដាក់អ្នកទាំងពីរឡើយ ចូរអ្នកមានវាចារកពួកគេដោយប្រើសំដីល្អប្រពៃ [ដោយគោរព] ។ 24. ចូរអ្នកបន្ទាបស្លាបនៃសេចក្ដីគោរពចំពោះអ្នកទាំងពីរដោយមានចិត្តធម៌[និងប្រោសប្រណី] ហើយចូរអ្នកពោលថា៖ "ព្រះម្ចាស់អើយ សូមព្រះអង្គមានព្រះមេត្តាធម៌ដល់លោកទាំងពីរ ឲ្យដូចកាលដែលលោកទាំងពីរបានចិញ្ចឹមទូលព្រះបង្គំជាខ្ញុំកាលពីតូចផង ។"*

ពាក្យថា "أُفٍّ ថ្វីយ" ជាពាក្យស្រាលបំផុត តែព្រះសន្ធអ៊ីម៉ាំ យ៉ាក់ហ្ការ អាស្ស៊ូ-ស៊្វឌិក្ក صلوات الله عليه والسلام មានវចនៈថា៖ "ប្រសិនបើមានពាក្យស្រាលជាងនេះ អល់ឡោះហ្ عز وجل

ប្រាកដជានឹងយកពាក្យនោះមកប្រើជាមិនខានជំនួសពាក្យ "أُفٍّ ថ្វីយ" នេះ ។" គេមិនត្រូវហៅឪពុកម្តាយខ្លួនឯងតាមឈ្មោះលោកទេ តែចូរហៅលោកថា ម៉ាក់ ប៉ា (ឬ ម៉ែ ពុក) ។

ថ្ងៃមួយ បុរសម្នាក់បានទៅជួបព្រះបរមសាស្តាមូហាំម៉ាដ់ﷺ សួរព្រះអង្គﷺ ថាតើទង្វើណាមួយដែលនាំមកនូវផលបុណ្យពីអល់ឡោះហ្ ជ.عز ។ ព្រះបរមសាស្តាមូហាំម៉ាដ់ﷺសួរបុរសនោះថាតើឪពុកម្តាយគាត់នៅរស់ឬស្លាប់ហើយ ។ ពេលគាត់តបថានៅរស់ ព្រះបរមសាស្តាមូហាំម៉ាដ់ﷺបានតបថាទង្វើល្អបំផុតដែលនាំមកនូវព្រះពរអល់ឡោះហ៊្ عزّ وجلّគឺធ្វើល្អចំពោះឪពុកម្តាយ ព្រោះទង្វើនេះជាទីស្រឡាញ់ជាងទង្វើឯទៀត ។

តាហ្ស៊ៀវថែងថាគេត្រូវបួងសួងអល់ឡោះហ្ عزّ وجلّ សូមឲ្យព្រះអង្គ عزّ وجلّប្រទានឋានសួគ៌ឲ្យឪពុកម្តាយខ្លួន បើឪពុកម្តាយខ្លួនធ្វើអំពើនីមួយដែលអល់ឡោះហ៊្ عزّ وجلّមិនសព្វព្រះហឫទ័យ គេត្រូវបួងសួងសូមឲ្យអល់ឡោះហ៊្ عزّ وجلّដឹកនាំលោកមកកាន់ផ្លូវត្រូវវិញ ។

ការពិត អ្វីដែលអល់ឡោះហ៊្ عزّ وجلّឲ្យគេចារមុនគេបង្អស់នៅលើ ឡៅហ៊្ អាល់-ម៉ាស់ហ៊្វូស្ (اَللَّوْحُ الْمَحْفُوظُ បន្ទះសំណេរអភិរក្ស) គឺ៖ *"អញ عزّ وجلّគឺអល់ឡោះហ៊្ عزّ وجلّ ពុំមានព្រះទេក្រៅពីអញ عزّ وجلّ ។ អញ عزّ وجلّពេញចិត្តបុគ្គលណាដែលឪពុកម្តាយពេញចិត្ត ។ អញ عزّ وجلّមិនពេញចិត្តបុគ្គលណាដែលឪពុកម្តាយមិនពេញចិត្ត ។"*

គ្រាមួយ ព្រះបរមសាស្តាមូហាំម៉ាដ់ﷺបានប្រាប់ព្រះសន្តអ៊ីម៉ាំអាលី صلوات الله عليه والسلامថា៖ *"អង្គុយមួយម៉ោងជាមួយឪពុកម្តាយគ្រាន់ជាងទៅយីហាដ់ ។"* ព្រះអង្គﷺមានវចនៈបន្ថែមថា៖ *"អាលី صلوات الله عليه والسلامអឺយ បើគេនិយាយពាក្យមួយម៉ាត់ក្នុងគោលបំណងធ្វើឲ្យឪពុកម្តាយពេញចិត្ត អល់ឡោះហ៊្ عزّ وجلّអាចសព្វព្រះហឫទ័យ ។"*

ពាក្យថា "ឪពុកម្តាយ" មិនផ្តោតទៅលើឪពុកម្តាយបង្កើតតែម្យ៉ាងទេ តែផ្តោតទៅលើបណ្តាអ្នកដែលខិតខំអប់រំអ្នកអស់ពីសមត្ថភាពដែរ ជាពិសេសបណ្តាអ្នកដែលធ្វើឲ្យអ្នកប្រសើរឡើងជាបុគ្គលមួយរូប ។ ឪពុកម្តាយមានបីប្រភេទយ៉ាងតិច

គឺ៖ ឪពុកម្ដាយបង្កើតដែលឲ្យកំណើតអ្នក, លោកគ្រូអ្នកគ្រូដែលបង្ហាត់បង្រៀនអ្នក និងឪពុកម្ដាយរបស់បុគ្គលដែលអ្នករៀបការជាមួយ ។ បុគ្គលទាំងនេះមានសិទ្ធិលើខ្លួនអ្នក ដូច្នេះចូរអ្នកបំពេញករណីយកិច្ចខ្លួនចំពោះបុគ្គលទាំងនេះតាមការណែនាំរួចមកហើយ ។

ពេលនេះយើងដឹងហើយថាត្រូវគោរពឪពុកម្ដាយយើងដូចម្ដេចខ្លះ យើងនឹងអធិប្បាយអំពីមូលហេតុដែលយើងត្រូវគោរពឪពុកម្ដាយយើង ។

ឪពុកម្ដាយយើងបានចិញ្ចឹមយើង តែលោកបានរួមចំណែកក្នុងការបង្កើតយើងដែរ ។ ចូរពិនិត្យមើលផ្ទះយើង ។ អ្នកអាចអះអាងបានទេថាផ្ទះមានតែជញ្ជាំងបួន ដំបូលនិងរនាប ? ទេ ព្រោះផ្ទះអ្នកមានគ្រឿងសង្ហារិម មានពណ៌ សំខាន់គឺមានមនុស្សនៅ ។ ស្រដៀងនេះដែរ ឪពុកម្ដាយអ្នកមិនត្រឹមតែបានបង្កើតខ្លួនអ្នកតែម្យ៉ាងទេ តែលោកបានបង្កើតលក្ខណៈសម្បត្តិអ្នកនិងបានធ្វើឲ្យអ្នកចេះគិតគូរដែរ ។ លោកបានរស់នៅដើម្បីអ្នក ។ លោកស្រឡាញ់អ្នក ថ្នាក់ថ្នមអ្នក លោកបានបង្ហាត់អ្នកឲ្យចេះដឹងអំពើល្អនិងអំពើអាក្រក់ លោកបានផ្ដល់អាហារឲ្យអ្នក ។

ប្រសិនបើនៅសល់អាហារសម្រាប់តែមនុស្សម្នាក់ លោកឲ្យអាហារនោះទៅកូន ។ ម្ដាយអ្នកបានបង្កើតអ្នក បានមើលថែរក្សាអ្នកកាលអ្នកនៅក្មេង ។ តើអ្នកអាចប៉ាន់ស្មានបានទេថាឪពុកម្ដាយលំបាកនិងបារម្ភប៉ុណ្ណាខ្លះ ។ បើអ្នកសួរលោកថាហេតុអ្វី លោកនឹងតបថាលោកចង់ឲ្យអ្នកមានអ្វីសព្វគ្រប់ដែលខ្លួនលោកពុំមានដើម្បីកសាងជីវិត ។ មិនឲ្យយើងគោរពលោកម្ដេចបាន ? មិនឲ្យយើងស្រឡាញ់លោកម្ដេចបាន ? នេះគឺមូលហេតុមួយដែលអ៊ីស្លាមថា៖ *"ឋានសួគ៌នៅក្រោមបាតជើងម្ដាយអ្នក ។"*

បានសេចក្ដីថាបើយើងធ្វើឲ្យម្ដាយយើងទាស់ចិត្ត យើងនឹងពុំបានចូលឋានសួគ៌ឡើយ ។ ដូច្នេះ ផ្លូវដែលនាំទៅកាន់ឋានសួគ៌អាស្រ័យលើការពេញចិត្តរបស់ឪពុកម្ដាយអ្នក ។

មានទ្រឹស្ដីនេះដែរនៅក្នុងព្រះបន្ទូលអល់ឡោះហ៏ﷻ កាលព្រះអង្គﷻបានប្រាប់ព្រះសាស្ដាមួយអង្គរបស់ព្រះអង្គﷻថា៖ *"អញﷻសូមស្បថចំពោះព្រះកិត្តិយសអញﷻថាអ្នកណាមួយមិនស្ដាប់បង្គាប់ឪពុកម្ដាយ ទោះបីអ្នកនោះមករកអញﷻដោយនាំមកនូវទង្វើដូចព្រះសាស្ដាដែរក៏ដោយ ក៏អញﷻមិនព្រមទទួលអ្នកនោះជាដាច់*

*ខាត ។"*

## ករណីយកិច្ចចំពោះឪពុកម្ដាយ

១. កុំប្រើសម្ដីធំ (គំហក) ដាក់ឪពុកម្ដាយជាដាច់ខាត ។
២. កុំអង្គុយពេលឪពុកម្ដាយឈរ ។
៣. កុំដើរកាត់មុខឪពុកម្ដាយ លើកលែងតែលោកអនុញ្ញាត ។
៤. កុំនិយាយពេលឪពុកម្ដាយនិយាយ ។
៥. កុំកែកំហុសឪពុកម្ដាយនៅពីមុខអ្នកដទៃ ។
៦. កុំធ្វើឲ្យឪពុកម្ដាយទាស់ចិត្តឬក្រោធ ។
៧. កុំជេរប្រមាថ ប្រកែកតវ៉ា ឬគំហកដាក់ឪពុកម្ដាយជាដាច់ខាត ។

ពេលអ្នកក្រោកពីដំណេកពេលព្រឹក ប្រការដំបូងបង្អស់ដែលអ្នកត្រូវធ្វើគឺថា *"អាស់-សាឡាមុ អ៊ាឡៃគុម"* ឲ្យឪពុកម្ដាយអ្នក ។ វាជាប្រការសាមញ្ញ តែមានអ្នកណាខ្លះធ្វើបែបនេះមែននៅជុំវិញយើង ? អ្នកណាខ្លះនៅជុំវិញយើងនឹងក្រោកឈរហើយថា *"អាស់-សាឡាមុ អ៊ាឡៃគុម"* ពេលឪពុកយើងឬម្ដាយយើងចូលមកក្នុងបន្ទប់ ?

បើឪពុកម្ដាយអ្នកឲ្យអ្នកធ្វើការនីមួយ ដូចជាទៅទិញអ៊ីវ៉ាន់ជាដើម អ្នកមិនត្រូវតវ៉ាទេ ទោះបីដោយសម្ដែងឲ្យឃើញថាអ្នកនឿយហត់ក៏ដោយ ។ សូម្បីតែមើលទៅឪពុកម្ដាយដោយអាការធុញទ្រាន់ក៏កុំសម្ដែងដាក់លោក ។ ហេតុដូច្នេះឯងបានជាគេថា៖ *"មើលមុខឪពុកឬម្ដាយខ្លួនដោយសេចក្ដីគោរពស្មើនឹងមើលព្រះមហាគ្រឹះកាក់ហ្ពាស់ គឺបានរង្វាន់ស្មើគ្នា ។"*

ការមិនពេញចិត្តរបស់អល់ឡោះហ្ទ៍ាំចំពោះបុគ្គល ដែលធ្វើឲ្យឪពុកម្ដាយខ្លួនទាស់ចិត្តនោះធំណាស់ បើបុគ្គលណាមួយត្រូវឪពុកម្ដាយកាត់កាល់ បុគ្គលនោះនឹងមិនបានធុំក្លិនឋានសួគ៌ជាដាច់ខាត ។ បើឪពុកម្ដាយមិនពេញចិត្តកូនណាម្នាក់ពេញមួយយប់ ពេលថ្ងៃរះហើយក៏នៅតែទាស់ចិត្ត វាដូចទ្វារនរកពីរត្រូវបើកសម្រាប់

កូនម្នាក់នោះ ។

## មេរៀនទី ២

# ករណីយកិច្ចចំពោះកូនៗ

យើងបាននិយាយអំពីសេចក្ដីគោរពឪពុកម្ដាយក្នុងមេរៀនមុន យើងដឹងហើយថាវាជាប្រការសំខាន់មួយ ។ តែកូនៗនោះយ៉ាងម៉េចដែរ ? ត្រូវតែមានករណីយកិច្ចមកលើកូនៗដែរ ។

អល់ឡោះហ្ន៎ﷻមានព្រះបន្ទូលនៅក្នុងព្រះគម្ពីរគួរអាន (ស៊ូរ៉ោះត្ទ៍ 66 អាយ៉ាស្ទ៍ 6) ថា៖

يَٰٓأَيُّهَا ٱلَّذِينَ ءَامَنُواْ قُوٓاْ أَنفُسَكُمْ وَأَهْلِيكُمْ نَارًا وَقُودُهَا ٱلنَّاسُ وَٱلْحِجَارَةُ عَلَيْهَا مَلَٰٓئِكَةٌ غِلَاظٌ شِدَادٌ لَّا يَعْصُونَ ٱللَّهَ مَآ أَمَرَهُمْ وَيَفْعَلُونَ مَا يُؤْمَرُونَ ٦

*6. អ្នកមានសទ្ធាទាំងឡាយអើយ ចូរពួកអ្នកសង្គ្រោះខ្លួនពួកអ្នកនិងគ្រួសារពួកអ្នកឲ្យផុតពីភ្លើងដែលមានមនុស្សនិងដុំថ្មជាឧស [ដោយហាមខ្លួនពួកអ្នកនិងដោយហាមកូនៗពួកអ្នកនិងសមាជិកឯទៀតរបស់គ្រួសារពួកអ្នកកុំឲ្យសាងបាប] ។ [គឺភ្លើង]ដែលមានទេវតាគួរឲ្យខ្លាចនិងតឹងរ៉ឹងជាអ្នកត្រួតត្រា ពួកគេមិនល្មើសព្រះបញ្ជាអល់ឡោះហ្ន៎ទេ ពួកគេអនុវត្តតាមព្រះបញ្ជាដែលគេដាក់មកលើពួកគេ ។*
(ស៊ូរ៉ោះត្ទ៍ អាត់-តាស្ទ៍រីម អាយ៉ាស្ទ៍ ៦)

សឲ្យឃើញថាករណីយកិច្ចដំបូងបង្អស់ដែលត្រូវធ្វើចំពោះកូនៗ គឺអប់រំពួកគេឲ្យស្គាល់ប្រការល្អនិងប្រការអាក្រក់ ។ ត្រូវអនុវត្តិករណីយកិច្ចនេះដោយបង្ហាញជាគំរូ ។

ករណីយកិច្ចមួយរបស់ឪពុកម្ដាយចំពោះកូនៗគឺការអប់រំ ការអប់រំផ្នែកសាសនាអ៊ីស្លាមជាដំបូង ការអប់រំផ្នែកមិនទាក់ទងនឹងសាសនាជាបន្ទាប់ ។ មិនបានសេចក្ដីថាត្រូវបញ្ជូនកូនៗទាំងអស់ទៅនៅឯមណ្ឌលអប់រំ ហៅ៍ស្ម៉ាស្ទ៍ (حوزة) រាប់ឆ្នាំនោះទេ តែបានសេចក្ដីថាកូនៗរាល់គ្នាត្រូវចេះដឹងយ៉ាងហោចណាស់គោលរបស់សាសនាអ៊ីស្លាម ដើម្បីនឹងឲ្យកូនៗទាំងនោះចេះប្រើចំណេះរបស់ខ្លួនដើម្បីបម្រើអ៊ីស្លាមនិងសហាគមន៍ ។

ព្រះបរមសាស្ដាមូហាំម៉ាដ់صلى الله عليه وآله وسلمមានព្រះវចនៈថា យើងត្រូវប្រព្រឹត្តត្រឹមត្រូវទៅលើកូនៗយើង យើងត្រូវស្រឡាញ់កូនៗយើង ទន់ភ្លន់ចំពោះកូនៗយើង យើងត្រូវគោរពពាក្យសន្យាដែលបានសន្យាចំពោះកូនៗយើង ព្រោះយើងជាអ្នកទ្រទ្រង់កូនៗយើង ព្រោះកូនៗយើងពឹងផ្អែកលើយើងដើម្បីជួយពួកគេ ។

ថ្ងៃមួយព្រះបរមសាស្ដាមូហាំម៉ាដ់صلى الله عليه وآله وسلمកំពុងដើរ ព្រះអង្គصلى الله عليه وآله وسلمបានជួបកូនក្មេង ។ ព្រះអង្គصلى الله عليه وآله وسلمគ្រវីក្បាល មានព្រះវចនៈថាព្រះអង្គصلى الله عليه وآله وسلمសោកស្ដាយចំពោះឪពុកម្ដាយក្មេងៗសម័យចុងក្រោយ ។ គេសួរព្រះអង្គصلى الله عليه وآله وسلمថា៖ *"ហេតុអ្វី ? ពួកគេនឹងទៅជាមនុស្សគ្មានធម៌ឬ ?"* ព្រះបរមសាស្ដាមូហាំម៉ាដ់صلى الله عليه وآله وسلمមានព្រះវចនៈថា៖ *"ទេ មិនដូច្នេះទេ តែឪពុកម្ដាយមិនអប់រំកូនៗឲ្យចេះដឹងសាសនាទេ ពួកគេនឹងពេញចិត្តផ្ដល់ការអប់រំផ្នែកលោកនេះឲ្យកូនៗ ។"* ព្រះអង្គصلى الله عليه وآله وسلمមានព្រះវចនៈថាមនុស្សប្រភេទនេះមិននៅក្នុងបក្សព្រះអង្គصلى الله عليه وآله وسلمទេ ថាព្រះអង្គصلى الله عليه وآله وسلمនឹងមិនស្រឡាញ់មនុស្សប្រភេទនេះទេ ។

គ្រាមួយ ព្រះបរមសាស្ដាមូហាំម៉ាដ់صلى الله عليه وآله وسلمបានប្រាប់ព្រះសន្តអ៊ីម៉ាំអាលីصلوات الله عليه والسلامថា៖ *"អាលីصلوات الله عليه والسلامអើយ ឪពុកម្ដាយមានករណីយកិច្ចរ៉ាយ៉ីបចំពោះកូនៗស្មើកូនៗមានករណីយកិច្ចចំពោះឪពុកម្ដាយដែរ ។"*

ករណីយដំបូងបង្អស់គឺដាក់ឈ្មោះត្រឹមត្រូវឲ្យកូន ។ ដូច្នេះ កូនៗនឹងយកគម្រាប់តាមបុគ្គលដែលជាម្ចាស់ដើមរបស់ឈ្មោះនោះ ឬវានឹងធ្វើតាមអត្ថន័យរបស់ឈ្មោះវា ។

កូនក្មេងឆ្លងកាត់បីដំណាក់ការក្នុងជីវិត មុននឹងអាចរស់នៅក្នុងលោក "មនុស្សធំ" បាន ។ ដំណាក់ការនីមួយៗមានអំឡុងពេលប្រាំពីរឆ្នាំ ។ ប្រាំពីរឆ្នាំដំបូងនៃជីវិតវា កូនក្មេងជា **លោកម្ចាស់** គេត្រូវបណ្ដោយឲ្យវាលេង ឲ្យវាសប្បាយដោយគ្មានការទទួលខុសត្រូវ ។ មិនបានសេចក្ដីថាអ្នកបណ្ដោយឲ្យវាធ្វើអ្វីបានតាមចិត្តទេ តែអ្នកត្រូវឲ្យវាមានសេរីភាពក្នុងក្របខ័ណ្ឌច្បាប់ស្ហារីអាស់ ។ មិនត្រូវអប់រំវាតាមវិធីការទេ តែត្រូវបង្ហាត់វាឲ្យស្គាល់គោលវិន័យ ។

ប្រាំពីរឆ្នាំបន្ទាប់ កូនក្មេងជា **ទាសៈ** ។ បានសេចក្ដីថាកូនក្មេងត្រូវស្គាល់ការទទួលខុសត្រូវ គេត្រូវបង្ហាត់វាឲ្យស្គាល់ច្បាប់អ៊ីស្លាមនិងឲ្យស្គាល់លោកនេះ ។ មិនបានសេចក្ដីថាត្រូវបង្ខិតបង្ខំកូនក្មេងទេ តែពេលនេះត្រូវរឹតត្បិតអ្វីដែលគេបានអនុញ្ញាតឲ្យវាធ្វើបានក្នុងអំឡុងពេលប្រាំពីរឆ្នាំដំបូងនៃជីវិតវា ។

ប្រាំពីរឆ្នាំចុងក្រោយ គេហៅថាឆ្នាំ **ក្រសួង** (មុខការ) ។ កូនក្មេង ឬយុវជន ត្រូវប្រកបកិច្ចការ ជួយធ្វើការផ្ទះ ។ វាត្រូវប្រគល់ឲ្យគ្រួសារវិញនូវអ្វីៗដែលវាបានយកកាលវាកំពុងធំ ។

## កូនក្មេងដែលប្រកបដោយគុណធម៌ជាផ្កាឋានសួគ៌មួយទង ។

អ៊ីស្លាមសង្កត់ធ្ងន់ណាស់លើការចាំបាច់ប្រព្រឹត្តត្រឹមត្រូវចំពោះកូនក្មេង ដល់ថ្នាក់ព្រះបរមសាស្ដាមូហាំម៉ាដ្ឋ ﷺ មានព្រះវចនៈថា៖ *"រាល់ពេលដែលបុគ្គលថើបកូនខ្លួន គេចារទង្វើល្អមួយក្នុងបញ្ជីកត់អំពើល្អទុកឲ្យបុគ្គលនោះ ។"*

ថ្ងៃមួយ បុរសម្នាក់បានមកជួបព្រះបរមសាស្ដាមូហាំម៉ាដ្ឋ ﷺ ទូលព្រះអង្គ ﷺ ថា៖ *"ទូលបង្គំមិនដែលថើបកូនទេ ។"* ពេលបុរសនោះបែរក្រោយត្រឡប់ទៅវិញ ព្រះបរមសាស្ដាមូហាំម៉ាដ្ឋ ﷺ មានព្រះវចនៈថា៖ "បុរសចិត្តថ្មម្នាក់នេះនៅក្នុងចំណោមបុគ្គលដែលនឹងត្រូវភ្លើងនរកឆេះ ។"

នេះគឺឌូអាអ៊ុំមួយសរសេរដោយព្រះសន្តអ៊ីមុាំ ស៊ែនុល-អាប៊ីឌីន صلوات الله عليه والسلام ដកស្រង់ពីសាត្រា ស្វ៉ាហ៊ីហ្វាស់ អាល់-កាមីឡាស់ (اَلصَّحِيفَةُ اَلْكَامِلَةُ) ។

(25) وَ كَانَ مِنْ دُعَائِهِ عَلَيْهِ السَّلَامُ لِوُلْدِهِ عَلَيْهِمُ السَّلَامُ

**(25) ឌូអាអ៊ុំឲ្យព្រះរាជបុត្រ** عليهم السلام **ព្រះអង្គ** صلوات الله عليه والسلام

1. اللَّهُمَّ وَ مُنَّ عَلَيَّ بِبَقَاءِ وُلْدِي وَ بِإِصْلَاحِهِمْ لِي و بِإِمْتَاعِي بِهِمْ .

*1. អល់ឡោះហ្ទ៍ ﷻ អើយ សូមព្រះអង្គ ﷻ ប្រោសប្រណីទូលព្រះបង្គំជាខ្ញុំដោយឲ្យកូនៗ*

*ទូលព្រះបង្គំជាខ្ញុំរួចផុតពីការស្លាប់ ដោយអប់រំពួកគេឲ្យទូលព្រះបង្គំជាខ្ញុំ ដោយឲ្យទូលព្រះបង្គំជាខ្ញុំគាប់ចិត្តពួកគេ ។*

2. إِلَهِي أَمْدُدْ لِي فِي أَعْمَارِهِمْ ، وَ زِدْ لِي فِي آجَالِهِمْ ، وَ رَبِّ لِي صَغِيرَهُمْ ، وَ قَوِّ لِي ضَعِيفَهُمْ ، وَ أَصِحَّ لِي أَبْدَانَهُمْ وَ أَدْيَانَهُمْ وَ أَخْلاَقَهُمْ ، وَ عَافِهِمْ فِي أَنْفُسِهِمْ وَ فِي جَوَارِحِهِمْ وَ فِي كُلِّ مَا عُنِيتُ بِهِ مِنْ أَمْرِهِمْ ، وَ أَدْرِرْ لِي وَ عَلَى يَدِي أَرْزَاقَهُمْ .

*2. អល់ឡោះហ្ទ៍عز وجلអើយ សូមព្រះអង្គعز وجلធ្វើឲ្យពួកគេមានជីវិតយឺនយូរឲ្យទូលព្រះបង្គំជាខ្ញុំ សូមព្រះអង្គعز وجلបង្កើនរយៈពេលរស់នៅពួកគេឲ្យវែងឲ្យទូលព្រះបង្គំជាខ្ញុំ សូមព្រះអង្គعز وجلធ្វើឲ្យកូនតូចឆាប់ធំឲ្យទូលព្រះបង្គំជាខ្ញុំ សូមព្រះអង្គعز وجلពង្រឹងកូនខ្សោយឲ្យទូលព្រះបង្គំជាខ្ញុំ សូមព្រះអង្គعز وجلថែរក្សាខ្លួនប្រាណពួកគេ ជំនឿពួកគេ សីលធម៌ពួកគេឲ្យទូលព្រះបង្គំជាខ្ញុំ សូមព្រះអង្គعز وجلឲ្យពួកគេរួចផុតពីអន្តរាយក្នុងចិត្ត ក្នុងខ្លួនប្រាណនិងក្នុងរឿងឯទៀតទាក់ទងនឹងពួកគេដែលទូលព្រះបង្គំជាខ្ញុំបារម្ភ សូមព្រះអង្គعز وجلធ្វើឲ្យជីវព្រឹត្តពួកគេហូរមកលើដៃទូលព្រះបង្គំជាខ្ញុំ ។*

3. وَ اجْعَلْهُمْ أَبْرَاراً أَتْقِيَاءَ بُصَرَاءَ سَامِعِينَ مُطِيعِينَ لَكَ ، وَ لِأَوْلِيَائِكَ مُحِبِّينَ مُنَاصِحِينَ ، وَ لِجَمِيعِ أَعْدَائِكَ مُعَانِدِينَ وَ مُبْغِضِينَ ، آمِينَ .

*3. សូមព្រះអង្គعز وجلឲ្យពួកគេមានសីលធម៌ មានធម្មគោរព អាចឃើញនិងអាចឮស្តាប់បង្គាប់ព្រះអង្គعز وجل ស្រឡាញ់និងមានបំណងល្អចំពោះបណ្តាមិត្តព្រះអង្គعز وجل ប្រឆាំងនិងស្អប់បណ្តាសត្រូវរបស់ព្រះអង្គعز وجل ។ អាមីន ។*

4. اللَّهُمَّ أَشْدُدْ بِهِمْ عَضُدِي ، وَ أَقِمْ بِهِمْ أَوَدِي ، وَ كَثِّرْ بِهِمْ عَدَدِي ، وَ زَيِّنْ بِهِمْ مَحْضَرِي ، وَ أَحْيِ بِهِمْ ذِكْرِي ، وَ اكْفِنِي بِهِمْ فِي غَيْبَتِي ، وَ أَعِنِّي بِهِمْ عَلَى حَاجَتِي ، وَ اجْعَلْهُمْ لِي مُحِبِّينَ ، وَ عَلَيَّ حَدِبِينَ مُقْبِلِينَ مُسْتَقِيمِينَ لِي ، مُطِيعِينَ ، غَيْرَ عَاصِينَ وَ لَا عَاقِّينَ وَ لَا مُخَالِفِينَ وَ لَا خَاطِئِينَ .

*4. អល់ឡោះហ្ទ៍عز وجلអើយ សូមព្រះអង្គعز وجلពង្រឹងកម្លាំងទូលព្រះបង្គំជាខ្ញុំដោយពួកគេ សូមព្រះអង្គعز وجلផ្តល់ឲ្យទូលព្រះបង្គំជាខ្ញុំ នូវអ្វីដែលទូលព្រះបង្គំខ្ញុំខ្វះខាតដោយពួកគេ សូមព្រះអង្គعز وجلបង្កើនចំនួនទូលព្រះបង្គំជាខ្ញុំដោយពួកគេ សូមព្រះអង្គعز وجلធ្វើឲ្យសភាទូលព្រះបង្គំជាខ្ញុំមានលំអដោយសារពួកគេ សូមព្រះអង្គعز وجلធ្វើឲ្យការចងចាំទូលព្រះបង្គំជាខ្ញុំរស់រវើកដោយសារពួកគេ សូមព្រះអង្គعز وجلធ្វើឲ្យទូលព្រះបង្គំជាខ្ញុំ*

*គ្រប់គ្រាន់ដោយសារពួកគេពេលទូលព្រះបង្គំជាខ្ញុំមិននៅ សូមព្រះអង្គﷻជួយទូលព្រះបង្គំជាខ្ញុំដោយពួកគេពេលទូលព្រះបង្គំជាខ្ញុំមានវិបត្តិ សូមព្រះអង្គﷻធ្វើឲ្យពួកគេមានចិត្តល្អប្រពៃ មានធម៌សន្តោស មានទឹកចិត្ត[ចំពោះទូលព្រះបង្គំជាខ្ញុំ] ស្មោះត្រង់ ស្តាប់ឱវាទ មិនរឹងទទឹងទេ មិនប្រឆាំងទេ មិនសាងបាបកម្មទេ ឲ្យទូលព្រះបង្គំជាខ្ញុំផង ។*

5. وَ أَعِنِّي عَلَى تَرْبِيَتِهِمْ وَ تَأْدِيبِهِمْ ، وَ بِرِّهِمْ ، وَ هَبْ لِي مِنْ لَدُنْكَ مَعَهُمْ أَوْلَاداً ذُكُوراً ، وَ اجْعَلْ ذَلِكَ خَيْراً لِي ، وَ اجْعَلْهُمْ لِي عَوْناً عَلَى مَا سَأَلْتُكَ .

*5. សូមព្រះអង្គﷻជួយទូលព្រះបង្គំជាខ្ញុំចិញ្ចឹមពួកគេ អប់រំពួកគេនិងធ្វើល្អចំពោះពួកគេ សូមព្រះអង្គﷻទ្រង់ព្រះរាជទាន មកពីព្រះអង្គﷻ ឲ្យទូលព្រះបង្គំជាខ្ញុំនូវកូនប្រុសក្នុងចំណោមកូនៗនោះ ដែលល្អសម្រាប់ទូលព្រះបង្គំជាខ្ញុំ សូមឲ្យពួកគេជាជំនួយទូលព្រះបង្គំខ្ញុំសម្រាប់អ្វីដែលទូលព្រះបង្គំជាខ្ញុំបានសូមព្រះអង្គﷻនោះ ។*

6. وَ أَعِذْنِي وَ ذُرِّيَّتِي مِنَ الشَّيْطَانِ الرَّجِيمِ ، فَإِنَّكَ خَلَقْتَنَا وَ أَمَرْتَنَا وَ نَهَيْتَنَا وَ رَغَّبْتَنَا فِي ثَوَابِ مَا أَمَرْتَنَا وَ رَهَّبْتَنَا عِقَابَهُ ، وَ جَعَلْتَ لَنَا عَدُوّاً يَكِيدُنَا ، سَلَّطْتَهُ مِنَّا عَلَى مَا لَمْ تُسَلِّطْنَا عَلَيْهِ مِنْهُ ، أَسْكَنْتَهُ صُدُورَنَا ، وَ أَجْرَيْتَهُ مَجَارِيَ دِمَائِنَا ، لَا يَغْفُلُ إِنْ غَفَلْنَا ، وَ لَا يَنْسَى إِنْ نَسِينَا ، يُؤْمِنُنَا عِقَابَكَ ، وَ يُخَوِّفُنَا بِغَيْرِكَ .

*6. សូមព្រះអង្គﷻការពារទូលព្រះបង្គំជាខ្ញុំនិងបណ្តាកូនចៅទូលព្រះបង្គំជាខ្ញុំ ពីមារស្ទៃតានلعنត្រូវបណ្តាសា ព្រោះអង្គﷻបានបង្កើតអស់ទូលព្រះបង្គំជាខ្ញុំ បានដាក់ព្រះបញ្ជាមកលើអស់ទូលព្រះបង្គំជាខ្ញុំ បានហាមអស់ទូលព្រះបង្គំជាខ្ញុំ ព្រះអង្គﷻធ្វើឲ្យអស់ទូលព្រះបង្គំជាខ្ញុំចង់បានរង្វាន់ពីព្រះបញ្ជា ដែលព្រះអង្គﷻបានដាក់មកលើអស់ទូលព្រះបង្គំជាខ្ញុំ ព្រះអង្គﷻធ្វើឲ្យអស់ទូលព្រះបង្គំជាខ្ញុំខ្លាចទណ្ឌកម្មវា ។ ព្រះអង្គﷻបានធ្វើឲ្យអស់ទូលព្រះបង្គំជាខ្ញុំមានសត្រូវមួយ ដែលប្រើឧបាយកលបៀតបៀនអស់ទូលព្រះបង្គំជាខ្ញុំ ព្រះអង្គﷻបានឲ្យវាមានអំណាចលើអ្វីមួយនៃខ្លួនអស់ទូលព្រះបង្គំជាខ្ញុំ ព្រះអង្គﷻមិនឲ្យអស់ទូលព្រះបង្គំជាខ្ញុំមានអំណាចលើអ្វីនោះទេ ព្រះអង្គﷻឲ្យអ្វីនោះចេញពីវាមកនៅក្នុងទ្រូងអស់ទូលព្រះបង្គំជាខ្ញុំ ព្រះអង្គﷻឲ្យអ្វីនោះទៅមកក្នុងសរសៃឈាមអស់ទូលព្រះបង្គំជាខ្ញុំ ។ វាមិនធ្វេសប្រហែសទេ ថ្វីដ្បិតអស់ទូលព្រះបង្គំជាខ្ញុំធ្វេសប្រហែស វាមិនភ្លេចទេថ្វីដ្បិតអស់ទូលព្រះបង្គំជាខ្ញុំភ្លេច វាធ្វើឲ្យអស់ទូលព្រះបង្គំជាខ្ញុំជឿថាគេចផុតពីព្រះទណ្ឌកម្មព្រះអង្គﷻ វាធ្វើ*

*ឲ្យអស់ទូលព្រះបង្គំជាខ្ញុំខ្លាចក្រែងអ្នកផ្សេងពីព្រះអង្គ عزوجل ។*

7. إِنْ هَمَمْنَا بِفَاحِشَةٍ شَجَّعَنَا عَلَيْهَا ، وَ إِنْ هَمَمْنَا بِعَمَلٍ صَالِحٍ ثَبَّطَنَا عَنْهُ ، يَتَعَرَّضُ لَنَا بِالشَّهَوَاتِ ، وَ يَنْصِبُ لَنَا بِالشُّبُهَاتِ ، إِنْ وَعَدَنَا كَذَبَنَا ، وَ إِنْ مَنَّانَا أَخْلَفَنَا ، وَ إِلَّا تَصْرِفْ عَنَّا كَيْدَهُ يُضِلَّنَا ، وَ إِلَّا تَقِنَا خَبَالَهُ يَسْتَزِلَّنَا .

*7. បើអស់ទូលព្រះបង្គំជាខ្ញុំជិតនឹងធ្វើអំពើមានទោស វាគាំទ្រអស់ទូលព្រះបង្គំជាខ្ញុំឲ្យធ្វើទង្វើនោះ បើអស់ទូលព្រះបង្គំជាខ្ញុំត្រៀមខ្លួនធ្វើអំពើល្អ វាពាំងអស់ទូលព្រះបង្គំជាខ្ញុំមិនឲ្យធ្វើទង្វើល្អនោះទេ ។ វាបង្ហាញខ្លួនចំពោះអស់ទូលព្រះបង្គំជាខ្ញុំតាមរយៈតណ្ហា វាញុះញង់អស់ទូលព្រះបង្គំជាខ្ញុំឲ្យធ្វើខុសដោយការសង្ស័យ ។ បើវាសន្យាអស់ទូលព្រះបង្គំជាខ្ញុំ វាកុហក បើវាធ្វើឲ្យអស់ទូលព្រះបង្គំជាខ្ញុំមានសេចក្ដីសង្ឃឹម វាមិនគោរពសម្ដីទេ ។ បើព្រះអង្គ عزوجل មិនច្រានកលល្បិចវាឆ្ងាយពីអស់ទូលព្រះបង្គំជាខ្ញុំទេ វានឹងធ្វើឲ្យអស់ទូលព្រះបង្គំជាខ្ញុំវង្វេងជាមិនខាន បើព្រះអង្គ عزوجل មិនការពារអស់ទូលព្រះបង្គំជាខ្ញុំពីការទាក់ទាញរបស់វាទេ វានឹងធ្វើឲ្យអស់ទូលព្រះបង្គំជាខ្ញុំភ្លាត់ជើង ។*

8. اللَّهُمَّ فَاقْهَرْ سُلْطَانَهُ عَنَّا بِسُلْطَانِكَ حَتَّى تَحْبِسَهُ عَنَّا بِكَثْرَةِ الدُّعَاءِ لَكَ فَنُصْبِحَ مِنْ كَيْدِهِ فِي الْمَعْصُومِينَ بِكَ .

*8. អល់ឡោះហ្ទ عزوجل អើយ សូមព្រះអង្គ عزوجل ច្រានអំណាចវាចេញឆ្ងាយពីអស់ទូលព្រះបង្គំជាខ្ញុំដោយព្រះអំណាចព្រះអង្គ عزوجل លុះព្រះអង្គ عزوجل ឃុំឃាំងវាឆ្ងាយពីអស់ទូលព្រះបង្គំជាខ្ញុំតាមរយៈការបួងសួងព្រះអង្គ عزوجل ដ៏ច្រើន លុះអស់ទូលព្រះបង្គំជាខ្ញុំបានចៀសផុតពីកលល្បិចវាដោយសារព្រះអង្គ عزوجل ។*

9. اللَّهُمَّ أَعْطِنِي كُلَّ سُؤْلِي ، وَ اقْضِ لِي حَوَائِجِي ، وَ لَا تَمْنَعْنِي الْإِجَابَةَ وَ قَدْ ضَمِنْتَهَا لِي ، وَ لَا تَحْجُبْ دُعَائِي عَنْكَ وَ قَدْ أَمَرْتَنِي بِهِ ، وَ امْنُنْ عَلَيَّ بِكُلِّ مَا يُصْلِحُنِي فِي دُنْيَايَ وَ آخِرَتِي مَا ذَكَرْتُ مِنْهُ وَ مَا نَسِيتُ ، أَوْ أَظْهَرْتُ أَوْ أَخْفَيْتُ أَوْ أَعْلَنْتُ أَوْ أَسْرَرْتُ .

*9. អល់ឡោះហ្ទ عزوجل អើយ សូមព្រះអង្គ عزوجل ឲ្យសំណូមទាំងអស់របស់ទូលព្រះបង្គំជាខ្ញុំបានសម្រេចដូចបំណង សូមព្រះអង្គ عزوجل បំពេញសេចក្ដីត្រូវការរបស់ទូលព្រះបង្គំជាខ្ញុំ សូមព្រះអង្គ عزوجل កុំឲ្យទូលព្រះបង្គំជាខ្ញុំអត់ចម្លើយដ្បិតព្រះអង្គ عزوجل បានធានាថានឹងឆ្លើយតបហើយនោះ សូមព្រះអង្គ عزوجل កុំដាក់របាំងលើការបួងសួងរបស់ទូលព្រះបង្គំជាខ្ញុំ មិនឲ្យវាទៅដល់ព្រះអង្គ عزوجل ដ្បិតព្រះអង្គ عزوجل បានបញ្ជាឲ្យទូលព្រះបង្គំជាខ្ញុំ*

*បួងសួងហើយនោះ ។ សូមព្រះអង្គ﷿ប្រទានឲ្យទូលព្រះបង្គំជាខ្ញុំនូវអ្វីដែលធ្វើឲ្យទូលព្រះបង្គំជាខ្ញុំកាន់តែប្រសើរឡើងក្នុងលោកនេះនិងក្នុងលោកមុខ អ្វីដែលទូលព្រះបង្គំជាខ្ញុំចងចាំឬអ្វីដែលទូលព្រះបង្គំជាខ្ញុំភ្លេច អ្វីដែលទូលព្រះបង្គំជាខ្ញុំបើកឲ្យឃើញឬអ្វីដែលទូលព្រះបង្គំជាខ្ញុំបិទបាំង អ្វីដែលទូលព្រះបង្គំជាខ្ញុំបង្ហាញជាសាធារណៈឬអ្វីដែលទូលព្រះបង្គំជាខ្ញុំទុកជាអាថ៌កំបាំង ។*

10. وَ اجْعَلْنِي فِي جَمِيعِ ذَلِكَ مِنَ الْمُصْلِحِينَ بِسُؤَالِي إِيَّاكَ ، الْمُنْجِحِينَ بِالطَّلَبِ إِلَيْكَ غَيْرِ الْمَمْنُوعِينَ بِالتَّوَكُّلِ عَلَيْكَ .

*10. អាស្រ័យអ្វីទាំងនេះ សូមព្រះអង្គ﷿ឲ្យទូលព្រះបង្គំជាខ្ញុំបាននៅក្នុងចំណោមបណ្តាអ្នកដែលបានកសាងខ្លួនល្អដោយបានអង្វរសូមព្រះអង្គ﷿ បណ្តាអ្នកដែលបានសម្រេចដូចបំណងពេលពួកគេអង្វរសូមព្រះអង្គ﷿ បណ្តាអ្នកដែលមិនខកចិត្តទេពេលពួកគេពឹងផ្អែកលើព្រះអង្គ﷿*

11. الْمُعَوَّدِينَ بِالتَّعَوُّذِ بِكَ ، الرَّابِحِينَ فِي التِّجَارَةِ عَلَيْكَ ، الْمُجَارِينَ بِعِزِّكَ ، الْمُوَسَّعِ عَلَيْهِمُ الرِّزْقُ الْحَلَالُ مِنْ فَضْلِكَ ، الْوَاسِعِ بِجُودِكَ وَ كَرَمِكَ ، الْمُعَزِّينَ مِنَ الذُّلِّ بِكَ ، وَ الْمُجَارِينَ مِنَ الظُّلْمِ بِعَدْلِكَ ، وَ الْمُعَافَيْنَ مِنَ الْبَلَاءِ بِرَحْمَتِكَ ، وَ الْمُغْنَيْنَ مِنَ الْفَقْرِ بِغِنَاكَ ، وَ الْمَعْصُومِينَ مِنَ الذُّنُوبِ وَ الزَّلَلِ وَ الْخَطَاءِ بِتَقْوَاكَ ، وَ الْمُوَفَّقِينَ لِلْخَيْرِ وَ الرُّشْدِ وَ الصَّوَابِ بِطَاعَتِكَ ، وَ الْمُحَالِ بَيْنَهُمْ وَ بَيْنَ الذُّنُوبِ بِقُدْرَتِكَ ، التَّارِكِينَ لِكُلِّ مَعْصِيَتِكَ ، السَّاكِنِينَ فِي جِوَارِكَ .

*11. បណ្តាអ្នកដែលរមែងតែយកព្រះអង្គ﷿ជាជម្រក បណ្តាអ្នកដែលទទួលបាននូវកម្រៃពេលធ្វើជំនួញជាមួយព្រះអង្គ﷿ បណ្តាអ្នកដែលត្រូវការពារដោយព្រះឥទ្ធិឫទ្ធិព្រះអង្គ﷿ បណ្តាអ្នកដែលត្រូវប្រទានឲ្យនូវគ្រឿងត្រូវការស្របច្បាប់ដ៏សម្បើមអាស្រ័យព្រះគុណព្រះអង្គ﷿ដ៏ឥតព្រំដែន អាស្រ័យព្រះចាគៈព្រះអង្គ﷿ដ៏វិសេសវិសាល អាស្រ័យព្រះហឫទ័យព្រះអង្គ﷿ដ៏ទូលំទូលាយ បណ្តាអ្នកដែលព្រះអង្គ﷿លើកស្ទួយបន្ទាប់ពីត្រូវគេបំបាក់មុខ បណ្តាអ្នកដែលចាកផុតពីអយុត្តិធម៌អាស្រ័យព្រះយុត្តិធម៌ព្រះអង្គ﷿ បណ្តាអ្នកដែលចាកផុតពីទុក្ខវេទនាអាស្រ័យព្រះធម៌មេត្តាព្រះអង្គ﷿ បណ្តាអ្នកដែលត្រូវរំដោះរួចពីសេចក្តីក្រីក្រអាស្រ័យព្រះភោគទ្រព្យព្រះអង្គ﷿ បណ្តាអ្នកដែលត្រូវការពារពីបាប ពីការភ្លាំងភ្លាត់ ពីកំហុសដោយសារតែខ្លាចក្រែងព្រះអង្គ﷿ បណ្តាអ្នកដែលបានជោគជ័យក្នុងការប្រព្រឹត្តល្អ ក្នុងសុភនិច្ឆ័យនិងក្នុងការដឹកនាំខ្លួនត្រឹមត្រូវដោយស្តាប់ព្រះឱវាទព្រះអង្គ﷿ បណ្តាអ្នកដែលបាំងខ្លួនពីបាបអាស្រ័យព្រះមហិទ្ធិឫទ្ធិព្រះអង្គ﷿ បណ្តាអ្នកដែលលះបង់*

*ចោលនូវបទល្មើស បណ្ដាអ្នកដែលស្ថិតនៅជិតខាងព្រះអង្គ ﷻ ។*

12. اللَّهُمَّ أَعْطِنَا جَمِيعَ ذَلِكَ بِتَوْفِيقِكَ وَ رَحْمَتِكَ ، وَ أَعِذْنَا مِنْ عَذَابِ السَّعِيرِ ، وَ أَعْطِ جَمِيعَ الْمُسْلِمِينَ وَ الْمُسْلِمَاتِ وَ الْمُؤْمِنِينَ وَ الْمُؤْمِنَاتِ مِثْلَ الَّذِي سَأَلْتُكَ لِنَفْسِي وَ لِوُلْدِي فِي عَاجِلِ الدُّنْيَا وَ آجِلِ الْآخِرَةِ ، إِنَّكَ قَرِيبٌ مُجِيبٌ سَمِيعٌ عَلِيمٌ عَفُوٌّ غَفُورٌ رَءُوفٌ رَحِيمٌ .

*12. អល់ឡោះហ្ ﷻ អឺយ សូមព្រះអង្គ ﷻ ព្រះរាជទានអ្វីៗទាំងនេះឲ្យអស់ទូលព្រះបង្គំជាខ្ញុំក្នុងព្រះនាមព្រះទានព្រះអង្គ ﷻ ក្នុងព្រះនាមព្រះធម៌មេត្តាព្រះអង្គ ﷻ សូមព្រះអង្គ ﷻ ការពារអស់ទូលព្រះបង្គំជាខ្ញុំពីទណ្ឌកម្មអណ្ដាតភ្លើង សូមព្រះអង្គ ﷻ ទ្រង់ព្រះរាជទានឲ្យបណ្ដាមុស្លីមប្រុស មុស្លីមស្រី បណ្ដាអ្នកមានសទ្ធាប្រុស អ្នកមានសទ្ធាស្រីឲ្យស្មើនឹងអ្វីៗ ដែលទូលព្រះបង្គំជាខ្ញុំបានសូមព្រះអង្គ ﷻ សម្រាប់ខ្លួនទូលព្រះបង្គំជាខ្ញុំនិងកូនៗទូលព្រះបង្គំជាខ្ញុំ ក្នុងពេលនេះនាលោកនេះនិងក្នុងពេលក្រោយនាលោកមុខ ព្រោះព្រះអង្គ ﷻ នៅជិត ព្រះអង្គ ﷻ បំពេញបំណង ព្រះអង្គ ﷻ ទ្រង់សវនាការ ព្រះអង្គ ﷻ ទ្រង់ញាណ ព្រះអង្គ ﷻ អភ័យទោស ព្រះអង្គ ﷻ អត់ឱន ព្រះអង្គ ﷻ ទ្រង់ប្រណី ព្រះអង្គ ﷻ មានព្រះមេត្តាករុណា ។*

13. وَ آتِنَا فِي الدُّنْيَا حَسَنَةً ، وَ فِي الْآخِرَةِ حَسَنَةً وَ قِنَا عَذَابَ النَّارِ .

*13. សូមអង្គព្រះមេត្តាប្រទានឲ្យអស់ទូលព្រះបង្គំជាខ្ញុំនូវអ្វីៗ ដែលល្អប្រសើរក្នុងលោកនេះ អ្វីៗដែលល្អប្រសើរក្នុងលោកមុខ ។ សូមព្រះអង្គមេត្តាស្រោចស្រង់អស់ទូលបង្គំជាខ្ញុំឲ្យផុតពីទណ្ឌកម្មភ្លើងនរកផង ។* (ស៊ូរ៉ោះត៍ អាល់-បាក៏រ៉ោះត៍ អាយ៉ាស់ 201)

## លំហាត់

ចូរសូត្រឌូអាអ៊ុំនេះរាល់ថ្ងៃពេញមួយអាទិត្យឲ្យឪពុកម្ដាយស្ដាប់ ។ គោលដៅលំហាត់នេះគឺធ្វើឲ្យអ្នកធ្លាប់សូត្រឌូអាអ៊ុំទៀងទាត់ ។

## មេរៀនទី ៣

# ហាក់ អាន់-ណាស់

حَقُّ النَّاسِ

ហាក់ អាន់-ណាស់ ជាពាក្យពីរ ។ "ហាក់" មានន័យថាសិទ្ធិ ពោលគឺសិទ្ធិរបស់ បុគ្គលម្នាក់ៗក្នុងការមានអ្វីមួយឬជាម្ចាស់អ្វីមួយ ។ "អាល់-ណាស់" មានន័យថា មនុស្សនានាឬមនុស្សជាតិ ។

ដូច្នេះ ហាក់ អាន់-ណាស់គឺសិទ្ធិមនុស្ស ។ មនុស្សគ្រប់ៗគ្នាមានសិទ្ធិមួយចំនួនដែលសំខាន់បំផុតមិនអាចដកចេញឬលុបចោលបានទេ ។

បើខ្ញុំទុកទ្រព្យរបស់កូនកំព្រា កូនកំព្រាជាម្ចាស់សិទ្ធិទទួលទ្រព្យនេះជាមរតកពេលវាធំឡើងគ្រប់អាយុ ។ ខ្ញុំមិនត្រូវប្រើប្រាស់ទ្រព្យនេះដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួនទេ ដោយអាងថាខ្ញុំជាអាណាព្យាបាល ។

អល់ឡោះហ៊្វ ﷻ អាចអត់ឱនឲ្យយើងបាន ដែលយើងបានប្រព្រឹត្តខុសទៅលើព្រះអង្គ ﷻ បើយើងដឹងកំហុសឡើងវិញនិងស្តាយក្រោយដោយស្មោះ ។ ព្រះអង្គ ﷻ អាចអត់ឱនឲ្យយើងដូចម្តេចបាន ដែលយើងប្រព្រឹត្តខុសទៅលើអ្នកដទៃនោះ ? វាផ្ទុយពីយុត្តិធម៌ព្រះអង្គ ﷻ ។ គេមិនអាចលើកទោសឲ្យយើងបានជាដាច់ខាតដែលយើងរំលោភសិទ្ធិអ្នកដទៃនោះ (ហាក់ អាន់-ណាស់) លើកលែងតែបុគ្គលដែលរងអំពើអយុត្តិធម៌នោះលើកទោសឲ្យយើង ទោះបីបុគ្គលនោះជាមុស្លីមឬមិនមែនមុស្លីមក៏ដោយ ទោះបីបុគ្គលនោះជាមនុស្សសាងបាបឬជាអ្នកមានសទ្ធាក៏ដោយ ។

សូម្បីតែអ្នកអវត្តមានក៏អ្នកត្រូវគោរពសិទ្ធិអ្នកនោះដែរ ។ ឧទាហរណ៍អ្នកនៅក្នុងអង្គប្រជុំ និយាយជាមួយអ្នកដទៃ ។ ថ្វីដ្បិតតែខ្ញុំមិននៅក្នុងអង្គប្រជុំនោះមែន តែខ្ញុំនៅតែមានសិទ្ធិជានិច្ចមិនឲ្យគេប្រមាថខ្ញុំទេ មានសិទ្ធិរក្សាកិត្តិយសខ្ញុំនិងកេរ្តិ៍ឈ្មោះខ្ញុំ ។ បានសេចក្តីថាបើអ្នកធ្វើគ៊ីបាស្ទ៍ (غِيبَة) ឬ ទុស្ហម៉ាស្ទ៍ (تُهْمَة) ឬ ហ៊្វីតណាស្ទ៍ មកលើខ្លួនខ្ញុំ អ្នកប្រព្រឹត្តបាប (ធ្វើខុស) មកលើខ្លួនខ្ញុំ ។

បាប (គឺកំហុស) នេះដែលប្រព្រឹត្តមកលើខ្លួនខ្ញុំនោះនឹងអាចលើកលែងឲ្យបានលុះត្រាតែខ្ញុំលើកលែងឲ្យ ។ អាស្រ័យហេតុនេះ យើងត្រូវចៀសវាងធ្វើប្រការ

ណាដែលបំពារបំពានសិទ្ធិអ្នកដទៃ ។ សឲ្យឃើញថាអ៊ីស្លាមជាសាសនាដែលមិនត្រឹមតែផ្តល់ផលប្រយោជន៍ដល់បុគ្គលតែម្នាក់ទេ តែជួយដល់សហគមន៍ទូទៅដែរ ។ ក្រៅពីនេះ តើយើងឃើញមានទេ ច្បាប់ដែលដាក់បញ្ញាមិនឲ្យជេរប្រមាថអ្នកដទៃ ឲ្យការពារកេរ្តិ៍ឈ្មោះអ្នកដទៃទាំងជាសាធារណៈ ទាំងអសាធារណៈ ។

អ្នកនឹងត្រូវតែសងសិទ្ធិគេវិញ (ហ្វាក្ញ់ អាន់-ណាស់) ក្រោយពីស្លាប់ ។

អ៊ីស្លាមដាស់តឿនយើងថា ឲ្យសូមទោសបុគ្គលណាដែលត្រូវយើងធ្វើខុសទៅលើមុនភាគីណាមួយស្លាប់ ។ បើភាគីដែលត្រូវគេធ្វើខុសមកលើខ្លួននោះស្លាប់មុនបានលើកទោសឲ្យភាគីមួយទៀត នឹងពុំមានមធ្យោបាយសម្រាប់ទទួលបាននូវការលើកលែងទោសដោយផ្ទាល់ទេ បាបនេះ (កំហុសនេះ) នឹងតាមអ្នកជាប់រហូតដល់ថ្ងៃជំនុំជម្រះ ។

ចូរយកចិត្តទុកដាក់នឹងគ្រោះថ្នាក់ដែលកើតមកពីបាបនេះ ។ អល់ឡោះហ្ [عز وجل] ដែលបានបង្កើតភពផែនដែនចក្រវាល ដែលអាចកម្ទេចវាចោលបានមួយប៉ប្រិចភ្នែក ដែលអាចធ្វើអ្វីៗបានតាមតែនឹកឃើញ ដែលគង់នៅមិនចេះស្លាប់ សូម្បីតែព្រះអង្គ [عز وجل] ក៏មិនអាចលើកទោសឲ្យយើងបានដែរ ដែលបានប្រព្រឹត្តខុសបទល្មើសសិទ្ធិមនុស្សនោះ ។ ព្រះអង្គផ្ទាល់ [عز وجل] មានព្រះបន្ទូលប្រាប់យើងថាមានតែបុគ្គលដែលត្រូវគេធ្វើខុសមកលើខ្លួននោះទេដែលអាចលើកទោសឲ្យបាន ។ ទោះបីបុគ្គលនោះជាមុស្លីមឬមិនមែនមុស្លីមក៏ដោយ ទោះបីបុគ្គលនោះជាមនុស្សមានសទ្ធាឬជាមនុស្សសាងបាបកម្មក៏ដោយ ។

## មេរៀនទី ៤

# ផ្សះផ្សាគេឲ្យសះជានឹងគ្នា



ផ្សះផ្សាមនុស្សឲ្យសះជាគ្នា គឺធ្វើឲ្យបុគ្គលពីរនាក់ ឬមនុស្សពីរក្រុមដែលបានបែកបាក់គ្នាបន្ទាប់ពីបានឈ្លោះគ្នាឬខ្វែងគំនិតគ្នា ។

ផ្សះផ្សាភាគីពីរដែលខ្លួនស្គាល់ ឲ្យសុខនឹងគ្នាជាករណីយកិច្ចលើមុស្លីមគ្រប់រូប ។

អល់ឡោះហ្ទ៍ﷻមានព្រះបន្ទូលនៅក្នុងព្រះគម្ពីគួរអាន (ស៊ូរ៉ោះត៍ 49 អាយ៉ាស់ 10) ថា៖

إِنَّمَا ٱلْمُؤْمِنُونَ إِخْوَةٌ فَأَصْلِحُوا۟ بَيْنَ أَخَوَيْكُمْ ۚ وَٱتَّقُوا۟ ٱللَّهَ لَعَلَّكُمْ تُرْحَمُونَ ١٠

*10. អ្នកមានសទ្ធាទាំងឡាយជាបងប្អូនគ្នា ។ ដូច្នេះចូរពួកអ្នកផ្សះផ្សាបងប្អូនពួកអ្នក ចូរខ្លាចអល់ឡោះហ្ទ៍ ដើម្បីពួកអ្នកនឹងបានទទួលនូវព្រះមេត្តាប្រណី ។*

បើអ្នកណាមួយដែលអាចផ្សះផ្សាមនុស្សពីរក្រុមបាន ដោយមិនខូចខាតអ្វីឡើយតែអ្នកនោះមិនធ្វើទេ អ្នកនោះនឹងត្រូវសាកសួរអំពីរឿងនេះក្នុងថ្ងៃជំនុំជម្រះ ។

បើគេធ្វើទុក្ខទោសមកលើខ្លួនអ្នក អ្នកមានសិទ្ធិធ្វើតបវិញស្មើគ្នា តែអ្នកគប្បីមានសីលធម៌ ជាគំរូ លើកលែងទោសឲ្យគេ ។ អល់ឡោះហ្ទ៍ﷻពន្យល់យើងរឿងនេះថា៖

وَجَزَٰٓؤُا۟ سَيِّئَةٍ سَيِّئَةٌ مِّثْلُهَا ۖ فَمَنْ عَفَا وَأَصْلَحَ فَأَجْرُهُۥ عَلَى ٱللَّهِ ۚ إِنَّهُۥ لَا يُحِبُّ ٱلظَّٰلِمِينَ ٤٠

*40. ការទូទាត់សងអំពើអាក្រក់គឺអំពើអាក្រក់ដូចគ្នា ។ តែអ្នកណាអត់ឱនហើយកែខ្លួន រង្វាន់អ្នកនោះនៅលើអល់ឡោះហ្ទ៍ ។ ពិតមែន ព្រះអង្គមិនសព្វព្រះហឫទ័យជនទុច្ចរិតទេ ។* (ស៊ូរ៉ោះត៍ 42 អាយ៉ាស់ 40)

ព្រះសន្ដអ៊ីម៉ាំអាលី صلوات الله عليه والسلام បានពន្យល់ដែរថា ផ្សះផ្សាពីរភាគីប្រៀបបាននឹងដាក់ទាន គឺៈ *"ផ្សះផ្សាពីរភាគីជាការបរិច្ចាគទានមួយប្រភេទដ៏ប្រសើរបំផុត ។"*

តែការផ្សះផ្សាមានកំណត់ ។ ថ្វីដ្បិតអ៊ីស្លាមជាសាសនាប្រកបដោយសន្តិភាពមែន តែមិននៅស្ងៀមឥតដំណើរការនោះទេ ។

បើអ្នកណាមួយប្រព្រឹត្តល្មើសច្បាប់ស្ហារីអាស់អ៊ីស្លាម ឬល្មើសបទរំលោភសិទ្ធិអ្នកដទៃ អ្នកនោះធ្វើខុសបទឧក្រិដ្ឋ ហ្វាក់ អាន់-ណាស់ ដូច្នេះត្រូវមានសកម្មភាពដើម្បីដោះស្រាយរឿងនេះ ។

وَإِن طَآئِفَتَانِ مِنَ ٱلۡمُؤۡمِنِينَ ٱقۡتَتَلُواْ فَأَصۡلِحُواْ بَيۡنَهُمَاۖ فَإِنۢ بَغَتۡ إِحۡدَىٰهُمَا عَلَى ٱلۡأُخۡرَىٰ فَقَٰتِلُواْ ٱلَّتِي تَبۡغِي حَتَّىٰ تَفِيٓءَ إِلَىٰٓ أَمۡرِ ٱللَّهِۚ فَإِن فَآءَتۡ فَأَصۡلِحُواْ بَيۡنَهُمَا بِٱلۡعَدۡلِ وَأَقۡسِطُوٓاْۖ إِنَّ ٱللَّهَ يُحِبُّ ٱلۡمُقۡسِطِينَ ٩

*9. បើអ្នកមានសទ្ធាពីរក្រុមប្រយុទ្ធគ្នា ចូរពួកអ្នកផ្សះផ្សាពួកគេ ។ តែបើអ្នកណាមួយក្នុងចំណោមពួកគេទាំងពីររំលោភទៅលើម្នាក់ទៀត ចូរពួកអ្នកប្រយុទ្ធតទល់អ្នកឈ្លានពានទាល់តែគេវិលត្រឡប់មករកព្រះបញ្ជាអល់ឡោះហ្ទ៍វិញ ។ បន្ទាប់ពីនោះ បើគេព្រមត្រឡប់វិញ ចូរពួកអ្នកផ្សះផ្សាជាមួយពួកគេដោយយុត្តិធម៌ ។ ចូរពួកអ្នកប្រព្រឹត្តសមតាមសមធម៌ ។ ពិតមែន អល់ឡោះហ្ទ៍ទ្រង់សព្វព្រះហឫទ័យអ្នកប្រព្រឹត្តសមតាមសមធម៌ ។* (ស៊ូរ៉ោះត៍ 49 អាយ៉ាស់ 9)

## ការផ្សះផ្សាមានគោលដៅអ្វី ?

មូលហេតុដែលគេឲ្យយើងផ្សះផ្សាគ្នានោះគឺដើម្បីឯកភាព ។

អ៊ីស្លាមជាសាសនាសាកលដែលផ្សះផ្សាមនុស្ស ដោយមិនគិតថាមនុស្សនោះមានរូបកាយខុសគ្នាទេ ។ យើងអាចគង់ជីវិតនិងចម្រុងចម្រើនបានលុះត្រាតែយើងមូលជុំគ្នា ។ បើយើងបែកបាក់គ្នា ឈ្លោះប្រកែកគ្នា អ្នកដទៃនឹងឆ្លៀតធ្វើឲ្យយើងបែកបាក់គ្នាខ្លាំងឡើង ។ ចូរភ្ញាក់រលឹកឡើងវិញថាព្រះបរមសាស្ដាមូហ៊ាំម៉ាដ់ صلى الله عليه وآله وسلم បានពន្យល់យើងថាៈ *"អ្នកណាមិនយកចិត្តទុកដាក់រឿងមុស្លីមទេ អ្នកនោះមិនមែនមុស្លីមទេ ។"*

## មេរៀនទី ៥

# បម្រើមនុស្សជាតិ

មកដល់ពេលនេះ អ្នកបានដឹងថាអ៊ីស្លាមជាសាសនាសម្រាប់សហគមន៍ ដើម្បីប្រតិបត្តិរួមគ្នាក្នុងសង្គម និងដើម្បីប្រមូលផ្តុំសង្គមនៅក្រោមជំនឿតែមួយ ដោយគោរពសិទ្ធិទាំងអស់គ្នា ។

មនុស្សមានគុណសម្បត្តិច្រើន ដែលខុសប្លែកពីសត្វលោកមានជីវិតឯទៀត ។ មនុស្សមានប្រាជ្ញាខ្ពស់ អាចវែកញែកឃើញខុស ឃើញត្រូវបាន ។ លក្ខណៈពិសេសមួយដែលមនុស្សនិងសត្វមានដូចគ្នា គឺសមត្ថភាពរស់នៅជុំគ្នាជាសហគមន៍ ។

ស្មារតីចេះគិតដល់អ្នកដទៃជាកម្លាំងសំខាន់បំផុត ដែលចងភ្ជាប់មនុស្សនឹងគ្នាឲ្យជាប់នៅក្នុងសង្គម ។ មនុស្សជាតិដែលគ្មានស្មារតីចេះគិតដល់គ្នានឹងក្លាយទៅជាដូចសត្វធាតុដែលនៅក្រោមច្បាប់របស់បុគ្គលខ្លាំងជាងគេ ម្នាក់ៗគិតតែប្រយោជន៍ផ្ទាល់ខ្លួន ។

អ្នកណាមួយមិនចេះប្រើសមត្ថភាពខ្លួន ដើម្បីជួយនិងណែនាំអ្នកដទៃទេ អ្នកនោះរស់នៅឥតប្រយោជន៍ ។ ទ្រឹស្តី "បម្រើអ្នកដទៃ" នេះ អ៊ីស្លាមបានសង្កត់បញ្ជាក់ច្រើនលើក ។ ព្រះបរមសាស្តាមូហ៊ាំម៉ាដ់ﷺមានព្រះវចនៈថា៖ *"អ្នកណាមិនយកចិត្តទុកដាក់រឿងមុស្លីមទេ អ្នកនោះមិនមែនមុស្លីមទេ ។ ដូចគ្នាដែរ អ្នកណាមិនឆ្លើយតបការសូមជំនួយរបស់មុស្លីមទេ អ្នកនោះមិនមែនមុស្លីមទេ ។"*

រង្វាន់តបស្នងការបម្រើមនុស្សជាតិនោះធំណាស់ ។ មានទង្វើឯទៀតតិចណាស់ដែលបានមកនូវរង្វាន់ដូចនេះដែរ ។

*"អ្នកណាបំពេញសេចក្តីត្រូវការរបស់បងប្អូនមុស្លីម ដូចអ្នកនោះបានធ្វើសក្ការៈអល់ឡោះ ﷻ មួយជីវិត ។"*

ជួនកាល គេសូមឲ្យអ្នកជួយតែអ្នកនៅក្នុងស្ថានការណ៍នីមួយដែលមិនអាច

ជួយគេបានទេ ។ ទោះបីនៅក្នុងស្ថានភាពបែបនេះក៏ដោយ បើនៀតអ្នកបរិសុទ្ធ (គឺអ្នកចង់ជួយគេដោយស្មោះ) អ្នកនឹងបានរង្វាន់ ។

ព្រះសន្ដអ៊ីម៉ាំទីប្រាំរបស់យើងصلوات الله عليه والسلامមានវចនៈថា៖ *"ជួនកាល មានមុស្លីមម្នាក់សូមជំនួយពីមុស្លីមម្នាក់ទៀតតែមុស្លីមនោះ ថ្វីដ្បិតចង់ជួយគេមែន នៅក្នុងស្ថានការណ៍នីមួយដែលមិនអាចជួយគេបាន ។ អល់ឡោះហ្ទ៍عزّ وجلّនឹងឲ្យមុស្លីមនោះចូលឋានសួគ៌ព្រោះតែគាត់បានតាំងចិត្ត ។"*

ឱវាទប្រសើរបំផុតស្ដីអំពីការបម្រើមនុស្សជាតិ អាចមកពីព្រះសន្ដអ៊ីម៉ាំហ៊ូសែន៍صلوات الله عليه والسلامដែលបានពន្យល់យើងថា៖ *"ការសុំដែលមនុស្សសុំលោកជាព្រះគុណអល់ឡោះហ្ទ៍عزّ وجلّ ដូច្នេះចូរអស់លោកកុំធុញទ្រាន់ឬទើសទាល់ឡើយ ។"*

មានកន្លែងច្រើនដែលយើងមានឱកាសជួយអ្នកដទៃ ។ មានឱកាសជួយគេច្រើនក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់យើង ក្នុងឱកាសនានាដូចជាពេលធ្វើពិធីហ្ហាច់ជាដើមដែរ ។ ពេលយើងនៅក្នុងពិធីហ្ហាច់ យើងត្រូវបម្រើអ្នកដទៃដោយវិធីល្អប្រសើរបំផុតឥតប្រៀបផ្ទឹមបាន ។ ទោះបីមនុស្សប្រព្រឹត្តហួសហេតុមកលើអ្នកឬជេរប្រមាថអ្នកក៏ដោយ ចូរអ្នកចងចាំថានៀតរបស់អ្នក (គោលបំណងអ្នក) គឺផ្គាប់ចិត្តអល់ឡោះហ្ទ៍عزّ وجلّ (លីលឡាស៊្ហ) ។

## មេរៀនទី ៦

# ក៏រ៉ដ្ធ់ អាល់-ហាសាណាស្ទ់

قرض الحسنة

នេះមានន័យថាជួយជ្រោមជ្រែងអ្នកដែលសូមជំនួយ ។ ក្នុងអ៊ីស្លាម ករណីយកិច្ចនិងឯកភាពត្រូវចងឆ្នាក់មុស្លីមទាំងអស់គ្នា ។ ករណីយកិច្ចនេះសំខាន់ណាស់ដល់ថ្នាក់ត្រូវទុកផលប្រយោជន៍សំខាន់ឯទៀតមួយអន្លើសិន ដើម្បីបំពេញករណីយកិច្ចនេះ ។

បុគ្គលដែលបានជោគជ័យ ដែលបានសម្រេចក្នុងធុរកិច្ចត្រូវអរព្រះគុណអល់ឡោះហ៍ﷻដែលបានឲ្យខ្លួនមានឱកាសទទួលបាននូវជោគជ័យ ។

អ្នកនោះមិនត្រូវអរព្រះគុណព្រះអង្គﷻដោយសម្ដី ឬដោយការបួងសួងតែម្យ៉ាងទេ តែដោយទង្វើផង ។ មធ្យោបាយល្អបំផុតសម្រាប់អរព្រះគុណអល់ឡោះហ៍ﷻគឺធ្វើប្រការនីមួយដើម្បីជួយអ្នកដទៃ ព្រោះអល់ឡោះហ៍ﷻមិនត្រូវការអ្វីឡើយ ។

ឲ្យគេខ្ចីប្រាក់ពេលគេត្រូវការ គឺឲ្យអល់ឡោះហ៍ﷻខ្ចី ។ នៅក្នុងស៊ូរ៉ោះតុ៍ អាល់-បាក៏រ៉ោះតុ៍ (2:245) អល់ឡោះហ៍ﷻមានព្រះបន្ទូលថា៖

مَّن ذَا ٱلَّذِى يُقْرِضُ ٱللَّهَ قَرْضًا حَسَنًا فَيُضَٰعِفَهُۥ لَهُۥٓ أَضْعَافًا كَثِيرَةً ۚ وَٱللَّهُ يَقْبِضُ وَيَبْصُۜطُ وَإِلَيْهِ تُرْجَعُونَ ﴿٢٤٥﴾

*245. អ្នកណាមួយឲ្យអល់ឡោះហ៍ខ្ចីដោយការឲ្យខ្ចីដ៏ល្អ ព្រះអង្គនឹងធ្វើឲ្យវាកើនឡើងលើសដើមច្រើនដងសម្រាប់អ្នកនោះ ។ អល់ឡោះហ៍រឹតត្បិត ព្រះអង្គពង្រីក [ទ្រព្យឲ្យសត្វលោក] ។ ពួកអ្នកនឹងត្រឡប់ទៅឯព្រះអង្គវិញ ។*

យើងត្រូវដឹងថាការឲ្យអល់ឡោះហ៍ﷻខ្ចី (គឺការជ្រោមជ្រែងអល់ឡោះហ៍ﷻ) គេនឹងសងវិញច្រើនលើសដើម ។ អល់ឡោះហ៍ﷻមានព្រះបន្ទូលនៅក្នុងព្រះគម្ពីរគួរអាន ស៊ូរ៉ោះតុ៍ 64 អាយ៉ាស្ទ់ 17 ដែរថា៖

إِن تُقْرِضُوا۟ ٱللَّهَ قَرْضًا حَسَنًا يُضَٰعِفْهُ لَكُمْ وَيَغْفِرْ لَكُمْ ۚ وَٱللَّهُ شَكُورٌ حَلِيمٌ ﴿١٧﴾

*17. បើពួកអ្នកឲ្យអល់ឡោះហ៍ខ្ចីដោយការឲ្យខ្ចីដ៏ល្អ ព្រះអង្គនឹងធ្វើឲ្យវាកើនឡើងយ៉ាងសម្បើម ហើយព្រះអង្គនឹងអត់ឱន[បាបកម្មពួកអ្នក]ឲ្យពួកអ្នក ។ អល់ឡោះហ៍*

*ទ្រង់ដឹងគុណ ព្រះអង្គមានព្រះខន្តី ។*

ព្រោះតែអល់ឡោះហ៊្លឲ្យអ្នកមានឱកាសទទួលបាននូវជោគជ័យ អ្នកត្រូវផ្តល់ឱកាសឲ្យអ្នកដទៃទទួលបាននូវជោគជ័យដែរ ។

បើគេមករកអ្នក សូមឲ្យអ្នកជួយ ដោយជំនួយថវិកាឬដោយជំនួយផ្សេងៗ អ្នកមានករណីយកិច្ចជួយអ្នកនោះ ។ អ្នកត្រូវឲ្យអ្នកនោះនូវចំនួនប្រាក់ដែលអ្នកនោះសូមបើអ្នកអាចធ្វើបាននិងផ្តល់ជំនួយលើសពីនេះទៀត ។

តែកាតព្វកិច្ចនេះជាកាតព្វកិច្ចទៅវិញទៅមក ។ អ៊ីស្លាមបានដាក់សម្រួលឲ្យមាន ក៏្វរ៉ដ្ធ (ក្វរដ្ធ) អាល់-ហ៊ាសាណាស្ញ់ ដើម្បីនឹងឲ្យសហគមន៍ទូទៅអាចរីកចម្រើននិងលូតលាស់បាន ព្រមនឹងមានឯកភាពនិងរួបរួមគ្នាក្នុងសម្រុងតែមួយ ។ ដូច្នេះអ្នកដែលខ្ចីប្រាក់គេត្រូវតែប៉ងប្រាថ្នាសងប្រាក់គេវិញយ៉ាងឆាប់ តាមដែលអាចធ្វើបាន ។ បើអ្នកនោះបំពានវិធានការងាយស្រួលនេះ អ្នកនោះទាញយកផលប្រយោជន៍ពីប្រព័ន្ធនេះដោយធ្វើឲ្យអ្នកដទៃខូចខាត នឹងធ្វើឲ្យគេរងការលំបាក ។

តើមានអ្វីនៅពីក្រោយទ្រឹស្តីបរិច្ចាគនេះ ? ហេតុអ្វីបានជាវាមានសារសំខាន់ខ្លាំង ?

មានពាក្យស្លោកថា គេអាចដេកលក់ពេលយប់ទោះបីបងប្អូនខ្លួនបានស្លាប់កាលពីថ្ងៃក៏ដោយ តែថ្ងៃដែលគេបាត់បង់ប្រាក់ គេនឹងលែងដេកបានសោះ ។

សឲ្យឃើញថាមនុស្សមាននិស្ស័យអាក្រក់ដូចជាសេចក្តីកំណាញ់ និងការឃើញតែផលប្រយោជន៍ផ្ទាល់ខ្លួនជាដើម ។ ពេលណាមនុស្សអាចឲ្យគេខ្ចីប្រាក់ច្រើនបានដោយមិនចង់បានកម្រៃមកវិញទេ ពេលនោះអ្នកនោះបានឈ្នះនិស្ស័យអាក្រក់ទាំងពីរនេះ ។

អ្នកនោះនឹងឈ្នះការឃើញតែផលប្រយោជន៍ផ្ទាល់ខ្លួន ដោយប្រគល់ប្រាក់ខ្លួនឲ្យទៅអ្នកដទៃដើម្បីនឹងឲ្យអ្នកដទៃមានឱកាសបានសម្រេចផលល្អ ។

អ្នកនោះនឹងឈ្នះសេចក្តីកំណាញ់ដែរ ព្រោះអ្នកនោះនឹងដឹងថាខ្លួនពុំអាចទាញយកផលប្រយោជន៍ពីប្រាក់នេះបានទេពីព្រោះវាហ៊ារ៉ាំស៊ីការប្រាក់ ។

យើងត្រូវជួយសហគមន៍យើងជានិច្ចនិងមនុស្សទូទៅ ។ បើយើងគិតមើល

បន្តិច ថ្ងៃស្អែកយើងនឹងលែងបាននៅក្នុងលោកនេះទៀត តែបញ្ជីចារអំពើយើងនឹងនៅតែបើក ។ ពេលយើងចាកចោលលោកនេះ បណ្ដាអ្នកនៅខាងក្រោយយើងនឹងចងចាំយើងដែលបានជួយពួកគេ យើងនៅតែទទួលបាននូវព្រះពរអល់ឡោះហ៊្ ﷻ ។ ម្យ៉ាងទៀត បើគេចាំបានតែថាយើងធ្លាប់តែកោងកាច ចិត្តអាក្រក់ ទ្រព្យសម្បត្តិយើងនឹងមានប្រយោជន៍អ្វីសម្រាប់យើងថ្ងៃជំនុំជម្រះនោះ ?

## មេរៀនទី ៧

# ការចម្លងប្រកបដោយវិនាសនូវវប្បធម៌ប្រទេសខាងលិច

ចម្លងគឺយកតម្រាប់តាមគេឬតាមអ្វីមួយ ក្នុងគោលបំណងក្លាយទៅជាដូចគេឬអ្វីមួយនោះ ។

វប្បធម៌គឺរបៀបរស់នៅ ។ វប្បធម៌រាប់បញ្ចូលរបៀបរស់នៅរួមគ្នារបស់មនុស្ស ការហូបចុករបស់ពួកគេ ការប្រព្រឹត្តខ្លួនរបស់ពួកគេជាទូទៅ ។ អ៊ីស្លាមមានវប្បធម៌ផ្ទាល់ខ្លួន តែបើកចំហទុកចន្លោះមួយសម្រាប់សម្របសម្រួលជាមួយទំនៀមទម្លាប់របស់វប្បធម៌ដទៃ ដរាបណាវប្បធម៌ទាំងនោះគោរពច្បាប់ស្ហារីអ៊ុស្ហ៍ (ច្បាប់អ៊ីស្លាម) ។ ដូច្នេះឯងបានជាគេហៅអ៊ីស្លាមថាសាសនាសាកល ព្រោះអ៊ីស្លាមមានរបៀបប្រព្រឹត្តខ្លួនជាមជ្ឈដ្ឋានផ្ទាល់ខ្លួន តែអនុញ្ញាតឲ្យវប្បធម៌របស់ប្រជាជាតិផ្សេងៗក្នុងពិភពលោកអាចមកចូលផងបាន ។

យើងរស់នៅក្នុងពិភពលោកប៉ែកខាងលិច វប្បធម៌ប្រទេសប៉ែកខាងលិចចោមជុំវិញខ្លួនយើង ។ វប្បធម៌ទាំងអស់សុទ្ធតែមានគុណសម្បត្តិ រាប់បញ្ចូលវប្បធម៌ពិភពលោកប៉ែកខាងលិចដែរ ។

យើងទាំងអស់គ្នា ក្មេងៗពិភពលោកប៉ែកខាងលិច ត្រូវរកមធ្យោបាយដើម្បីអាចរស់នៅបានជាមុស្លីមល្អក្នុងពិភពលោកប៉ែកខាងលិច ដោយមិនបាច់លះបង់ចោលគោលការណ៍ជំនឿយើងទេ តែដោយសម្របសម្រួលទៅតាមលោកដែលយើងរស់នៅនោះ ។ យើងអាចធ្វើដូចនេះបានដោយរើសយកតែចំណុចល្អៗនៃប្រទេសប៉ែកខាងលិច ។ តែយើងត្រូវប្រយ័តខ្លួន ព្រោះមានប្រការច្រើនដែលផ្ទុយពីវប្បធម៌អ៊ីស្លាមយើង យើងត្រូវចៀសវាងប្រការទាំងនោះ ។

អ្វីដែលយើងមិនត្រូវធ្វើគឺធ្វើតាមមិត្តយើងទាំងងងឹតងងុល ក្លាយខ្លួនទៅជាបុគ្គលទិសខាងលិចទាំងស្រុង ។ វានឹងធ្វើឲ្យយើងបាត់បង់អត្តសញ្ញាណអ៊ីស្លាមតែម្តង ។ ចូរយើងចងចាំជានិច្ចថា **យើងជាមុស្លីមមុនអ្វីៗទាំងអស់** អ្វីៗផ្សេងៗជាបន្ទាប់បន្សំ ។

នៅសាលារៀន យើងឃើញគេប្រព្រឹត្តខ្លួនខុសពីយើង ព្រោះតែយើងមិនចង់

ឲ្យគេមើលមកយើងថាប្លែកខុសពីគេ យើងចូលលាយឡំជាមួយគេនិងធ្វើដូចគេដែរ ។ នេះមិនមែនជាការយល់ឃើញល្អទេ ។ ពេលឃើញប្រុសៗពាក់ក្រវិលត្រចៀកនិងស្លៀកពាក់ដើម្បីនឹងឲ្យស្រីៗចាប់អារម្មណ៍ខ្លួន យើងត្រូវដឹងថាប្រការទាំងអស់នេះមិននៅក្នុងចំណោមប្រការ ដែលអ៊ីស្លាមបានបង្ហាត់បង្រៀនយើងទេ យើងមិនត្រូវធ្វើបែបនេះទេ ។ ក្នុងអ៊ីស្លាម គេអាចស្លៀកពាក់ល្អបានបើគេចង់ តែមិនដើម្បីឲ្យគេមើលទេ ។

ម្យ៉ាងទៀត យើងឃើញប្រុសៗនៅសាលារៀនមានមិត្តស្រី នាំគ្នាទៅរាំរែកឯរង្គសាលឬធ្វើបុណ្យជប់លៀងសប្បាយ ។ យើងមិនត្រូវប្រព្រឹត្តខ្លួនដូចនេះទេ ។ នៅបស្ចឹមប្រទេស (ប្រទេសខាងលិច) គេជ្រើសរើសមិត្តស្រីដោយមើលតែអាការរាងកាយ ។ ប្រុសៗមានមិត្តស្រីផ្សេងៗរាល់អាទិត្យ ។ អ៊ីស្លាមមិនអនុលោមទេ ។ ពេលមនុស្សប្រុសដល់អាយុអាចរៀបការបាន គេណែនាំឲ្យស្គាល់នារីដែលចង់រៀបការដែរ ដោយមានគោលបំណងដូចគ្នា មិនមែនសម្រាប់តែជាមិត្តស្រីពីរបីអាទិត្យទេ តែជាគូស្រករមួយជីវិត ។ នេះជាមូលហេតុដែលបណ្ដាលឲ្យមានការលែងលះគ្នាច្រើនណាស់នៅបស្ចឹមប្រទេស តិចណាស់នៅក្នុងលោកអ៊ីស្លាម ។

មានទម្លាប់ខ្លះដែលស្ទើរតែទូទៅនៅឯបស្ចឹមប្រទេស តែយើងត្រូវចៀសវាងទម្លាប់ទាំងនេះ ។ ឧទាហរណ៍ ពេលយើងទៅហាត់កីឡា យើងឃើញគេផ្លាស់សំលៀកបំពាក់ដោយឲ្យគេឃើញ បង្ហាញឲ្យឃើញខ្មាស ងូតទឹកស្រាត ដោយឥតអៀនខ្មាស ។ ទោះបីពួកគេទាំងអស់គ្នាជាប្រុសក៏ដោយ ក្នុងអ៊ីស្លាម ហ៊ាំរាំបើកចំហខ្មាសនៅពីមុខអ្នកដទៃឬមើលខ្មាសរបស់អ្នកដទៃ ។ បានសេចក្ដីថាពេលអ្នកផ្លាស់សំលៀកបំពាក់ អ្នកត្រូវបិទបាំងខ្លួនដោយកន្សែង ពេលអ្នកងូតទឹក អ្នកត្រូវស្លៀកឈុតងូតទឹកមួយបែប ដើម្បីនឹងកុំឲ្យស្រាតពេលណាមួយឡើយ ។ ចូរប្រយ័តខ្លួនដែរ កុំមើលគេកំពុងផ្លាស់សំលៀកបំពាក់ ។

ចូរកុំបណ្ដោយឲ្យបស្ចឹមប្រទេសបំភាន់អ្នកបាន ។ មនុស្សបស្ចឹមប្រទេសមិនជឿពិតប្រាកដថាមានឋានសួគ៌និងឋាននរកទេ ។ ពួកគេគិតថាខ្លួននឹងរស់នៅក្នុងនេះតែម្យ៉ាង ។ ហេតុដូច្នេះឯងបានជាពួកគេភ្លើតភ្លើន ការភ្លើតភ្លើនរបស់ពួកគេបានត្រឹមខ្លួន ព្រោះពួកគេមិនយល់រឿងវិញ្ញាណសោះ ។ ពួកគេបំពេញបំណងដោយកំសាន្តសប្បាយជាមួយស្រីៗ ដោយផឹកស្រានិងដោយត្រេកត្រអាលនឹងកាម ។

តែបុគ្គលមុស្លីមដឹងខ្លួនថាលោកនេះមិនឋិតថេររហូតទេ ដូចមួយប៉ប្រិចភ្នែក ប្រៀបធៀបនឹងលោកមុខ ។

នៅក្នុងជីវិតមានប្រការច្រើនទៀត ដែលសំខាន់ជាងការភ្លើតភ្លើនខ្លួន ។ អ៊ីស្លាមមិនហាមការសប្បាយទេ តែអ្នកត្រូវបំពេញបំណងផ្លូវភេទរបស់អ្នកនៅក្នុងក្របខ័ណ្ឌស្វាមីភរិយា មិនដូចសត្វទេ ។

សំខាន់បំផុតអ្នកត្រូវយល់ចំណុចនេះ ។

យើងមិនត្រូវគិតទេថា "ហេតុអ្វីពួកគេអាចសប្បាយបាន យើងសប្បាយមិនបាន ?" ព្រោះយូៗទៅវានឹងធ្វើឲ្យជ្រេញ ។ បើអ្នកហូបការេមរាល់ថ្ងៃ យូរៗទៅអ្នកនឹងធុញទ្រាន់ ។ អ្នកលែងចង់ហូបទៀត ។ ដូចគ្នាដែរ អ៊ីស្លាមបង្ហាត់យើងឲ្យចេះគ្រប់គ្រងចំណង់យើង ។ យើងត្រូវទប់ខ្លួន ។ បើយើងបណ្តោយខ្លួន មិនទប់ខ្លួនគ្មានការហាមឃាត់ខ្លួនឯងដូចពួកស្ទឹមប្រទេស យើងនឹងសប្បាយតែមួយពេលទេ មិនយូរប៉ុន្មានយើងនឹងប្រាប់ខ្លួនឯងថា៖ "ក្នុងជីវិតត្រូវតែមានអ្វីផ្សេងពីការសប្បាយស្រី (ឬប្រុស) និងស្រា ។"

ក្នុងជីវិតមានអ្វីៗច្រើនណាស់ ។ អ៊ីស្លាមបើកភ្នែកយើង ធ្វើឲ្យយើងមើលតាមការយល់ឃើញផ្សេង ។ បើអ្នកគិតថាលោកនេះជាផ្លូវខ្វាត់ខ្វែង លោកប៉ែកខាងលិចពេញចិត្តតែនឹងការដើរលេងតាមផ្លូវខ្វាត់ខ្វែងនេះប៉ុណ្ណោះ ដោយចាប់យកអ្វីដែលខ្លួនប្រទះ ។ អ៊ីស្លាមលើកអ្នកឡើងទៅលើផ្លូវខ្វាត់ខ្វែងនោះ ធ្វើឲ្យអ្នកអាចមើលឃើញអ្វីៗពីទីខ្ពស់ ដើម្បីអ្នកនឹងអាចដឹងបានថាត្រូវយកផ្លូវណា ត្រូវចៀសវាងផ្លូវណា ។ នេះគឺវិធីតែមួយគត់សម្រាប់ឆ្លងកាត់ផ្លូវខ្វាត់ខ្វែង ។

ទម្លាប់មួយទៀតដែលយើងត្រូវចៀសវាងគឺជក់បារី ។ ជក់បារីជាប្រការគ្រោះថ្នាក់និងធ្វើឲ្យយើងញៀន ។ ជក់បារីជាប្រាការ ម៉ាក់រុស្វ (مكروه) ក្នុងអ៊ីស្លាម (គួរឲ្យស្អប់ ដូច្នេះត្រូវចៀសវាង) ។ គេឃើញក្មេងប្រុស ក្មេងស្រីជក់បារីពេលបរិភោគបាយថ្ងៃ ឬតាមផ្លូវត្រឡប់ទៅផ្ទះវិញ ។ ជួនកាលពួកគេមកជិតយើង សួរយើងថាចង់បឺតមួយខ្សឹតទេ ។ ចូរកុំខ្លាចថា ទេ ! ទោះបីពួកគេគិតអំពីអ្នកថាអ្វីក៏ដោយ ថាអ្នកកំសាកឬមិនកំសាកក៏ដោយ ចូរអ្នកកុំបណ្តោយខ្លួនឲ្យគេអូសទាញទៅរកអ្វីដែលមិនល្អសម្រាប់សុខភាពអ្នកឡើយ ជាពិសេសក្នុងវ័យក្មេង ។

សូមអង្វរ ចូរអ្នកចងចាំថា អ៊ីស្លាមពិតជាសាសនាដែលធ្វើឲ្យមនុស្សមានសុខុមាលភាពនិងស្កប់ស្កល់ផ្លូវចិត្ត ។ ចូរកុំធ្វើតាមទង្វើរបស់មនុស្សប៉ែកខាងលិចដែលអ៊ីស្លាមហាមឡើយ ។ វាដូចជាងាយស្រួលមួយរយៈពេល តែអ្នកនឹងឃើញផលវិបត្តិនៅទីបំផុត ។

**មេរៀនទី ៨**

# ហ៊ុសនុស្ស-ស្ហាន់ និង ស៊ូអ៊ុស្ស-ស្ហាន

حسن الظن سوء الظن

កន្សោមពាក្យទាំងពីរនេះមានន័យផ្ទុយគ្នា ស្តីអំពីយោបល់ដែលអ្នកមានអំពីអ្នកដទៃ ។

មនុស្សមានពីរប្រភេទគឺៈ មានមនុស្សដែលគិតអាក្រក់ជានិច្ចអំពីអ្នកដទៃ និងមានមនុស្សដែលព្យាយាមគិតល្អអំពីអ្នកដទៃ ។

ហ៊ុសនុស្ស-ស្ហាន់ គឺការមានយោបល់ល្អអំពីអ្នកដទៃ ។ មិនគិតអាក្រក់អំពីអ្នកដទៃទេ មិនសង្ស័យទង្វើអ្នកដទៃទេ ។ បើអ្នកឃើញបុរសមុស្លីមណាម្នាក់និយាយជាមួយនារីមិនមែនម៉ាស្ហ៊រ៉មទេ (គឺនារីសះនីកាស្ហ) អ្នកស្មានថាគាត់បានណាត់ជួបគ្នាជាមួយនារីនោះឬគាត់ខ្វះសីលធម៌ អ្នកបានធ្វើឲ្យកេរ្តិ៍ឈ្មោះគាត់ប្រេះស្រាំស្រេចហើយសម្រាប់ខ្លួនអ្នក ។ ពេលអ្នកនិយាយប្រាប់អ្នកដទៃឲ្យដឹងយោបល់អ្នក អ្នកបានប្រព្រឹត្ត ហ្ស៊ីតណាស្ហ និង ហ្វាសាដ្ហ ។ អ្នកត្រូវខំយល់អំពីមូលហេតុដែលគាត់ប្រព្រឹត្ត ។ ទោះបីការសង្ស័យរបស់អ្នកទៅជាពិតក៏ដោយ អ្នកមានសិទ្ធិអ្វីសាបព្រោះកំហុសអ្នកដទៃ ថ្វីដ្បិតអល់ឡោះហ្ស៊ﷻបិទបាំងកំហុសអ្នក ?

ពេលអ្នកណាមួយស្មានក្នុងចិត្តថាអ្នកដទៃធ្វើអាក្រក់ គេហៅអំពើនេះថាស៊ូអ៊ុស្ស-ស្ហាន នេះជាទម្លាប់អាក្រក់ណាស់ ។ អំពើនេះនាំទៅរក ហ្ស៊ីតណាស្ហ និង ហ្វាសាដ្ហ និងទង្វើគួរឲ្យខ្លាចច្រើនទៀត ។

ឧទាហរណ៍ បើអ្នកណាមួយងើបឡើង បរិច្ចាគទានប្រាក់ច្រើនពាន់អឺរ៉ូ ខ្ញុំអាចគិតបានពីរយ៉ាង ។ ខ្ញុំអាចគិតបានថាអ្នកនោះអួតខ្លួនឯងដោយបង្ហាញគេថាខ្លួនមានប្រាក់ច្រើន ឬខ្ញុំអាចគិតបានដែរថាអ្នកនោះស្មោះត្រង់ គាត់ជាគំរូសម្រាប់អ្នកដទៃដែលគួរយកតម្រាប់តាម ។

ព្រះគម្ពីរគួរអាន (ស៊ូរ៉ោះត៍ 49:12) ចែងប្រាប់យើងឲ្យចៀសវាងសង្ស័យអ្នកដទៃ ព្រោះជួនកាលវាអាចជាបាបមួយ ជាពិសេសពេលពាក្យនិយាយតៗគ្នាពុំសុសសាយ ។

يَـٰٓأَيُّهَا ٱلَّذِينَ ءَامَنُوا۟ ٱجْتَنِبُوا۟ كَثِيرًا مِّنَ ٱلظَّنِّ إِنَّ بَعْضَ ٱلظَّنِّ إِثْمٌ ۖ وَلَا تَجَسَّسُوا۟ وَلَا يَغْتَب بَّعْضُكُم بَعْضًا ۚ أَيُحِبُّ أَحَدُكُمْ أَن يَأْكُلَ لَحْمَ أَخِيهِ مَيْتًا فَكَرِهْتُمُوهُ ۚ وَٱتَّقُوا۟ ٱللَّهَ ۚ إِنَّ ٱللَّهَ تَوَّابٌ رَّحِيمٌ ﴿١٢﴾

*12. បណ្ដាអ្នកមានសទ្ធាអើយ ចូរពួកអ្នកចៀសវាងប៉ាន់ស្មាន ព្រោះការពិត ក្នុងករណីខ្លះ ប៉ាន់ស្មានជាបាប ។ ចូរពួកអ្នកកុំលបយកការណ៍ ។ ចូរពួកអ្នកកុំនិយាយបង្កាច់អ្នកឯទៀត ។ តើមានអ្នកណាម្នាក់ក្នុងចំណោមពួកអ្នកចូលចិត្តស៊ីសាច់បងប្អូនឯងដែលស្លាប់នោះទេ ? ពួកអ្នកពិតជាស្អប់ខ្ពើមអំពើនេះខ្លាំងណាស់ ។ ចូរពួកអ្នកខ្លាចអល់ឡោះហ្វ ។ ពិតមែន អល់ឡោះហ្វរមែងតែបែរត្រឡប់ (ប្រោសប្រណីគឺទទួលការសូមខមាទោស) ព្រះអង្គមានព្រះធម៌មេត្តា ។*

មនុស្សដែលមានចិត្តមិនទូលាយមិនចង់ធ្វើល្អខ្លួនឯងទេ និងមិនចង់ឲ្យអ្នកដទៃធ្វើល្អទេ ។ មនុស្សបែបនេះព្យាយាមបង្ខូចកិត្តិយសអ្នកដទៃរាល់ពេលដែលខ្លួនមានឱកាស ។ ស៊ូអ៊ុស្ស-ស្ម៉ននាំទៅរកប្រការនេះឯង ។

អល់ឡោះហ្វ៏ﷻបង្ហាញនូវព្រះពិរោធ ទៅលើបុគ្គលដែលចោទប្រកាន់គេមិនពិត ។ សម័យព្រះសាស្ដានុះហ្វ៉ﷺ គេបានចោទបង្កាច់ព្រះអង្គﷺ ព្រះអង្គﷺ បានសូមអល់ឡោះហ្វ៏ﷻឲ្យជួយ ។ អាយ៉ាស់តទៅនេះចែងបំភ្លឺប្រព្រឹត្តិការណ៍នេះ ។

قَالَ رَبِّ ٱنصُرْنِى بِمَا كَذَّبُونِ ﴿٣٩﴾

*39. គេ (នុះហ្វ៉) បានទូលថា៖ "ព្រះម្ចាស់អើយ សូមព្រះអង្គជួយទូលព្រះបង្គំជាខ្ញុំផង ព្រោះពួកគេចោទទូលព្រះបង្គំជាខ្ញុំថានិយាយមុសា ។"*(ស៊ូរ៉ោះត៍ 23:39)

قَالَ عَمَّا قَلِيلٍ لَّيُصْبِحُنَّ نَـٰدِمِينَ ﴿٤٠﴾

*40. ព្រះអង្គមានព្រះបន្ទូលថា៖ "បន្តិចទៀតពួកគេនឹងស្ដាយក្រោយ ។"* (ស៊ូរ៉ោះត៍

23:39)

فَأَخَذَتۡهُمُ ٱلصَّيۡحَةُ بِٱلۡحَقِّ فَجَعَلۡنَٰهُمۡ غُثَآءٗۚ فَبُعۡدٗا لِّلۡقَوۡمِ ٱلظَّٰلِمِينَ ﴿٤١﴾

*41. សម្រែកបានច្បាមពួកគេដោយយុត្តិធម៌ (ជាលទ្ធផលនៃអំពើអសប្បុរសរបស់ពួកគេ) ។ យើងបានធ្វើឲ្យពួកគេទៅជាកម្ទេច ។ ចូរជនទុច្ចរិតទាំងឡាយវិនាសអស់ទៅ ។*(ស៊ូរ៉ោះគ្ហ៍ 23:39)

ដើម្បីបញ្ចប់សេចក្ដី ចូរអ្នកកុំសង្ស័យអ្នកដទៃ (ចូរទុកឱកាសអ្នកដទៃអធិប្បាយបំភ្លឺទង្វើរបស់ខ្លួន) ។ ទោះបីអ្នកដឹងប្រាកដថាអ្នកនោះធ្វើអាក្រក់ក៏ដោយ ចូរកុំនិយាយប្រាប់អ្នកដទៃ ។ ហេតុតែអល់ឡោះហ្ជ៍ﷻបិទបាំងរឿងសម្ងាត់របស់យើង យើងក៏ត្រូវបិទបាំងរឿងសម្ងាត់របស់អ្នកដទៃដែរ ។ បើអ្នកចង់ធ្វើប្រតិកម្មនីមួយ ចូរទៅជួបអ្នកនោះ ពន្យល់ប្រាប់អ្នកនោះថាខ្លួនកំពុងតែធ្វើខុស ។ បើអ្នកគិតថាមិនបានសម្រេចទេ ចូរនិយាយប្រាប់អ្នកណាម្នាក់ដែលអ្នកគិតថាគាត់អាចជួយអ្នកនោះបាន ។ នេះគឺទ្រឹស្ដី អាំរ៉ូ ប៊ិល ម៉ាក់រុហ្វ វ៉ា អាន់-ណាស្ហ៍យ៉ា អ៊ុនីល-មុនការ (اَلْأَمْرَ بِالْمَعْرُوفِ وَ النَّهْيَ عَنِ الْمُنْكَرِ - បង្គាប់ឲ្យធ្វើល្អនិងហាមធ្វើអាក្រក់) ។

**មេរៀនទី ៩**

# កាស្ម៉ុល-ក្ហយ៉្ស

كَظْم الغَيْظ

កាស្ម៉ុល-ក្ហយ៉្ស គឺលេបកំហឹង ការអត់ឱនឲ្យអ្នកដទៃ ។

កាស្ម៉ុល-ក្ហយ៉្សស្រដៀងអំណត់ដែរ តែផ្តោតទៅលើការដែលគេប្រព្រឹត្តខុសមកលើខ្លួន វាជាទង្វើមួយដែលអ៊ីស្លាមណែនាំឲ្យខំធ្វើដែរ ។

ពាក្យស្លោកថា "កប់ពូថៅសង្គ្រាម" មានន័យថា ជួសការសងសឹក (ពោលគឺដោយពូថៅ) យើងគប្បីកប់ពូថៅនោះចោលក្នុងដី បំភ្លេចចោល ។ មានពាក្យស្លោកមួយទៀតដែរថា "អត់ឱនហើយបំភ្លេចវាចោល" មានន័យដូចគ្នា ។

មិនបានសេចក្តីថាអ្នកត្រូវបណ្តោយឲ្យគេជាន់ក្បាលអ្នក ហើយអត់ទោសឲ្យគេនោះទេ ។ អនុវត្តិសម្រាប់បណ្តាបុគ្គលដែលអ្នកមានអាជ្ញាលើខ្លួនពួកគេ សម្រាប់បណ្តាអ្នកដែលធ្វើខុសមកលើខ្លួនអ្នកដោយអចេតនា ឬបណ្តាអ្នកដែលស្តាយក្រោយ ។

កំហឹងជាថ្នាំលេបមួយគ្រាប់ដែលល្វីងសម្រាប់លេប ទាល់តែអ្នកប្រើកម្លាំងចិត្តអត់ទ្រាំខ្លាំងណាស់ទើបអាចលេបវាចូលក្នុងពោះបាន ។ ព្រះបរមសាស្តាមូហ៊ាំម៉ាដ្ ﷺ មានព្រះវចនៈថា៖

*"អ្នកខ្លាំងជាងគេក្នុងចំណោមអស់លោកគឺអ្នកដែលទប់ខ្លួនបានពេលក្រោធ ។ អ្នកមានសន្តោសជាងគេក្នុងចំណោមអស់លោកគឺអ្នកដែលអត់ឱន លើកលែង ពេលអ្នកនោះមានប្រៀបលើសត្រូវខ្លួន ។"*

*"អស់លោកគិតថាគេវាស់ស្ទង់កម្លាំងអាស្រ័យលើសមត្ថភាពលើកដុំថ្ម (ធ្ងន់) តែការពិតវាអាស្រ័យលើសមត្ថភាពទប់ខ្លួនឯងពេលត្រូវកំហឹងឆេះឆួល ។"*

មធ្យោបាយលេបកំហឹងគឺធ្វើឲ្យអារម្មណ៍ស្ងប់ ។

*"កំហឹងចេញមកពីស្ហៃតន ដែលត្រូវបង្កើតពីភ្លើង ។ គេពន្លត់ភ្លើងដោយទឹក ដូច្នេះហើយបានជារាល់ពេលដែលអ្នកមានអារម្មណ៍ថាក្រោធ អ្នកត្រូវយកទឹកវូឌុអ៍ ។"*

ទឹកវូឌុអ៍មានប្រសិទ្ធភាពធ្វើឲ្យខ្លួនស្ងប់ ធូរស្រាល ។ វាធ្វើឲ្យយើងនឹកនាដល់អល់ឡោះហ្ស៊ូ عزوجل ដែរ ដូច្នេះយើងអាចទប់ខ្លួនបាន ។

ព្រះសន្តអ៊ីម៉ាំអាលី صلوات الله عليه والسلام មានព្រះវចនៈថា៖ *"ពេលអ្នកកំពុងឈរ ហើយកើតមានកំហឹងឡើង អ្នកត្រូវអង្គុយចុះ ។ បើអ្នកកំពុងអង្គុយហើយក៏កើតមានកំហឹងឡើង អ្នកត្រូវផ្តេកខ្លួន ។"*

រាល់គ្នាបានធ្វើបាបមួយដងក្នុងជីវិត បានប្រព្រឹត្តអំពើដែលមានទោស ។ តែបើអល់ឡោះហ្ស៊ូ عزوجل ព្រះដ៏មានព្រះធម៌មេត្តាលើសលុប អាចអត់ឱនឲ្យយើងបាន តើយើងមានសិទ្ធិអ្វីក្រោធបណ្តាអ្នកដែលស្តាយក្រោយបន្ទាប់ពីបានធ្វើខុស ?

*"អល់ឡោះហ្ស៊ូ عزوجل មានព្រះបន្ទូលថា៖ "កូនអាដាំ عليه السلام អើយ ចូរពួកអ្នកនឹកដល់អញ عزوجل ពេលពួកអ្នកក្រោធ ដើម្បីអញ عزوجل នឹងនឹករលឹកដល់ពួកអ្នកពេលពួកអ្នកសមនឹងរងព្រះពិរោធអញ عزوجل ហើយអញ عزوجل នឹងមិនកម្ទេចពួកអ្នកចោល ។"*

ព្រះគម្ពីរគួរអានថែងប្រាប់យើងដែរថា៖

۞وَسَارِعُوٓاْ إِلَىٰ مَغۡفِرَةٖ مِّن رَّبِّكُمۡ وَجَنَّةٍ عَرۡضُهَا ٱلسَّمَٰوَٰتُ وَٱلۡأَرۡضُ أُعِدَّتۡ لِلۡمُتَّقِينَ ١٣٣ ٱلَّذِينَ يُنفِقُونَ فِي ٱلسَّرَّآءِ وَٱلضَّرَّآءِ وَٱلۡكَٰظِمِينَ ٱلۡغَيۡظَ وَٱلۡعَافِينَ عَنِ ٱلنَّاسِۗ وَٱللَّهُ يُحِبُّ ٱلۡمُحۡسِنِينَ ١٣٤

*133. ចូរពួកអ្នកប្រញាប់ឆ្ពោះទៅរកការអភ័យទោសរបស់ព្រះម្ចាស់ពួកអ្នក និងសួនសួគ៌ដែលមានផ្ទៃទូលាយស្មើបណ្តាមេឃនិងផែនដី ត្រៀមទុកសម្រាប់បណ្តាអ្នកមានសទ្ធាស៊ប់ចិត្ត[ចំពោះអល់ឡោះហ្ស៊ូ] 134. [ទុកសម្រាប់]បណ្តាអ្នកដែលបរិច្ចាគ[លើមាគ៌ាអល់ឡោះហ្ស៊ូ] ពេលមានទ្រព្យនិងពេលទ័លទ្រព្យ [ទុកសម្រាប់]បណ្តាអ្នកដែលទប់កំហឹងនិងអត់ឱនឲ្យបណ្តាមនុស្ស ។ អល់ឡោះហ្ស៊ូសព្វព្រះហឫទ័យ*

*បណ្តាអ្នកប្រព្រឹត្តល្អ[ចំពោះអ្នកដទៃ] ។* (ស៊ូរ៉ោះត៍ 3 (អាលី អ៊ីមរ៉ន) អាយ៉ាស៍ 133-134)

ព្រះសន្តអ៊ីមុាំ មូសា អាល់-កាស៊្ទីមصلوات الله عليه والسلام មានព្រះឋានន្តរស័ក្តិថា អាល់-កាស៊្ទីម ដោយមូលហេតុនេះឯង ។ ព្រះអង្គصلوات الله عليه والسلامជាគំរូរបស់បណ្តាអ្នកដែលលេបកំហឹង ។ ព្រះអង្គصلوات الله عليه والسلامត្រូវគេប្រព្រឹត្តបំពារបំពានលើរគួរស្អប់ខ្ពើមខ្លាំងណាស់ បណ្តាពួកសង្កត់សង្កិតព្រះអង្គصلوات الله عليه والسلامបានឃុំឃាំងព្រះអង្គصلوات الله عليه والسلامក្នុងពន្ធនាគារ លុះព្រះអង្គصلوات الله عليه والسلام សោយព្រះទិវង្គត តែព្រះអង្គصلوات الله عليه والسلامទប់កំហឹង ស៊ូទ្រាំនិងអត់ធ្មត់ ។

ស៊ូរ៉ោះត៍ 42 (ស៊ូរ៉ោះត៍ អាស្ស៊ូរ៉) អាយ៉ាស៍ 36-41 បំភ្លឺថា៖

فَمَآ أُوتِيتُم مِّن شَيْءٍ فَمَتَٰعُ ٱلْحَيَوٰةِ ٱلدُّنْيَا ۖ وَمَا عِندَ ٱللَّهِ خَيْرٌ وَأَبْقَىٰ لِلَّذِينَ ءَامَنُوا۟ وَعَلَىٰ رَبِّهِمْ يَتَوَكَّلُونَ ﴿٣٦﴾ وَٱلَّذِينَ يَجْتَنِبُونَ كَبَٰٓئِرَ ٱلْإِثْمِ وَٱلْفَوَٰحِشَ وَإِذَا مَا غَضِبُوا۟ هُمْ يَغْفِرُونَ ﴿٣٧﴾ وَٱلَّذِينَ ٱسْتَجَابُوا۟ لِرَبِّهِمْ وَأَقَامُوا۟ ٱلصَّلَوٰةَ وَأَمْرُهُمْ شُورَىٰ بَيْنَهُمْ وَمِمَّا رَزَقْنَٰهُمْ يُنفِقُونَ ﴿٣٨﴾ وَٱلَّذِينَ إِذَآ أَصَابَهُمُ ٱلْبَغْىُ هُمْ يَنتَصِرُونَ ﴿٣٩﴾ وَجَزَٰٓؤُا۟ سَيِّئَةٍ سَيِّئَةٌ مِّثْلُهَا ۖ فَمَنْ عَفَا وَأَصْلَحَ فَأَجْرُهُۥ عَلَى ٱللَّهِ ۚ إِنَّهُۥ لَا يُحِبُّ ٱلظَّٰلِمِينَ ﴿٤٠﴾ وَلَمَنِ ٱنتَصَرَ بَعْدَ ظُلْمِهِۦ فَأُو۟لَٰٓئِكَ مَا عَلَيْهِم مِّن سَبِيلٍ ﴿٤١﴾

*36. អ្វីក៏ដោយដែលគេបានឲ្យពួកអ្នកនោះ វាគ្រាន់តែជារបស់របរសម្រាប់ជីវិតលោកនេះទេ ។ អ្វីដែលនៅឯអល់ឡោះហ្ម៍ប្រសើរបំផុតនិងឋិតថេរសម្រាប់ជនទាំងឡាយណាដែលមានសទ្ធា ដែលពឹងផ្អែកលើព្រះម្ចាស់ខ្លួន ។ 37. ពួកដែលចៀសវាងសាងបាបធំនិងអំពើអសីលធម៌ ហើយ**ពួកគេអត់ឱនពេលក្រេវក្រោធ** ។ 38. ពួកដែលឆ្លើយតបព្រះម្ចាស់ខ្លួន ដែលធ្វើនមស្ការមិនដាច់ ដែលពិភាក្សាគ្នាអំពីរឿងរបស់ខ្លួន ដែលបរិច្ចាគអ្វីដែលយើងបានប្រទានឲ្យ ។ 39. ពួកដែលការពារខ្លួនពេលរងអំពើអយុត្តិធម៌ ។ 40. ការទូទាត់សងអំពើអាក្រក់គឺអំពើអាក្រក់ដូចគ្នា ។ **តែអ្នកណាអត់ឱន**ហើយកែខ្លួន រង្វាន់អ្នកនោះនៅលើអល់ឡោះហ្ម៍ ។ ពិតមែន ព្រះអង្គមិនសព្វព្រះហឫទ័យជនទុច្ចរិតទេ ។ 41. អ្នកណាការពារខ្លួនក្រោយពីបានទទួលរងអំពើអយុត្តិធម៌ អ្នកនោះមិនមានទោសទេ ។*

## មេរៀនទី ១០

# អ៊ិះខ្ល៉ាស់

الإخلاص

អ៊ិះខ្ល៉ាស់មានន័យថាស្មោះអស់ពីចិត្តនិងត្រង់គ្រប់ប្រការ ។
ស្មោះអស់ពីចិត្តមានន័យថាមាត់ថាអ្វីចិត្តគិតអញ្ចឹងដែរ ។

យើងត្រូវតែស្មោះក្នុងគ្រប់ទង្វើ ។ ថ្វីដ្បិតហាក់ដូចជាងាយស្រួល វាជាប្រការមួយដែលពិបាកធ្វើជាងគេ ។ ចូរអ្នកសួរខ្លួនឯងថា៖ "តើខ្ញុំស្មោះដល់កម្រិតណាពេលខ្ញុំស៊ូឡាត់ ?"

ហេតុអ្វីពិបាកស្មោះម្ល៉េះ ?

កាលអល់ឡោះហ្ស៊ីបង្កើតមនុស្ស ព្រះអង្គហ្ស៊ីមានព្រះបន្ទូលថា៖

وَإِذْ قَالَ رَبُّكَ لِلْمَلَٰٓئِكَةِ إِنِّى جَاعِلٌ فِى ٱلْأَرْضِ خَلِيفَةً ۖ قَالُوٓا۟ أَتَجْعَلُ فِيهَا مَن يُفْسِدُ فِيهَا وَيَسْفِكُ ٱلدِّمَآءَ وَنَحْنُ نُسَبِّحُ بِحَمْدِكَ وَنُقَدِّسُ لَكَ ۖ قَالَ إِنِّىٓ أَعْلَمُ مَا لَا تَعْلَمُونَ ﴿٣٠﴾

*30. កាលព្រះម្ចាស់អ្នកបានត្រាស់ទៅកាន់បណ្ដាទេវតាថា៖ "អញនឹងដាក់នៅឯផែនដីនូវខលីហ្វាមួយរូប ។" ពួកគេបានទូលថា៖ "ព្រះអង្គនឹងបង្កើតអ្នកបង្កវិនាស និងបង្ហូរឈាមនៅលើនោះឬ រីឯពួកទូលព្រះបង្គំជាខ្ញុំវិញគោរពបូជាដោយសេចក្ដីស្ញើចសរសើរព្រះអង្គ និងប្រកាសជាឱឡារិកព្រះសុចិភាពដ៏ពិសិដ្ឋនៃព្រះអង្គ ?" ព្រះអង្គមានព្រះបន្ទូលថា៖ "អញដឹងនូវអ្វីដែលពួកអ្នកមិនដឹង ។"* (ស៊ូរ៉ោះត៍ អាល់-បាក៏រ៉ោះត៍ អាយ៉ាស់ 30)

មានន័យថាពួកទេវតាមិនដឹងទេ ថាអល់ឡោះហ្ស៊ីបានរៀបផែនការអ្វីសម្រាប់សត្វលោករបស់ព្រះអង្គហ្ស៊ីដែលប្រសើរជាច់គេនោះ ។

ពួកទេវតាមានអារម្មណ៍តែមិនមានចំណង់ទេ ។ អាស្រ័យហេតុនេះឯងបានជាពួកទេវតាពុំនៅក្រោមការល្បួងទាក់ទាញចិត្ត ។ ពួកគេធ្វើអ្វីដែលគេដាក់ឲ្យធ្វើ

ពួកគេមិនចង់បានអ្វីសម្រាប់ខ្លួនឯងទេ ។ ពួកគេចេះគិត តែពុំមានអ្វីបញ្ចេះពួកគេឲ្យល្មើសព្រះបញ្ញាអល់ឡោះហ្ស៍ﷻទេ ។

អល់ឡោះហ្ស៍ﷻបានបង្កើតមនុស្ស បានប្រគល់គុលប្បាការ (គឺចេះថ្លឹងមើល) ឲ្យមនុស្ស ។ នៅក្នុងពិភពដែលសព្វសារពើសុទ្ធតែមានប៉ែកផ្ទុយរបស់វា - ខ្មៅនិងស ល្អនិងអាក្រក់ - អល់ឡោះហ្ស៍ﷻបានប្រទាន**ហ្វ៊ូរក្វន**ឲ្យមនុស្ស គឺសមត្ថភាពវិនិច្ឆ័យរវាងប៉ែកផ្ទុយទាំងពីរ ។

បន្ទាប់មកអល់ឡោះហ្ស៍ﷻបានបង្កើតប៉ែកមួយរបស់ណាហ្វ់យើង ដែលទទួលសម្តីរបស់ស្ហៃតន (لعنه الله) ។ វានៅក្នុងជម្រៅចិត្តយើង វាខ្សឹបប្រកាសអាក្រក់ដាក់ក្នុងគំនិតយើង ។ នៅក្នុងព្រះគម្ពីរគួរអានស៊ូរ៉ោះត៍ 114 អាយ៉ាស់ 4-5 យើងសូមឲ្យអល់ឡោះហ្ស៍ﷻការពារយើងពីអ្នកខ្សឹបខ្សៀវនេះ ពីគំនិតដែលវាព្យាយាមដាំនៅក្នុងអារម្មណ៍យើង ។ យើងត្រូវច្បាំងទល់នឹងវានេះឯង ។

ស្ហៃតន (لعنه الله) សូមអល់ឡោះហ្ស៍ﷻឲ្យបណ្តោយវា (لعنه الله) ធ្វើអ្វីៗបានតាមចិត្ត រហូតដល់ថ្ងៃជំនុំជម្រះ ។ អល់ឡោះហ្ស៍ﷻយល់ព្រម ស្ហៃតន (لعنه الله) បានថាវា (لعنه الله) នឹងធ្វើឲ្យមនុស្សចោលអល់ឡោះហ្ស៍ﷻ ។

ស៊ូរ៉ោះត៍ 15 អាយ៉ាស់ 36-43 ចែងថា៖

قَالَ رَبِّ فَأَنظِرْنِيٓ إِلَىٰ يَوْمِ يُبْعَثُونَ ﴿٣٦﴾ قَالَ فَإِنَّكَ مِنَ ٱلْمُنظَرِينَ ﴿٣٧﴾ إِلَىٰ يَوْمِ ٱلْوَقْتِ ٱلْمَعْلُومِ ﴿٣٨﴾ قَالَ رَبِّ بِمَآ أَغْوَيْتَنِي لَأُزَيِّنَنَّ لَهُمْ فِي ٱلْأَرْضِ وَلَأُغْوِيَنَّهُمْ أَجْمَعِينَ ﴿٣٩﴾ إِلَّا عِبَادَكَ مِنْهُمُ ٱلْمُخْلَصِينَ ﴿٤٠﴾ قَالَ هَٰذَا صِرَٰطٌ عَلَيَّ مُسْتَقِيمٌ ﴿٤١﴾ إِنَّ عِبَادِي لَيْسَ لَكَ عَلَيْهِمْ سُلْطَٰنٌ إِلَّا مَنِ ٱتَّبَعَكَ مِنَ ٱلْغَاوِينَ ﴿٤٢﴾ وَإِنَّ جَهَنَّمَ لَمَوْعِدُهُمْ أَجْمَعِينَ ﴿٤٣﴾

*36. វា (គឺអ៊ិបលិស) បានទូលថា៖ "ព្រះម្ចាស់អើយ សូមព្រះអង្គពន្យារពេលឲ្យទូលព្រះបង្គំជាខ្ញុំដរាបដល់ថ្ងៃដែលពួកគេ (មនុស្ស) នឹងរស់ឡើងវិញ ។" 37. ព្រះអង្គមានព្រះតម្រាស់ថា៖ "អ្នកជាម្នាក់ក្នុងចំណោមអ្នកទាំងឡាយដែលគេពន្យារពេលឲ្យ 38. រហូតដល់ថ្ងៃដែលបានកំណត់ពេលស្រេចហើយ[ដោយអល់ឡោះហ្ស៍] ។" 39. វា (គឺអ៊ិបលិស) បានទូលថា៖ "ព្រះម្ចាស់អើយ ព្រោះតែព្រះអង្គបានធ្វើឲ្យទូលព្រះបង្គំជាខ្ញុំវង្វេង ទូលព្រះបង្គំជាខ្ញុំនឹងក្លែង[អំពើអាក្រក់បំផុតរបស់ពួកគេ]ឲ្យឃើញថាជាល្អសម្រាប់ពួកគេនៅលើផែនដី ហើយទូលព្រះបង្គំជាខ្ញុំនឹងធ្វើឲ្យពួកគេទាំងអស់ប្រព្រឹត្តខុស ។ 40. លើកលែងតែបណ្តាបាវបម្រើរបស់ព្រះអង្គដែលស្មោះ*

*ត្រង់[និងមានភក្តីភាព]ប៉ុណ្ណោះ ក្នុងចំណោមពួកគេ ។" 41. ព្រះអង្គមានព្រះតម្រាស់ថា៖ "នេះគឺមាគ៌ាទៀងត្រង់របស់អញ 42. អ្នកពុំមានអំណាចលើបាវបម្រើទាំងឡាយរបស់អញទាល់តែសោះ លើកលែងតែលើបណ្តាអ្នកណាក្នុងចំណោមជនប្រព្រឹត្តខុសដែលតាមអ្នកប៉ុណ្ណោះ 43. ឋាននរកជាកន្លែងដែលគេបានសន្យាឲ្យពួកគេទាំងអស់គ្នា ។*

ដូច្នេះ ស្ហៃតនចាំឆ្មក់យើង វាខ្សឹបដាក់ត្រចៀកយើង វាលើកស្ទួយយើង វាបញ្ជោកបញ្ជោរនិងលើកតម្កើងយើង ។ បើយើងមិនប្រយ័តខ្លួនទេ នៀតយើងនឹងខូច យើងនឹងបាត់បង់សេចក្តីស្មោះ ។

ពេលយើងស៊ូឡាត់ យើងត្រូវស្មោះអស់ពីចិត្ត ។ យើងមិនត្រូវបង្ខំស៊ូឡាត់ពេលព្រឹកឲ្យឆាប់ចប់ទេដើម្បីឆាប់បានចូលដេកវិញ ។ យើងត្រូវគិតមួយភ្លែតថាយើងកំពុងអរព្រះគុណព្រះដែលបានឲ្យជីវិតយើង ។ ចូរដាក់ដៃលើទ្រូងខ្លួនឯង ចូរស្តាប់សង្វាក់បេះដូងអ្នក (គឺស្តាប់បេះដូងលោត) និងចូរនឹករលឹកដល់កម្លាំងពលំដែលធ្វើឲ្យវាអាចដំណើរការបាន ។ កម្លាំងពលំនេះឯងដែលយើងធ្វើសក្ការៈ ។

បន្ទាប់មក សម្លេងនេះខ្សឹបដាក់អ្នកថាគ្រែដេកអ្នកកក់ក្តៅគួរឲ្យដេកណាស់ អ្នកងុយដេកណាស់...

ពេលយើងនៅពីមុខគេ នៀតយើងត្រូវសម្លេងនេះដែរជិះជាន់ ។ ជួសប្រាប់យើងឲ្យស៊ូឡាត់លឿនៗ វាប្រាប់យើងឲ្យស៊ូឡាត់បន្ថយល្បឿន ដើម្បីនឹងឲ្យអ្នកដទៃមើលមកយើងថាយើងកាន់ធម៌ខ្ជាប់ខ្ជួនណាស់ ។

អល់ឡោះហ៊្វប្រាប់យើងនៅក្នុងហាឌីស្ស គូដុស៊ី (الحديث القدسي) ថា៖ *"អញជាកំណាប់កប់លាក់ទុក អញចង់ឲ្យគេរកឃើញអញ ដូច្នេះហើយបានជាអញបង្កើត (كنت كنزاً مخفياً فأحببت أن أعرف فخلقتُ الخلق لكى أعرف) ។"*

កំណាប់ជាផលប្រយោជន៍នីមួយដែលយើងទទួលបាន ទោះជាចំណេះវិជ្ជាក្តី ទ្រព្យសម្បត្តិក្តី ។ល ។

អល់ឡោះហ៊្វជាកំណាប់លាក់ទុក តែព្រះអង្គបានទុកឲ្យយើងនូវសញ្ញាច្រើនដើម្បីនឹងឲ្យយើងអាចរកព្រះអង្គឃើញ ។ ព្រះគម្ពីរគួរអានពោរពេញដោយការណែនាំសម្រាប់យល់សញ្ញារបស់អល់ឡោះហ៊្វ និងសម្រាប់រកសញ្ញាទាំងនោះឃើញ ។ គន្លឹះសម្រាប់រកផ្លូវឃើញគឺរក្សានៀតស្មោះរបស់យើងឲ្យខ្ជាប់ខ្ជួន ទង្វើ

ទាំងអស់របស់អ្នកត្រូវធ្វើដោយសេចក្ដីស្មោះត្រង់ និងដើម្បីផ្គាប់ចិត្តអល់ឡោះហ្ ﷻ ។

បើយើងគិតដល់អល់ឡោះហ្ ﷻ អល់ឡោះហ្ ﷻ ក៏គិតដល់យើងវិញដែរ ព្រោះព្រះអង្គ ﷻ មានព្រះបន្ទូលនៅក្នុងព្រះគម្ពីរគួរអានស៊ូរ៉ោះតុ៍ 2 អាយ៉ាស្ទ 152 ថា៖

فَٱذۡكُرُونِيٓ أَذۡكُرۡكُمۡ ... ﴿١٥٢﴾

*152. ដូច្នេះចូរពួកអ្នករលឹកដល់អញ អញនឹងរលឹកដល់ពួកអ្នក...*

បើគ្រប់ទង្វើយើងត្រូវធ្វើដោយស្មោះអស់ពីចិត្ត យើងនឹងទទួលបាននូវកម្លាំងប៉ែកខាងក្នុងមកពីអល់ឡោះហ្ ﷻ គឺរបៀបមើលឃើញនូវអ្វីៗដែលមិនអាចមើលឃើញបានដោយភ្នែកលោកិយ ។ ជីវិតយើងនឹងមានន័យ យើងនឹងមានគោលដៅក្នុងជីវិត យើងនឹងពេញចិត្តនិងស្កប់ស្កល់ រស់នៅដោយសុខដុមរមណី ជាមួយអ្វីៗជុំវិញខ្លួនយើង ។

ពេលយើងឈ្នះសម្លេងខ្សឹបខ្សៀវនេះ ត្រចៀកយើងនឹងទទួលតែការណែនាំល្អ ។ ត្រូវខិតខំបន្តិច តែរង្វាន់ដែលនឹងបានមកនោះធំធេងលើសពីការស្មាន ។

## មេរៀនទី ១១

# រស់នៅដោយមានសីលធម៌

ដំបូងយើងកំណត់អត្ថន័យសីលធម៌ថា "ពាក់ព័ន្ធនឹងសុភនិច្ឆ័យដឹងខុសត្រូវ" ។

អ៊ីស្លាមជាសាសនាដែលអល់ឡោះហ៊ូ ﷻ ព្រះរាជទាន ឲ្យមកមនុស្សជាព្រះរាជអំណោយដើម្បីនឹងឲ្យមនុស្សអាចរស់នៅជាមួយគ្នាបាន ដោយសុខដុមរមណីយ និងចុះសម្រុងគ្នា ។ អាចធ្វើដូច្នេះបានទាល់តែមនុស្សក្នុងសហគមន៍មានសីលធម៌បរិសុទ្ធ ។

ដូច្នេះ ដើម្បីរស់នៅដោយសុខដុម អ៊ីស្លាមបានបង្កើតនូវក្បួនខ្នាតសង្គម (សីលធម៌) ដើម្បីនឹងឲ្យរាល់ៗគ្នានិងសហគមន៍ទាំងមូលអាចកសាងបាននូវជីវិតដែលប្រកបដោយសីលធម៌ ។

តើយើងរស់នៅដោយមានសីលធម៌ដូចម្ដេច ?

យើងម្នាក់ៗមានការទទួលខុសត្រូវចំពោះអ្នកដទៃ ក្នុងការរក្សាយុត្តិធម៌ ក្នុងការគោរពសិទ្ធិអ្នកដទៃ ។

នៅក្នុងព្រះគម្ពីរគួរអាន (ស៊ូរ៉ោះត៍ 49 អាយ៉ាស់ 11-12) អល់ឡោះហ៊ូ ﷻ រៀបរាប់ប្រាប់យើងនូវរបៀបប្រព្រឹត្តខ្លួន គឺ៖

يَـٰٓأَيُّهَا ٱلَّذِينَ ءَامَنُواْ لَا يَسْخَرْ قَوْمٌ مِّن قَوْمٍ عَسَىٰٓ أَن يَكُونُواْ خَيْرًا مِّنْهُمْ وَلَا نِسَآءٌ مِّن نِّسَآءٍ عَسَىٰٓ أَن يَكُنَّ خَيْرًا مِّنْهُنَّ ۖ وَلَا تَلْمِزُوٓاْ أَنفُسَكُمْ وَلَا تَنَابَزُواْ بِٱلْأَلْقَـٰبِ ۖ بِئْسَ ٱلِٱسْمُ ٱلْفُسُوقُ بَعْدَ ٱلْإِيمَـٰنِ ۚ وَمَن لَّمْ يَتُبْ فَأُوْلَـٰٓئِكَ هُمُ ٱلظَّـٰلِمُونَ ﴿١١﴾ يَـٰٓأَيُّهَا ٱلَّذِينَ ءَامَنُواْ ٱجْتَنِبُواْ كَثِيرًا مِّنَ ٱلظَّنِّ إِنَّ بَعْضَ ٱلظَّنِّ إِثْمٌ ۖ وَلَا تَجَسَّسُواْ وَلَا يَغْتَب بَّعْضُكُم بَعْضًا ۚ أَيُحِبُّ أَحَدُكُمْ أَن يَأْكُلَ لَحْمَ أَخِيهِ مَيْتًا فَكَرِهْتُمُوهُ ۚ وَٱتَّقُواْ ٱللَّهَ ۚ إِنَّ ٱللَّهَ تَوَّابٌ رَّحِيمٌ ﴿١٢﴾

*១១. បណ្ដាអ្នកមានសទ្ធាអើយ ចូរកុំឲ្យមនុស្សក្រុមណាមួយចំអកឲ្យមនុស្សមួយក្រុមទៀត ។ ជួនកាលពួកគេអាចប្រសើរជាងពួកគេទាំងនោះ ។ ចូរកុំឲ្យបណ្ដាស្ត្រីចំអកឲ្យបណ្ដាស្ត្រីឯទៀត ។ ជួនកាលពួកនាងប្រសើរជាងពួកនាងទាំងនោះ ។ ចូរពួកអ្នកកុំចាប់កំហុសគ្នាឯង ។ ចូរពួកអ្នកកុំហៅឈ្មោះគ្នាតាមឈ្មោះក្រៅ ។ អប្រិយ*

*គឺឈ្មោះអាក្រក់ បន្ទាប់ពីមានសទ្ធាហើយនោះ ។ អ្នកណាមិនស្មារលោកំហុសទេ (គឺមិនកែខ្លួនពេលដឹងកំហុស) អ្នកនោះជាជនទុច្ចរិត ។ 12. បណ្ដាអ្នកមានសទ្ធាអើយ ចូរពួកអ្នកចៀសវាងប៉ាន់ស្មាន ព្រោះការពិត ក្នុងករណីខ្លះ ប៉ាន់ស្មានជាបាប ។ ចូរពួកអ្នកកុំលបយកការណ៍ ។ ចូរពួកអ្នកកុំនិយាយបង្កាច់អ្នកឯទៀត ។ តើមានអ្នកណាម្នាក់ក្នុងចំណោមពួកអ្នកចូលចិត្តស៊ីសាច់បងប្អូនឯងដែលស្លាប់នោះទេ ? ពួកអ្នកពិតជាស្អប់ខ្ពើមអំពើនេះខ្លាំងណាស់ ។ ចូរពួកអ្នកខ្លាចអល់ឡោះហ្ ។ ពិតមែនអល់ឡោះហ្ទ្រង់រមែងតែបែរត្រឡប់ (ប្រោសប្រណី គឺទទួលការសូមខមាទោស) ព្រះអង្គមានព្រះធម៌មេត្តា ។*

មានច្រើនរបៀបសម្រាប់ប្រព្រឹត្តខ្លួននៅក្នុងសហាគមន៍ ខ្លឹមសាររបស់ចរិយាមារយាទនៅលើការចេះគិតដល់គេ ។ បើអ្នកណាចេះគិតដល់សុខទុក្ខអ្នកដទៃ អ្នកនោះនឹងមិនធ្វើឲ្យគេកាន់តែពិបាកកើនឡើងឡើយ ។

ព្រះបរមសាស្ដាមូហាំម៉ាដ់ﷺមានព្រះវចនៈថា៖ *"ចូរលោកចង់ឲ្យអ្នកដទៃបាន ឲ្យដូចខ្លួនលោកចង់បានដែរ ។"*

នៅក្នុងស៊ូរ៉ោះត៍ខ្លីបំផុត អាល់-អ៊ាស្វ៍រ អាយ៉ាស់ 2 (103:2-3) អល់ឡោះហ្ﷻ ប្រាប់របៀបប្រព្រឹត្តខ្លួនរបស់មនុស្សជាតិទាំងអស់ថា៖

إِنَّ ٱلۡإِنسَٰنَ لَفِي خُسۡرٍ ٢

*2. ពិតណាស់ មនុស្សនៅក្នុងសេចក្ដីវិនាស ។*

អាយ៉ាស់នេះផ្ដោតទៅលើថ្ងៃជំនុំជម្រះ ពេលអល់ឡោះហ្ﷻនឹងឲ្យមនុស្សងើបឡើងពីក្នុងផ្នូរដើម្បីសាកសួរដល់ជីវិតមនុស្សនោះ មនុស្សខ្លះនឹងថាខ្លួនពុំបានធ្វើប្រការល្អសោះ មនុស្សទាំងនេះនឹងវិនាស ។ មនុស្សខ្លះទៀតនឹងឆ្លើយថាខ្លួនជាមនុស្សល្អ បានធ្វើសក្ការៈទៀងទាត់ មនុស្សទាំងនេះក៏នឹងវិនាសដែរ ។

إِلَّا ٱلَّذِينَ ءَامَنُواْ وَعَمِلُواْ ٱلصَّٰلِحَٰتِ وَتَوَاصَوۡاْ بِٱلۡحَقِّ وَتَوَاصَوۡاْ بِٱلصَّبۡرِ ٣

*3. លើកលែងតែបណ្ដាអ្នកដែលមានសទ្ធា សាងអំពើល្អ ដាស់តឿន[គ្នាទៅវិញទៅមក]ឲ្យទៅកាន់សេចក្ដីពិត ដាស់តឿន[គ្នាទៅវិញទៅមក]ឲ្យអត់ធ្មត់[នៅលើមាគ៌ា*

*អល់ឡោះហ្ទ៍]* ។

សឲ្យឃើញថាជាមនុស្សល្អមិនគ្រប់គ្រាន់ទេ ។ អ្នកត្រូវប្រើជីវិតរស់នៅបែបនេះដោយបម្រើនិងអប់រំសហគមន៍ដែរ ដោយណែនាំគេទៅរកសេចក្ដីពិតនិងដោយបង្គាប់គេឲ្យធ្វើល្អ ។ គេហៅប្រការនេះថា អាំរ៉ូ ប៊ិល ម៉ាក់រុហ្វ (اَلْأَمْرَ بِالْمَعْرُوفِ បង្គាប់ឲ្យធ្វើល្អ) វ៉ា អាន់-ណាស្ហ៊ុយ៉ា អ៊ុននីល-មុនការ (وَ النَّهْيَ عَنِ الْمُنْكَرِ និងហាមធ្វើអាក្រក់) ។

ក្បួនខ្នាតសីលធម៌ដែលអល់ឡោះហ្ទ៍ ﷻ ព្រះរាជទានឲ្យមនុស្សជាតិនោះ ត្រូវបង្ហាញឲ្យឃើញនៅក្នុងចរិមារយាទ (ស៊ុនណាស្ហ៍) របស់ព្រះបរមសាស្ដាមូហ៊ាំម៉ាដ៍ និងព្រះសន្ដអ៊ីម៉ាំ عليهم السلام ។

គ្រាមួយ គេបានសួរព្រះសន្ដអ៊ីម៉ាំអាលី صلوات الله عليه والسلام ថាសីលធម៌របស់បុគ្គលបិតនៅលើប្រការអ្វី ។ ព្រះអង្គ صلوات الله عليه والسلام បានតបថា៖ *"ថ្វីដ្បិតមានអំណាច បុគ្គលនោះងាយអត់ឱនឲ្យគេ ។ បុគ្គលនោះមានចិត្តទូលំទូលាយដោយសមហេតុផល ។ បុគ្គលនោះមានឥរិយាបថស្លូតបូត ។ ទង្វើនិងដំណើររបស់បុគ្គលនោះសឲ្យឃើញនូវសេចក្ដីសុភាពរម្យទម ។ មនុស្សស្រឡាញ់មិត្តភាពនិងសេចក្ដីស្ងប់ស្ងាត់របស់បុគ្គលនោះ ។ បុគ្គលនោះត្រៀមខ្លួនអត់ទ្រាំការលំបាកជាស្រេចដើម្បីជួយសម្រាលទុក្ខអ្នកដទៃ ។ បុគ្គលនោះជាមិត្តស្មោះត្រង់ ។ បុគ្គលនោះគោរពពាក្យសន្យា ។ បុគ្គលនោះជួយជនរងការសង្កត់សង្កិននិងបារម្ភជនគ្មានពំនាក់អាស្រ័យ ។ បុគ្គលនោះមិនបោះបង់ជនមានអាសន្នទេ បុគ្គលនោះព្យាយាមជួយសម្រាលទុក្ខជនទាំងនោះ ។ បុគ្គលនោះគោរពសិទ្ធិអ្នកអវត្តិមាន ។ បុគ្គលនោះព្រមទទួលការសូមខមាទោសរបស់ជនមានកំហុស ។ បុគ្គលនោះជួយឧបត្ថម្ភបណ្ដាអ្នកដែលបានជួយឧបត្ថម្ភខ្លួន ។ បុគ្គលនោះមិនបរិហារអាថិកំបាំងរបស់អ្នកដទៃទេ ។ បុគ្គលនោះមិនជ្រៀតជ្រែកក្នុងរឿងសម្ងាត់ដែលមិនទាក់ទងនឹងខ្លួនទេ ។ បុគ្គលនោះជាគំរូល្អសម្រាប់បណ្ដាអ្នកដែលនឹងតាមខ្លួន ។ បុគ្គលនោះធ្វើល្អមិនមែនដើម្បីអួតគេទេ ។ បុគ្គលនោះមិនពើបពះបញ្ហាតែមួយពីរដងទេ ។"*

នៅក្នុងខ្ទុអ្៊ាអ៊ុំសូមឲ្យមានសីលធម៌ ព្រះសន្ដអ៊ីម៉ាំស្ហ៊ែនុល-អាប៊ីឌីន صلوات الله عليه والسلام បាន

សរសេរដៃរបៀ៖

1. اللَّهُمَّ صَلِّ عَلَى مُحَمَّدٍ وَ آلِهِ ، وَ بَلِّغْ بِإِيمَانِي أَكْمَلَ الْإِيمَانِ ، وَ اجْعَلْ يَقِينِي أَفْضَلَ الْيَقِينِ ، وَ انْتَهِ بِنِيَّتِي إِلَى أَحْسَنِ النِّيَّاتِ ، وَ بِعَمَلِي إِلَى أَحْسَنِ الْأَعْمَالِ .

*1. សូមអល់ឡោះហ៊្ជ﷿ព្រះរាជទានពរជ័យសិរីសួស្តីឲ្យមូហាំម៉ាដ់صلى الله عليه وآله وسلم និងព្រះរាជវង្សព្រះអង្គعليهم السلام ។ សូមព្រះអង្គ﷿ឲ្យជំនឿទូលព្រះបង្គំជាខ្ញុំបានទៅដល់កម្រិតជំនឿបរិសុទ្ធ សូមព្រះអង្គ﷿ឲ្យការជឿជាក់របស់ទូលព្រះបង្គំជាខ្ញុំបានទៅជាការជឿជាក់ដែលប្រសើរបំផុត សូមព្រះអង្គ﷿ឲ្យការយកចិត្តទុកដាក់របស់ទូលព្រះបង្គំជាខ្ញុំបានទៅជាការយកចិត្តទុកដាក់ដែលប្រសើរបំផុត ឲ្យទង្វើរបស់ទូលព្រះបង្គំជាខ្ញុំបានទៅជាទង្វើដែលប្រសើរបំផុត ។*

2. اللَّهُمَّ وَفِّرْ بِلُطْفِكَ نِيَّتِي ، وَ صَحِّحْ بِمَا عِنْدَكَ يَقِينِي ، وَ اسْتَصْلِحْ بِقُدْرَتِكَ مَا فَسَدَ مِنِّي.

*2. អល់ឡោះហ៊្ជ﷿អើយ សូមព្រះអង្គ﷿ធ្វើឲ្យការយកចិត្តទុកដាក់របស់ទូលព្រះបង្គំជាខ្ញុំមានសុក្រឹតភាពដោយការអាណិតមេត្តារបស់អង្គ﷿ សូមព្រះអង្គ﷿កែតម្រង់ការជឿជាក់របស់ទូលព្រះបង្គំជាខ្ញុំដោយអ្វីដែលព្រះអង្គ﷿មាន សូមព្រះអង្គ﷿កែតម្រូវអ្វីដែលខុសនៅក្នុងខ្លួនទូលព្រះបង្គំជាខ្ញុំដោយព្រះឥទ្ធិឫទ្ធិព្រះអង្គ﷿ ។*

3. اللَّهُمَّ صَلِّ عَلَى مُحَمَّدٍ وَ آلِهِ ، وَ اكْفِنِي مَا يَشْغَلُنِي الِاهْتِمَامُ بِهِ ، وَ اسْتَعْمِلْنِي بِمَا تَسْأَلُنِي غَداً عَنْهُ ، وَ اسْتَفْرِغْ أَيَّامِي فِيمَا خَلَقْتَنِي لَهُ ، وَ أَغْنِنِي وَ أَوْسِعْ عَلَيَّ فِي رِزْقِكَ ، وَ لَا تَفْتِنِّي بِالنَّظَرِ ، وَ أَعِزَّنِي وَ لَا تَبْتَلِيَنِّي بِالْكِبْرِ ، وَ عَبِّدْنِي لَكَ وَ لَا تُفْسِدْ عِبَادَتِي بِالْعُجْبِ ، وَ أَجْرِ لِلنَّاسِ عَلَى يَدِيَ الْخَيْرَ وَ لَا تَمْحَقْهُ بِالْمَنِّ ، وَ هَبْ لِي مَعَالِيَ الْأَخْلَاقِ ، وَ اعْصِمْنِي مِنَ الْفَخْرِ .

*3. សូមអល់ឡោះហ៊្ជ﷿ព្រះរាជទានពរជ័យសិរីសួស្តីឲ្យមូហាំម៉ាដ់صلى الله عليه وآله وسلم និងព្រះរាជវង្សព្រះអង្គعليهم السلام ។ សូមព្រះអង្គ﷿កុំឲ្យកង្វល់បន្ទប់រឹករវទូលព្រះបង្គំជាខ្ញុំឡើយ សូមព្រះអង្គ﷿ប្រើទូលព្រះបង្គំជាខ្ញុំឲ្យធ្វើអ្វី ដែលព្រះអង្គ﷿នឹងសាកសួរទូលព្រះបង្គំជាខ្ញុំនាថ្ងៃស្អែក សូមព្រះអង្គ﷿ឲ្យទូលព្រះបង្គំជាខ្ញុំលះបង់ជីវិតសម្រាប់តែអ្វីដែលព្រះអង្គ﷿បានបង្កើតទូលព្រះបង្គំជាខ្ញុំមកសម្រាប់តែអ្វីនោះ សូមព្រះអង្គ﷿ឲ្យទូលព្រះបង្គំជាខ្ញុំចាកផុតពីសេចក្តីត្រូវការ សូមព្រះអង្គ﷿លាតសន្ធឹងធនធានព្រះអង្គ﷿មកលើទូលព្រះបង្គំជាខ្ញុំ សូមព្រះអង្គ﷿កុំលទូលព្រះបង្គំជាខ្ញុំដោយអកតញ្ញូតាឡើយ ។*

*សូមព្រះអង្គ عزّ وجلّ លើកស្ទួយទូលព្រះបង្គំជាខ្ញុំ សូមព្រះអង្គ عزّ وجلّ កុំលទូលព្រះបង្គំជាខ្ញុំដោយ អាការក្រអឺតក្រទមឡើយ សូមព្រះអង្គ عزّ وجلّ ឲ្យទូលព្រះបង្គំជាខ្ញុំនៅក្នុងចំណុះព្រះអង្គ عزّ وجلّ សូមព្រះអង្គ عزّ وجلّ កុំបណ្ដោយឲ្យការពេញចិត្តនឹងខ្លួនឯងនោះធ្វើឲ្យខូចការធ្វើ សក្ការៈព្រះអង្គ عزّ وجلّ ឡើយ សូមព្រះអង្គ عزّ وجلّ ឲ្យសេចក្ដីល្អហូរចេញពីដៃទូលព្រះបង្គំជាខ្ញុំ ទៅលើបណ្ដាមនុស្ស សូមព្រះអង្គ عزّ وجلّ កុំលប់វាចោលដោយសារទូលព្រះបង្គំជាខ្ញុំទារ សគុណពីពួកគេឡើយ សូមព្រះអង្គ عزّ وجلّ ព្រះរាជទានសីលធម៌ឧត្តុង្គឧត្តមឲ្យទូលព្រះ បង្គំជាខ្ញុំ សូមព្រះអង្គ عزّ وجلّ ឲ្យទូលព្រះបង្គំជាខ្ញុំចាកផុតពីអំនួតខ្លួនឯង ។*

9. اللَّهُمَّ صَلِّ عَلَى مُحَمَّدٍ وَ آلِهِ ، وَ سَدِّدْنِي لِأَنْ أُعَارِضَ مَنْ غَشَّنِي بِالنُّصْحِ ، وَ أَجْزِيَ مَنْ هَجَرَنِي بِالْبِرِّ ، وَ أُثِيبَ مَنْ حَرَمَنِي بِالْبَذْلِ ، وَ أُكَافِيَ مَنْ قَطَعَنِي بِالصِّلَةِ ، وَ أُخَالِفَ مَنِ اغْتَابَنِي إِلَى حُسْنِ الذِّكْرِ ، وَ أَنْ أَشْكُرَ الْحَسَنَةَ ، وَ أُغْضِيَ عَنِ السَّيِّئَةِ .

*9. សូមអល់ឡោះហ៍ عزّ وجلّ ព្រះរាជទានពរជ័យសិរីសួស្ដីឲ្យមូហាំម៉ាដ់ صلى الله عليه وآله وسلم និងព្រះរាជវង្សព្រះអង្គ عليهم السلام ។ សូមព្រះអង្គ عزّ وجلّ ឲ្យទូលព្រះបង្គំជាខ្ញុំជោគជ័យក្នុងការណែនាំបុគ្គលដែលមិនស្មោះត្រង់ចំពោះទូលព្រះបង្គំជាខ្ញុំ ក្នុងការតបស្នងដោយអំពើល្អបុគ្គលដែលបានបោះបង់ចោលទូលព្រះបង្គំជាខ្ញុំ ក្នុងការឲ្យរង្វាន់ដោយចិត្តទូលាយបុគ្គលដែលបានបំបាត់ទូលព្រះបង្គំជាខ្ញុំ ក្នុងការសងបុគ្គលដែលបានផ្ដាច់ទំនាក់ទំនងពីទូលព្រះបង្គំជាខ្ញុំដោយសាងសម្ពន្ធជាមួយបុគ្គលនោះ ក្នុងការប្រឆាំងតទល់បុគ្គលដែលបានបង្ខូចកេរ្តិ៍ឈ្មោះទូលព្រះបង្គំជាខ្ញុំ ដោយការនិយាយល្អអំពីបុគ្គលនោះ ក្នុងការដឹងគុណអំពីទង្វើល្អផ្សេងៗ[ដែលទូលព្រះបង្គំជាខ្ញុំទទួលបាន] ក្នុងការបិទភ្នែកមិនអើពើទង្វើអាក្រក់[ដែលគេប្រព្រឹត្តមកលើទូលព្រះបង្គំជាខ្ញុំ] ។*

ចូរយើងសាកល្បងប្ដូរសម្ដីទាំងនេះជាទង្វើ ។

## មេរៀនទី ១២

# ការអត់ធ្មត់

ការអត់ធ្មត់មានន័យថាស៊ូទ្រាំនិងអធ្យាស្រ័យ ។ ពាក្យអារ៉ាប់ហៅអត់ធ្មត់ថា ហ៊ីលម៍ (حِلْم) ។

ក្នុងជីវិតតែងតែមានពេលលំបាក នឹងមានបញ្ហាកើតឡើង ។ ពេលបញ្ហាកើតមានឡើង គេអាចធ្វើប្រការពីរគឺ៖

១) គេអាចខិតខំអស់ពីសមត្ថភាពដើម្បីពុះពារឧបសគ្គលុះបានសម្រេច ឬ

២) គេអាចអង្គុយយំមួយកន្លែង រង់ចាំឲ្យបញ្ហាបាត់ដោយខ្លួនឯង (បើវាអាចរលាយបាត់ដោយខ្លួនឯងបាន) ។

ពេលបុគ្គលព្យាយាមដោះស្រាយបញ្ហា បុគ្គលនោះបានធ្វើទង្វើវិជ្ជមាន (គឺបានធ្វើប្រការប្រសើរ) បុគ្គលនោះមានសង្ឃឹមអាចបានសម្រេច ។ តែបើបុគ្គលនោះមានស្មារតីអវិជ្ជមាន (គឺអស់សង្ឃឹម ឃើញតែអាក្រក់) បញ្ហាឬឧសគ្គនឹងនៅដដែលបុគ្គលនោះនៅតែត្អូញត្អែរអាណិតខ្លួន ។

អល់ឡោះហ៍ﷻជួយអ្នកណាដែលជួយខ្លួនឯង ។ ដូច្នេះ បើអ្នកណាត្អូញដាក់អល់ឡោះហ៍ﷻថា៖ "ហេតុអ្វីខ្ញុំធ្លាក់ខ្លួនបែបនេះ ?" អ្នកនោះមានជំនឿតិច ។ ពេលគ្រោះកាចបាក់ស្រោចមកលើយើង បានសេចក្តីថាអល់ឡោះហ៍ﷻពិសោធយើង ។ នៅក្នុងព្រះគម្ពីរគួរអាន អល់ឡោះហ៍ﷻសួរយើងថាតើយើងគិតថាភាពជាមុស្លីមគ្រប់គ្រាន់ណាស់ហើយ ដោយមិនបាច់ឆ្លងកាត់ការពិសោធន៍ទេ ?

ដូចនៅក្នុងការប្រកួតដែរ ។ ពេលបុគ្គលនីមួយថាខ្លួនអាចបំបែកឯកទត្តកម្មពិភពលោក អ្នកគិតថាគេនឹងថា៖ "O.K. នេះគឺមេដាយមាស ។ សូមអរគុណ ។" ពិតប្រាកដជាមិនដូច្នេះទេ គេនឹងសាកល្បងបុគ្គលនោះដើម្បីនឹងដឹងថាបុគ្គលនោះអាចធ្វើបានដូចថាឬទេ ។

ព្រះបរមសាស្តាមូហាំម៉ាដ់ﷺមានព្រះវចនៈថា៖ *"ចូរកុំឲ្យការត្អូញត្អែររបស់អស់លោកធ្វើឲ្យរង្វាន់អស់លោកមោឃៈឡើយ ។ ប្រសិនបើអស់លោកអាចមើលឃើញរង្វាន់ដែលគេទុកសម្រាប់គ្រោះរបស់អស់លោក អស់លោកនឹងឃើញថាគ្រោះនោះតូចតាចណាស់ប្រៀបនឹងរង្វាន់ដ៏ធំធេង ដែលអល់ឡោះហ្ជ៏សន្យាឲ្យអ្នកណាដែលចុះចូល[ក្នុងព្រះឆន្ទៈអល់ឡោះហ្ជ៏] ដែលអត់ទ្រាំ[គ្រោះ]ដោយអំណត់ ។"*

ដូច្នេះ អត់ធ្មត់ក្រោយពីខិតខំព្យាយាមដោះស្រាយបញ្ហាអស់ពីសមត្ថភាព ជាទង្វើប្រកបដោយជំនឿ ព្រោះអល់ឡោះហ្ជ៏បានសន្យាថាព្រះអង្គជ៏នឹងពិសោធយើង នោះគឺបញ្ហាដែលយើងត្រូវតែពុះពារលុះបានសម្រេច ។

បើយើងអត់ធ្មត់ការលំបាកដោយអំណត់ យើងនឹងឈ្នះការពិសោធន៍ យើងនឹងទទួលបាននូវសេចក្តីស្រណុក ព្រោះអល់ឡោះហ្ជ៏មានព្រះបន្ទូលនៅក្នុងព្រះគម្ពីរគួរអាន ស៊ូរ៉ោះត៍ 94 អាយ៉ាស់ 6 ថា៖

إِنَّ مَعَ ٱلْعُسْرِ يُسْرًا ۝٦

*6. មែន សេចក្តីលំបាកនៅជាមួយសេចក្តីស្រណុក ។*

ដូច្នេះ បើយើងអត់ធ្មត់ បញ្ហានឹងមានដំណោះស្រាយអាស្រ័យព្រះធម៌មេត្តារបស់អល់ឡោះហ្ជ៏ ។

ត្រូវចេះអត់ធ្មត់មិនត្រឹមតែក្នុងពេលមានគ្រោះនោះទេ តែត្រូវចេះអត់ធ្មត់ពេលអ្នករងអំពើអយុត្តិធម៌ដែរ ។ ក្រៅពីការសងសឹកបុគ្គលដែលធ្វើខុសមកលើយើង ទង្វើដែលធ្វើឲ្យយើងស្កប់ស្កល់ចិត្តនោះមានតិចណាស់ ។ ពិបាកអត់ឱនឲ្យបុគ្គលប្រភេទនេះណាស់ ជាពិសេសពេលអ្នកនៅក្នុងស្ថានភាពវាយតបវិញ ។ អត់ធ្មត់នៅក្នុងសភាពនេះទាមទារឲ្យមានកម្លាំងចិត្តខ្លាំងណាស់ ដូចមានចែងនៅក្នុងពាក្យពេជន៍របស់ព្រះបរមសាស្តាមូហាំម៉ាដ់ﷺថា៖ *"អ្នកខ្លាំងជាងគេក្នុងចំណោមអស់លោកគឺអ្នកដែលទប់ខ្លួនបានពេលក្រោធ ។ អ្នកមានសន្តោសជាងគេក្នុងចំណោមអស់លោកគឺអ្នកដែលអត់ឱន លើកលែង ពេលអ្នកនោះមានប្រៀបលើសត្រូវខ្លួន ។"*

# ហ្ស៊ីតណាស្ង៉ និង ហ្វាសាដ្ង៉

មានន័យថាដើរនិយាយពាក្យចចាមអារ៉ាម និងនិយាយកុហកភូតភរអំពីគេ ដោយមានបំណង (នៀត) បង្ខូចកេរ្តិ៍ឈ្មោះគេ ។

ដូចនិយាយអាក្រក់ដែរ ខុសគ្នាតែថាពាក្យចចាមអារ៉ាមជាសម្តីមិនពិត និងគ្មានអំណះអំណាង ។

មានពាក្យមួយទៀតសម្រាប់ហៅ ហ្ស៊ីតណាស្ង៉ និង ហ្វាសាដ្ង៉ គឺពាក្យថា និយាយបង្កាច់ (បង្ខូចឈ្មោះគេ) ។

ព្រះសន្តអ៊ីម៉ាំហ្សាសាន់ﷺមានវចនៈថា៖ *"ពេលអ្នកណាមួយមករកលោកនិយាយអាក្រក់អំពីគេ លោកត្រូវដឹងថាការពិតអ្នកនោះកំពុងតែនិយាយអាក្រក់អំពីលោក ។ វាជាប្រការល្អដែលចាត់ទុកអ្នកនោះជាសត្រូវរបស់លោកនិងកុំទុកចិត្តអ្នកនោះព្រោះការនិយាយកុហក ភូតភរ ការនិយាយអាក្រក់ពីគេ ការឆបោក កំហាកចិត្ត ការច្រណែន ពុតត្បុត ការបំភាន់ និងការធ្វើឲ្យមនុស្សបែកបាក់សាមគ្គីគ្នាស្មើនឹងការនិយាយបង្កាច់គេ ។"*

ព្រះសន្តអ៊ីម៉ាំអាលីﷺមានវចនៈថា៖ *"បុគ្គលអាក្រក់បំផុតក្នុងចំណោមអស់លោកគឺបុគ្គលដែលនិយាយបង្កាច់គេ ដែលធ្វើឲ្យមិត្តខ្វែងគំនិតគ្នា ។ ពួកគេនឹងចោទអ្នកស្លូតត្រង់ ។"*

និយាយបង្កាច់គេជាទង្វើអាក្រក់ណាស់ ព្រះបរមសាស្តាមូហ៊ាំម៉ាដ្ង៉ﷺមានព្រះវចនៈថា៖ *"អ្នកនិយាយបង្កាច់គេមិនបានចូលឋានសួគ៌ទេ ។"*

និយាយបង្កាច់គេជាប្រការហ្សារ៉ាំព្រោះវាសម្លុយកេរ្តិ៍ឈ្មោះគេ ។ វាជាអំពើអយុត្តិធម៌សម្រាប់បុគ្គលដែលរងការនិយាយបង្កាច់ ព្រោះអ្នកផងនឹងគិតថាបុគ្គលនោះបានធ្វើអ្វីដែលអ្នកនោះមិនបានធ្វើសោះ ។

ការនិយាយបង្កាច់គេធ្វើឲ្យសហគមន៍ប្រេះឆា បណ្តាលឲ្យទៅជាសត្រូវនឹងគ្នា

និងបង្កហិង្សា ។ វាជាបាបធំបំផុតមួយ ស្មើនឹងគ្នីបាត់ (غِيبَة) និងបទឧក្រិដ្ឋឯទៀត ដែលប្រព្រឹត្តទៅលើសង្គម ។

ពេលនេះ ដែលអ្នកបានឈានដល់ដំណាក់ការនីមួយដែលធ្វើឲ្យអ្នកជាប់ពាក់ព័ន្ធនឹងសហគមន៍កាន់តែក្រែលឡើងនោះ សំខាន់ណាស់ដែលអ្នកត្រូវដឹងអំពីវិបត្តិធំនិងគ្រោះថ្នាក់ដែលកើតមកពីការប្រព្រឹត្តហ្វឹតណាស្វ៍និងហ្វាសាដ្ជ ។ អ្នកនឹងជួបប្រទះមនុស្សដែលនឹងមិនយល់ស្របជាមួយអ្នកទេឬដែលអ្នកមិនចូលចិត្ត ។ ចូរអ្នកកុំប្រើហ្វឹតណាស្វ៍និងហ្វាសាដ្ជដើម្បីកម្ចាត់ពួកនោះ ។ ចូរប្រើមធ្យោបាយត្រឹមត្រូវ ។ បើគេធ្វើប្រការនីមួយដែលអ្នកមិនពេញចិត្ត ចូរអ្នកពើងទ្រូងដើម្បីដោះស្រាយបញ្ហា ។

ចូរកុំសាបព្រោះពាក្យចចាមអារ៉ាមដែលមិនពិតអំពីបុគ្គលនោះឡើយ ដើម្បីបង្អាប់កិត្តិយសបុគ្គលនោះ ។ គ្រួសារច្រើនបានបែកបាក់គ្នា សហគមន៍ច្រើនបានហែកហួរគ្នាដោយសារកំហុសនេះ ។ ពេលនេះអ្នកដឹងផលវិបត្តិហើយ ។

អល់ឡោះហ្ជ៍ ﷻ បានទុកទណ្ឌកម្មអាក្រក់បំផុត សម្រាប់បណ្តាអ្នកដែលធ្វើបាបអ្នកដទៃ ។ ចូរកុំប្រថុយប្រថានរងព្រះពិរោធនិងព្រះទណ្ឌកម្មអល់ឡោះហ្ជ៍ ﷻ ឡើយពាក់ព័ន្ធនឹងរឿងធំបែបនេះ ។

មានតែបុគ្គលកំសាកទេដែលនិយាយបង្កាច់គេ ។ ពេលឃើញអ្នកណាមួយដែលមានគេចូលចិត្តច្រើន បុគ្គលនោះច្រណែនអ្នកនោះ ចង់បង្ខូចកេរ្តិ៍ឈ្មោះអ្នកនោះ ។ បុគ្គលនោះមិនមានសេចក្តីក្លាប្រកួតអ្នកនោះទេ ដូច្នេះបុគ្គលនោះដើរចរច្រប់ដូចពស់អាសិរពិស សាបព្រោះនិងខ្សឹបខ្សៀវពាក្យចចាមអារ៉ាមនៅក្នុងកន្លែងងងឹត ។

**មេរៀនទី ១៣**

# គោរពបរិស្ថាន

អល់ឡោះហ្ជ៏បានបង្កើតយើង ឲ្យយើងទៅជាអ្នកទទួលផែនដីជាកេរដំណែល ។ ព្រះអង្គបានឲ្យពិភពលោកមកយើងនិងសព្វសត្វដែលមាននៅក្នុងលោកនេះ ដើម្បីជាជីវព្រឹត្តសម្រាប់យើងនិងឲ្យយើងចម្រុងចម្រើនដោយសារសព្វសត្វទាំងនេះ ។ ព្រះអង្គមានព្រះរាជបន្ទូលនៅក្នុងព្រះគម្ពីរគួរអានស៊ូរ៉ោះត៊ 6 អាយ៉ាស់ 165 ថា៖

وَهُوَ ٱلَّذِى جَعَلَكُمْ خَلَـٰٓئِفَ ٱلْأَرْضِ... ﴿١٦٥﴾

*165. ព្រះអង្គជាអ្នកធ្វើឲ្យពួកអ្នក [ដែលជាបណ្តាអ្នកមានសទ្ធាជ្រះថ្លានិងប្រកបដោយសច្ចធម៌] ជាអ្នកស្នងនៅលើផែនដី ។*

អាយ៉ាស់នេះសឲ្យឃើញថាយើងត្រូវមើលថែរក្សាពិភពលោកយើង ត្រូវខំរកមធ្យោបាយកែកុនការខូចខាតនិងការរត់រាយ ដែលយើងបានបង្កនៅលើពិភពលោកយើងនេះ ។

ពេលគេឲ្យអ្វីមួយទៅអ្នក សំខាន់គឺអ្នកត្រូវប្រើប្រាស់វាឲ្យល្អ ។ ទាល់តែធ្វើដូច្នេះទើបវាគង់បានយូរ ។ បើអ្នកប្រើអ្វីមួយដោយប្រមាទ វានឹងមិនគង់បានយូរទេ ទីបំផុតវានឹងខូច អ្នកនឹងគ្រវាត់វាចោល ។

យើងប្រើប្រាស់ពិភពលោកយើងដោយប្រមាទ ។ យើងមិនអាចគ្រវាត់វាចោលបានទេ ។ យើងមានតែពិភពលោកមួយគត់ ពិភពលោកយើងនេះ ទាល់តែយើងថែរក្សាវា សម្អាតវា ទើបវាគង់វង្សបានយូរ ។ ដូចយើងទទួលផែនដីជាកេរមរតកពីបុព្វការីយើងដែរ យើងត្រូវមើលថែរក្សាវាដើម្បីយើងនឹងអាចផ្ទេរវាឲ្យទៅមនុស្សជំនាន់ក្រោយក្នុងសភាពល្អប្រសើរដដែល ។

ចូរគិតដល់ផ្ទះអ្នក ។ អ្នករស់នៅក្នុងផ្ទះនោះ ដេកក្នុងផ្ទះនោះ ។ វានឹងទៅជាយ៉ាងណាបើអ្នកមិនបោសផ្ទះនោះទេ មិនសម្អាតរបស់ដែលអ្នកបានប្រើប្រាស់ទេ ដូចជាចាន សំលៀកបំពាក់ជាដើម មិនជូតធូលីនិងវត្ថុស្មោកគ្រោកឲ្យជ្រះស្អាតទេ ? បើមិនអើពើទេ មិនយូរទេអ្នកនឹងពុំអាចរស់នៅក្នុងផ្ទះអ្នកបានទេ ។ ពុំមាន

ប្រយោជន៍ទេដែលប្រមូលយកទៅលាក់ក្រោមកម្រាលនោះ វាគ្រាន់តែជាមធ្យោបាយបណ្ដោះអាសន្នប៉ុណ្ណោះ ។ អ្នកត្រូវតែយកវត្ថុស្មោកគ្រោកចេញ ។

ពិភពលោកនេះមានប្រជានិករចំនួន ៧ ៨៧៤ ៩៦៦ ០០០ នាក់ ។ បើយើងមិនកម្ចាត់កាកសំណល់របស់យើងទេ តើយើងនឹងអាចទៅរស់នៅឯណាបានពេលផែនដីទៅជាកខ្វក់ មានជាតិពុលពិបាករស់នៅ ?

តើយើងអាចធ្វើអ្វីបានខ្លះដើម្បីនឹងឲ្យផែនដីយើងស្អាត ?

យើងអាចចាប់ផ្ដើមគិត ចាប់ផ្ដើមយល់ថាកុំខ្ជះខ្ជាយ ។ បើយើងកាន់តែខ្ជះខ្ជាយ យើងកាន់តែចោលច្រើនទៅៗ ។ វានឹងទៅជាគំនរធំទៅៗ ។ យើងត្រូវព្យាយាមចៀសវាងប្រើគីមីដែលធ្វើឲ្យសមុទ្រនិងអាកាសខូច ។ យើងត្រូវចោលសម្រាមនៅកន្លែងសម្រាប់ចោលសម្រាមនោះ មិនត្រូវចោលតាមផ្លូវឬតាមបង្អួចទេ ។ ចូរគិតមើល បើរាល់គ្នាចោលសម្រាមតាមផ្លូវ អ្វីនឹងកើតឡើង ។ កាកសំណល់នឹងគរ នឹងបង្កឲ្យមានភាពរាយពាយគ្មានសណ្ដាប់ធ្នាប់ ។ មិនមានតែយើងទេនៅលើផែនដីនេះ ។ យើងត្រូវចែកសត្វលោកឯទៀតរបស់អល់ឡោះហ៍ﷻ រស់នៅលើពិភពលោកនេះដែរ ។

សព្វសារពើនៅក្នុងភពផែនដែនចក្រវាលនេះ សុទ្ធតែត្រូវអល់ឡោះហ៍ﷻ បង្កើតមកដើម្បីបំពេញបំណងព្រះអង្គﷻ ។ យើងត្រូវគោរពអ្វីៗទាំងនេះនិងប្រើប្រាស់វាឲ្យត្រឹមត្រូវ កុំខ្ជះខ្ជាយ ។ សូម្បីតែរុក្ខជាតិក៏យើងត្រូវគោរពដែរ ព្រោះអល់ឡោះហ៍ﷻមានព្រះបន្ទូល (ស៊ូរ៉ោះត៊ុ 55 អាយ៉ាស់ 6) ថា៖

وَٱلنَّجْمُ وَٱلشَّجَرُ يَسْجُدَانِ ﴿٦﴾

*6. ផ្កាយនិងដើមឈើក្រាបថ្វាយបង្គំ[ចំពោះអល់ឡោះហ៍] ។*

ចូរយើងកុំបង្កឲ្យមានការរាត់រាយគ្មានសណ្ដាប់ធ្នាប់ ធ្វើឲ្យសត្វលោកឯទៀតរងទុក្ខ រងការលំបាកដោយសារតែយើងគិតតែប្រយោជន៍ផ្ទាល់ខ្លួន ។

ការខូចបរិស្ថានដោយសារអ្វីទៀតដែលអ្នកគិតថាអាចមាននោះ ?

មានតែឧស្សាហកម្មជំនួញទេដែលធ្វើឲ្យមានការខូចដល់បរិស្ថាន ឬអតិថិជនម្នាក់ៗមានការទទួលខុសត្រូវក្នុងការខូចបរិស្ថានដែរ ?

តើអ្នកមានដំណោះស្រាយអ្វី សម្រាប់ពេលខ្លីនិងអនាគត ដើម្បីការពារបរិស្ថានកុំឲ្យខូច ?

## មេរៀនទី ១៤

# តាកាប់ប៊ូរ, រីយ៉ាអ៊ុ, អ៊ុយ្ជូប

تَكَبُّر، الرِّيَاءَ ، العُجب

ប្រការទាំងបីនេះជាបាបធំនៅក្នុងចរិយាមារយាទមនុស្ស ។

តាកាប់ប៊ូរ មានន័យគិតថាខ្លួនឯងប្រសើរឬគ្រាន់បើជាងអ្នកដទៃ សរសើរខ្លួនឯង ។

រីយ៉ាអ៊ុ មានន័យថាអួតខ្លួនដាក់គេ ។

អ៊ុយ្ជូប ឬ អ៊ុច្ជុប៍ មានន័យថាប្រកាន់ខ្លួន ស្រឡាញ់ខ្លួនឯងហួសហេតុ ។

ប្រការទាំងបីនេះជាប់ពាក់ព័ន្ធគ្នាទៅរកចំណុចតែមួយគឺ អាត្មា ។

អាត្មារបស់បុគ្គលគឺគំនិតដែលបុគ្គលនោះគិតអំពីខ្លួនឯង ។

ពេលណាអ្វីមួយដែលល្អកើតមានដល់ខ្លួនយើង ឬពេលណាគេសរសើរយើង ពេលនោះអារម្មណ៍ត្រេកអរកើតមានដល់ខ្លួនយើង ។ បើយើងមិនប្រយ័តខ្លួនទេ អារម្មណ៍នេះអាចក្លាយទៅជាសេចក្តីក្រអឺតក្រទម សរសើរខ្លួនឯង ។

ព្រះបរមសាស្តាមូហ៊ាំម៉ាដ់ﷺមានព្រះវចនៈថា៖ *"ឫកទ្បឹតចូលទៅក្នុងចិត្តដូចស្រមោចខ្មៅវារលើដុំថ្មខ្មៅពេលយប់[1] ។"*

សឲ្យឃើញថាការសរសើរខ្លួនឯង (ឬឫកទ្បឹត ឬឫកធំ) ឈ្នះយើងយ៉ាងងាយស្រួលបំផុត ។

ការ (ឬអាការ) សរសើរខ្លួនឯងជាជម្ងឺរបស់ចិត្ត ។ កើតមកពីការខ្វះជំនឿចំពោះអល់ឡោះហ្ ﷻ ។ ពេលអ្នកមានអារម្មណ៍សរសើរខ្លួនឯង អ្នកគិតថាខ្លួនអ្នកបានធ្វើអ្វីៗដោយខ្លួនអ្នកផ្ទាល់ អ្នកភ្លេចថាអល់ឡោះហ្ﷻជាអ្នកដែលបានដឹកនាំ

[1] មើលសៀវភៅសិក្សា សីលធម៌ ថ្នាក់ទី ៧ មេរៀនទី ៨ ។

អ្នក ។

បើយើងបានធ្វើអ្វីមួយដែលល្អប្រសើរ យើងពេញចិត្តមែន តែយើងត្រូវពេញចិត្តអំពីលទ្ធផលរបស់ទង្វើយើង មិនត្រូវពេញចិត្តព្រោះតែយើងជាអ្នកធ្វើទង្វើនោះទេ ។

តែណាហ្វ្ស៍យើងខ្សឹបដាក់ចិត្តយើង ថាយើងបានធ្វើប្រការមួយដែលធំធេងបំផុត ថាយើងអស្ចារ្យ វាសរសើរយើងឥតដាច់ ។ល។ បណ្តាលឲ្យយើងសម្តែងដាក់គេថាយើងគ្រាន់បើ (រីយ៉ាអ៊្) សម្តែងដាក់គេថាយើងជាបុគ្គលពូកែណាស់ ។

យើងទាំងអស់គ្នាធ្លាប់បានឃើញអ្នកណាម្នាក់ក្នុងជីវិតយើង បន្ទាប់ពីបានមើលអ្នកនោះមួយភ្លែតយើងគិតក្នុងចិត្តថា៖ "អាគាត់នេះមេអួតមែន ។"

បើយើងចង់បានជោគជ័យក្នុងអនាគត ប្រការដំបូងបង្អស់ដែលយើងត្រូវធ្វើគឺគិតដល់អល់ឡោះហ្ទ៍ﷻ ។ នៅក្នុងឌូអាអ៊ុំក្រោយស្វ៊ឡាត់អ៊ាស្វារ យើងទូលអល់ឡោះហ្ទ៍ﷻថា៖ "اَللّٰهُمَّ مَا بِنَا مِنْ نِعْمَةٍ فَمِنْكَ - អល់ឡ៉ហ៊ុមម៉ា ម៉ា ប៊ីណា នៀក្ម៉ាទិន ហ្វា មិនកា (ព្រះម្ចាស់ﷻអើយ កោសល្យទាំងអំបាលម៉ានដែលទូលព្រះបង្គំជាខ្ញុំមាននោះ វាសុទ្ធតែមកពីព្រះអង្គﷻមួយគត់)" ។

បើយើងចង់មានឫកពារបសា យើងត្រូវចងចាំក្នុងចិត្តជានិច្ចមួយឃ្លានេះសូត្រវាក្នុងចិត្តរាល់ពេលដែលយើងធ្វើប្រការល្អនីមួយ ឬពេលយើងជាប់លេខមួយ ឬឈ្នះបានអ្វីមួយ ។ ដូច្នេះ យើងនឹងឃាត់ណាហ្វ្ស៍យើងមិនឲ្យវាសរសើរយើងទេ យើងនឹងដឹកនាំវាឲ្យសរសើរអល់ឡោះហ្ទ៍ﷻវិញ ។ យើងនឹងដឹងខ្លួនដែរថាយើងមិនមានអ្វីគួរឲ្យអួតដាក់គេទេ ព្រោះយើងមានសមត្ថភាពធ្វើប្រការដែលយើងបានធ្វើនោះដោយសារតែអល់ឡោះហ្ទ៍ﷻបានជួយយើងទេ ។

មានកំហុសអ្វីដែលសរសើរខ្លួនឯងនោះ ?

ក្រៅពីវាធ្វើឲ្យអ្នកផ្តាច់ខ្លួនពីអ្នកដទៃ ព្រោះអ្នកគិតថាខ្លួនអ្នកគ្រាន់បើជាងអ្នកផង ការសរសើរខ្លួនឯងធ្វើឲ្យអ្នកខូចខាតផ្នែកប្រាជ្ញាដែរ ។

សរសើរខ្លួនឯងព្រោះតែចេះដឹងឬបានធ្វើប្រការនីមួយ ដោយគិតថាខ្លួនអ្នក

អស្ចារ្យ អ្នកនឹងមិនព្យាយាមស្តាបនាខ្លួនអ្នកឲ្យកាន់តែប្រសើរឡើងទេ ។ ផ្ទុយទៅវិញ បើអ្នកគិតថាអ្នកអាចធ្វើឲ្យប្រសើរជាងនេះទៀតបាន អ្នកនឹងព្យាយាមខិតខំខ្លាំងឡើងទាល់តែបានលទ្ធផលកំពូល ។

សម័យព្រះសាស្តាមូសា﵇ គ្រាមួយព្រះអង្គ﷿នឹកក្នុងចិត្តថា៖ "មូសាអើយ ឯងបានដល់កំពូលហើយ ។ ពុំមានអ្នកណាមួយនៅលើផែនដីចេះដឹងស្មើឯងទេ ។" ព្រះអង្គ﵇មិនថាសម្តីនេះទេ ។ សម្តីនេះគ្រាន់តែឆ្លងកាត់គំនិតព្រះអង្គ﵇ទេ ។ អល់ឡោះហ្ទ៑﷿បានប្រាប់ទេវតាយ៉ីបរ៉អ៊ីល﵇ភ្លាមថា៖ "ចូរអ្នក﵇ទៅសង្គ្រោះមូសា﵇ឲ្យរួចផុតពីខ្លួនឯង﵇ ។" កាលនោះឯងដែលគេបានដាក់បញ្ជាឲ្យព្រះសាស្តាមូសា﵇ដើររកខ៌្ទ៍ជៀរអ្នកចេះដឹងជាងព្រះអង្គ﵇ ។ គេបានឲ្យព្រះអង្គ﵇ទៅសូមរៀនពីខ៌្ទ៍ជៀរ ។ ដូច្នេះ ព្រះសាស្តាមូសា﵇បានដឹងថាមានគេចេះដឹងច្រើនជាងព្រះអង្គ﵇ ដូច្នេះព្រះអង្គ﵇បានរួចផុតពីអាការសរសើរខ្លួនឯង ។

អ៊ីប្លីស(لعنه الله)ត្រូវកាត់ផ្តាច់ពីព្រះមេត្តាអល់ឡោះហ្ទ៑﷿ ដោយសារអាការសរសើរខ្លួនឯងនេះឯង ។ វាជាមេរៀនសម្រាប់យើងរាល់គ្នាដែលល្អៀងទៅរកអាការសរសើរខ្លួនឯង ។

កាលអល់ឡោះហ្ទ៑﷿បានបង្កើតអាដាំ﵇ ព្រះអង្គ﷿បានបញ្ជាឲ្យសត្វទាំងអស់ដែលត្រូវបង្កើតមកនោះលំឱនខ្លួនចំពោះព្រះអង្គ﵇ ។ ទាំងអស់គ្នាបានធ្វើតាមព្រះបញ្ជាលើកលែងតែអ៊ីប្លីស(لعنه الله)ទេដែលតវ៉ាថា៖ *"ទូលព្រះបង្គំជាខ្ញុំ(لعنه الله)ត្រូវបង្កើតមកពីភ្លើង អាដាំ﵇ត្រូវបង្កើតមកពីដី ។ ទូលព្រះបង្គំជាខ្ញុំ(لعنه الله)ប្រសើរជាងវា﵇ ។"* អល់ឡោះហ្ទ៑﷿បានដកព្រះមេត្តាព្រះអង្គ﷿ពីអ៊ីប្លីស(لعنه الله)ហើយឲ្យវា(لعنه الله)ចាកចេញ ។

ក្នុងអ៊ីស្លាម គេបានបង្ហាត់បង្រៀនយើងថាពុំមានបុគ្គលណាប្រសើរជាងបុគ្គលណាទេ ។

ក្នុងអ៊ីស្លាម មានជោគជ័យចម្រុងចម្រើនឬដឹកនាំគេ មិនមែនជាប្រការអាក្រក់ទេ តែចូរចងចាំថាសេចក្តីថ្កើងថ្កានជាការល្បងពិសោធន៍មួយដែរដើម្បីដឹងថាតើអ្នកនឹងដោះស្រាយដូចម្តេច ។ ដរាបណាយើងដឹងជាប់ក្នុងចិត្តថាយើងថ្កើងថ្កានដោយសារជំនួយរបស់អល់ឡោះហ្ទ៑﷿ ថាយើងមិនគ្រាន់បើជាងអ្នកដទៃទេ

ដរាបនោះយើងបានជោគជ័យក្នុងការពិសោធន៍នោះ ។

ព្រះសន្តអ៊ីមុាំទីបួនរបស់យើងعليه السلاممានវចនៈនៅក្នុងសាត្រា ស៊្វហ៊ីហ្វាស៊ូ អាល់-កាមីឡាស៊ូ ថាៈ

4. اللَّهُمَّ صَلِّ عَلَى مُحَمَّدٍ وَ آلِهِ ، وَ لَا تَرْفَعْنِي فِي النَّاسِ دَرَجَةً إِلَّا حَطَطْتَنِي عِنْدَ نَفْسِي مِثْلَهَا ، وَ لَا تُحْدِثْ لِي عِزّاً ظَاهِراً إِلَّا أَحْدَثْتَ لِي ذِلَّةً بَاطِنَةً عِنْدَ نَفْسِي بِقَدَرِهَا .

*4. អល់ឡោះហ៊្វ៎عز وجلអើយ សូមព្រះអង្គعز وجلប្រទានពរជ័យសិរិសួស្តីដល់មូហាំម៉ាដ៏صلى الله عليه وآله وسلمនិងព្រះរាជវង្សរបស់ព្រះអង្គعليهم السلام ។ សូមព្រះអង្គعز وجلកុំលើកស្ទួយទូលព្រះបង្គំជាខ្ញុំ ទោះបីមួយកម្រិតតូចក៏ដោយជាងអ្នកដទៃឡើយ បើព្រះអង្គعز وجلមិនបន្ទាបចិត្តទូលព្រះបង្គំជាខ្ញុំមួយកម្រិតតូចដែរទេនោះ ។ សូមព្រះអង្គعز وجلកុំព្រះរាជទានសេចក្តីសរសើរឲ្យទូលព្រះបង្គំជាខ្ញុំឡើយ បើព្រះអង្គعز وجلមិនបង្អាប់បង្អោនចិត្តទូលព្រះបង្គំដែរទេនោះ ។* (ការបួងសួងរបស់ព្រះអង្គعليه السلامអំពីសីលធម៌ថ្លៃថ្លានិងអំពីទង្វើដែលសព្វព្រះហឫទ័យអល់ឡោះហ៊្វ៎عز وجل វគ្គ ២០)

ឫកធំនិងអាការស៊ើចសរសើរខ្លួនឯងផ្ទុយនឹងអាការដាក់ខ្លួនរាបសា ។ តើត្រូវធ្វើដូចម្តេចដើម្បីមានអាការដាក់ខ្លួនរាបសា ? តើបានសេចក្តីថាត្រូវអង្គុយលើកន្ទេលស៊្វឡាត់ សូត្រមិនឈប់ឬ ?

ទេ ! ព្រះសន្តអ៊ីមុាំអាលីعليه السلامមានវចនៈថាៈ *"ភិនភាគរបស់អ្នកដាក់ខ្លួនគឺការពេញចិត្តនឹងកន្លែងដែលគេចាត់ឲ្យខ្លួននៅក្នុងសភា ការគំនាប់ពេលជួបគេ ការលះបង់ចោលទំនាស់និងការខ្វែងគំនិតគ្នាទោះបីខ្លួនជាអ្នកត្រូវក៏ដោយ និងការមិនទទួលយកការកោតសរសើរពីអ្នកដទៃព្រោះតែខ្លួនខ្លាចអល់ឡោះហ៊្វ៎عز وجلនោះ ។"*

ហេតុអ្វីយើងត្រូវបោះបង់ចោលអាការសរសើរខ្លួនឯងនិងត្រូវដាក់ខ្លួន ?

បើយើងដាក់ខ្លួន យើងសម្តែងប្រាប់ពិភពលោកថាអល់ឡោះហ៊្វ៎عز وجلបានបង្កើតមនុស្សមកស្មើភាពគ្នា ទោះបីមានសម្បុរសក្តី ដាំដែងក្តី ខ្មៅក្តី លឿងក្តី ។

យើងសម្តែងឲ្យឃើញថាបុគ្គលគ្រាន់បើជាងគេសម្រាប់អល់ឡោះហ៊្វ៎عز وجل គឺបុគ្គលដែលមានតាក្វ៉ា (تقوی) ក្នុងខ្លួន (ពោលគឺ បុគ្គលដែលចង់ផ្គាប់ចិត្តអល់ឡោះហ៊្វ៎عز وجلតែម្យ៉ាង) ។

ព្រះបរមសាស្ដាមូហាំម៉ាដ់ﷺមានព្រះវចនៈថា៖ *"ការពិត អាការដាក់ខ្លួនលើកឋានៈបុគ្គលឡើងទៅក្បែរអល់ឡោះហ៍ﷻ ។ ដូច្នេះ ចូរអស់លោករក្សាអាការដាក់ខ្លួន ព្រោះអល់ឡោះហ៍ﷻនឹងស្រោចព្រះធម៌មេត្តារបស់ព្រះអង្គﷻមកលើអស់លោក ។"*

ដំណាក់ការចុងក្រោយបង្អស់របស់អាការសរសើរខ្លួនឯងគឺអ៊ុយ្ជូប ពេលអ្នកចាប់ផ្ដើមជឿថាខ្លួនអ្នកខ្ពង់ខ្ពស់ជាងអ្នកដទៃ ពេលអ្នកមានយោបល់ខ្ពស់ហួសហេតុអំពីសមត្ថភាពរបស់ខ្លួនឯង អំពីសម្រស់ខ្លួនឯង ។ល។ គេហៅថាប្រកាន់ខ្លួន ។ ក្នុងដំណាក់ការនេះឯងដែលអ្នកចំណាយពេលច្រើន ដើម្បីមើលមុខខ្លួនឯងក្នុងកញ្ចក់ឆ្លុះ ។

ពេលណាបុគ្គលបានឈានដល់ដំណាក់ការនេះ គឺបុគ្គលនោះគិតថាពុំមានអ្នកណាដូចខ្លួនឡើយ ពេលនោះបុគ្គលនោះវង្វេងខ្លាំង ។ បុគ្គលនោះសាងកំផែងជុំវិញខ្លួនឯង ផ្ដាច់ខ្លួនពីមនុស្សឯទៀតក្នុងពិភពលោក ។ បុគ្គលនោះរស់នៅក្នុងលោកនៃសេចក្ដីស្រមៃរបស់ខ្លួនឯង ។

## មេរៀនទី ១៥

# សម្តីអាក្រក់, ការប្រមាថ, ការបញ្ឈឺនិងសេចក្តីព្រហើន

សម្តីអាក្រក់គឺប្រមាថឬជេរគេ ។ នេះជាប្រការអាក្រក់ពិតមែន តែគួរឲ្យឆ្ងល់វាជាទម្លាប់ទូទៅ ជាពិសេសក្នុងចំណោមយុវជន ។

យើងនឹងលើកយកសម្តីបែបនេះមកពិនិត្យ ហេតុអ្វីគេប្រើសម្តីបែបនេះ បើវាមានប្រយោជន៍នីមួយមែននោះ ។

មនុស្សភាគច្រើនជេរប្រទេចពេលពើបពះប្រការអាក្រក់ ឬពេលគេធ្វើប្រការនីមួយដែលខ្លួនមិនចូលចិត្ត ។ មនុស្សទាំងនោះថាជេរប្រទេចជួយពួកគេឲ្យអាចទប់កំហឹងខ្លួនឯងបាននិងឃាត់ពួកគេមិនឲ្យធ្វើប្រការអាក្រក់ជាងនេះ ។

នេះជាអំណះអំណាងមានហេតុផល តែអ៊ីស្លាមបដិសេធពីព្រោះ បើបុគ្គលណាមិនអាចទប់កំហឹងខ្លួនឯងបានទេដោយមិនប្រើសម្តីអាក្រក់នោះទេ បុគ្គលនោះខ្សោយអំណាចចិត្ត ។ យោលតាមអ៊ីស្លាម (និងសីលធម៌) បុគ្គលថ្លៃថ្នូរបំផុតគឺបុគ្គលដែលអាចទប់កំហឹងខ្លួនឯងបានថែមទាំងមានអាការក្រៅរីករាយទៀតផង ។

ជេរប្រទេចដើម្បីប្រមាថគេជាអំពើមិនត្រឹមត្រូវគ្រប់កាលៈទេសៈ ។ អ៊ីស្លាមបង្ហាត់បង្រៀនយើង**មិនឲ្យជេរប្រមាថគេជាដាច់ខាត** ។ ប្រសិនបើគេធ្វើខុសមកលើអ្នក អ្នកត្រូវចាត់វិធានការឬប្រាប់អ្នកនោះ ថាអ្នកមិនពេញចិត្តទង្វើដែលអ្នកនោះធ្វើទេ តែជេរប្រទេចអ្នកនោះគឺបន្ថោកខ្លួនឯងឲ្យថោកទាបណាស់ អ៊ីស្លាមមិនព្រមឲ្យបុគ្គលបាត់បង់សេចក្តីថ្លៃថ្នូរដូច្នេះទេ ។

និយាយបញ្ឈឺគេនិងនិយាយលលេងដាក់គេសម្តែងឲ្យឃើញដែរថា មួយប៉ែកនៃចរិតរបស់មនុស្សនោះមានតំណិះ ។ គេមើលឃើញថាវាដូចការនិយាយលេងសើចមែន តែចូរគិតមើលបន្តិចសិនថាខ្លួនអ្នកជាមនុស្សនោះ ។ តើអ្នកពេញចិត្តទេដែលគេហៅឈ្មោះអ្នកផ្សេងៗ ចំអកឲ្យអ្នក ? តើអ្នកចូលចិត្តទេដែលគេសើចឲ្យ

អ្នកពេលអ្នកដួល ឬគេនិយាយរឿងមិនពិតអំពីអ្នក ? តើអ្នកចូលចិត្តទេដែលគេនិយាយចំអកឲ្យគ្រួសារអ្នក ចំអកឲ្យសម្បុរអ្នកឬបែបបទរបស់អ្នក ?

នេះគឺពាក្យពេជន៍ខ្លះរបស់ព្រះសន្តអ៊ីម៉ាំអាលីصلوات الله عليه والسلامអំពីគ្រោះថ្នាក់ ដែលកើតពីអណ្ដាត ។ ចូរអានពាក្យពេជន៍នេះហើយចូរគិតមើលអត្ថន័យ ។

*"មានតែអណ្ដាតទេដែលត្រូវទប់និងត្រូវគ្រប់គ្រងជាងអ្វីៗទាំងអស់ ។"*

*"អ្នកណាចង់ការពារខ្លួនពីគ្រោះថ្នាក់ ចូរអ្នកនោះប្រយ័តអ្វីដែលចេញមកពីអណ្ដាតខ្លួន ។"*

*"ចូរអស់លោកប្រយ័តអណ្ដាតខ្លួនឯង ។"*

*"វិនាសលើអស់លោក ! មនុស្សនឹងត្រូវឲ្យដាក់ច្រមុះក្រាបលើភ្លើងនរកជាវង្វាន់តបស្នងអណ្ដាតពួកគេ[ដែលបានប្រើវាខុស] ។"*

*"បុគ្គលដែលមនុស្សខ្លាចអណ្ដាតនៅក្នុងចំណោមជនភ្លើងនរក ។"*

*"ការចាកផុតគ្រោះរបស់បណ្ដាអ្នកមានសទ្ធានៅលើការទប់អណ្ដាតខ្លួន ។"*

ពាក្យពេជន៍ខាងលើនេះសឲ្យឃើញនូវគ្រោះថ្នាក់ បណ្ដាលមកពីការនិយាយមិនគប្បី ។

ប្រការមួយទៀតដែលត្រូវអធិប្បាយបំភ្លឺគឺសេចក្ដីព្រហើន ពោលគឺហ៊ានឆ្លើយតបគេវិញដោយខ្វះសេចក្ដីគោរពពេលគេនិយាយរកខ្លួន ។

ពេលគេនិយាយរកអ្នក ទោះបីនិយាយទ្រគោះឬមិនទ្រគោះក្ដី អ្នកមិនត្រូវឆ្លើយវិញដោយរបៀបអាក្រក់ជាដាច់ខាត ។ បើអ្នកមិនខុសទេ ចូរពន្យល់ប្រាប់ទេតែឆ្លើយតបឪពុកម្ដាយឬលោកគ្រូអ្នកគ្រូវិញយ៉ាងព្រហើន ជាការសម្ដែងឲ្យឃើញនូវការខ្វះសីលធម៌ដែលមិនអាចអត់ឱនឲ្យបាន ។

សេចក្ដីគោរពដែលគេតម្រូវឲ្យអ្នកមានចំពោះឪពុកម្ដាយ និងលោកគ្រូអ្នកគ្រូនោះសំខាន់ណាស់ អ្នកមិនត្រូវសម្ដែងឲ្យឃើញថាអ្នកមិនពេញចិត្តទេដែរ មិនចាំបាច់និយាយអំពីការឆ្លើយតបវិញយ៉ាងព្រហើននោះទេ !

សេចក្ដីព្រហើនបានត្រឹមតែបញ្ជាក់ថាអ្នកខ្សោយចរិតប៉ុណ្ណោះ ។ អ្នកអាចមានអារម្មណ៍ថាអ្នកខ្លាំងមួយភ្លែតនៅក្នុងថ្នាក់រៀន តែទីបំផុតអ្នកអាចបាត់បង់សេចក្ដីគោរពដែលមនុស្សចាស់មានចំពោះអ្នក ។

## មេរៀនទី ១៦

# ទម្លាយអាថ៌កំបាំងគេ

មនុស្សគ្រប់រូបសុទ្ធតែមានរឿងសម្ងាត់ផ្ទាល់ខ្លួន ។ គេមិនចង់បើកកកាយឲ្យអ្នកដទៃដឹងរឿងនោះទេព្រោះតែវាធ្វើឲ្យទើសចិត្ត ធ្វើឲ្យខ្មាសគេឬធ្វើឲ្យគេស្គាល់កំហុស ។ល ។

ពេលគេប្រាប់អ្នកឲ្យដឹងរឿងសម្ងាត់ គេបានប្រគល់អ្វីមួយដ៏សំខាន់ឲ្យមកអ្នក យើងមិនសូវយកចិត្តទុកដាក់អំពីចំណុចនេះទេ ។

ព្រះបរមសាស្ដាមូហាំម៉ាដ់ﷺមានព្រះវចនៈថា៖ *"អ្នកណាមិនរក្សាបញ្ញើទេ អ្នកនោះពុំមានសាសនាទេ ។"*

នៅក្នុងព្រះគម្ពីរគួរអាន ស៊ូរ៉ោះត៍ 8 អាយ៉ាស់ 27 អល់ឡោះហ្ជ័ﷻមានព្រះបន្ទូលថា៖

يَٰٓأَيُّهَا ٱلَّذِينَ ءَامَنُواْ لَا تَخُونُواْ ٱللَّهَ وَٱلرَّسُولَ وَتَخُونُوٓاْ أَمَٰنَٰتِكُمۡ وَأَنتُمۡ تَعۡلَمُونَ ۝٢٧

*27. បណ្ដាអ្នកមានសទ្ធាអើយ ចូរពួកអ្នកកុំក្បត់អល់ឡោះហ្ជ័និងសាស្ដា[ព្រះអង្គ] ហើយចូរកុំក្បត់សេចក្ដីទុកចិត្តឡើយ ថ្វីបើពួកអ្នកដឹងច្បាស់ ។*

ចូរសាកគិតមើលថា បើគេយកប្រាក់មកផ្ញើអ្នកដោយថា៖ "សូមអ្នកជួយមើលប្រាក់ខ្ញុំផង ។ កុំឲ្យវាទៅអ្នកណាដាច់ខាត ។"

បើអ្នកយល់ព្រម តែក្រោយពីអ្នកនោះចេញទៅផុត អ្នកឲ្យប្រាក់នោះទៅអ្នកណាម្នាក់ អ្នកនឹងក្បត់សម្ដីឯង ទោះបីអ្នកយកប្រាក់នោះបានមកវិញក៏ដោយ ។

អាថ៌កំបាំង (ឬរឿងសម្ងាត់) ក៏ដូច្នេះដែរ ។ វាជាអ្វីៗដែលគេផ្ញើទុកនឹងអ្នក (អាម៉ាណាស់ أَمَانَة) អ្នកមិនមានសិទ្ធិប្រាប់អ្នកដទៃឲ្យដឹងទេ ។

ព្រះបរមសាស្ដាមូហាំម៉ាដ់ﷺមានព្រះវចនៈថា៖ *"ពេលគេអនុញ្ញាតឲ្យលោក*

*ចូលក្នុងផ្ទះគេ មានបួនប្រការដែលធ្វើឲ្យបាត់បង់និងរារាំងសេចក្តីចម្រុងចម្រើន ។"*

ប្រការមួយ ក្នុងចំណោមប្រការទាំងបួននោះ គឺការក្បត់សេចក្តីទុកចិត្ត ។

ព្រះអង្គﷺមានព្រះវចនៈដែរថា៖ *"គេស្គាល់បុគ្គលមានពុតត្បុតអាស្រ័យសញ្ញាបីគឺ៖ បុគ្គលនោះនិយាយកុហក បុគ្គលនោះមិនគោរពពាក្យសន្យាទេ បុគ្គលនោះក្បត់សេចក្តីទុកចិត្តរបស់អ្នកផង ។"*

បើអ្នកណាម្នាក់និយាយការសម្ងាត់ប្រាប់អ្នក តែអ្នកដឹងថាបើអ្នកនិយាយការសម្ងាត់នោះប្រាប់គេ អ្នកអាចជួយអ្នកនោះបាន តើអ្នកត្រូវធ្វើយ៉ាងណា ?

ក្នុងករណីនេះ មិនមានបាបទេបើអ្នកប្រាប់គេឲ្យដឹងការសម្ងាត់នោះ ឲ្យតែកុំប្រាប់ឲ្យគេដឹងអត្តសញ្ញាណរបស់អ្នកដែលប្រាប់ការសម្ងាត់នោះមកអ្នក និងឲ្យតែអ្នកគិតដោយស្មោះថាដើម្បីជួយបុគ្គលនោះ ។

ចូរចងចាំទុកក្នុងចិត្តថា ព្រះសន្តអ៊ីម៉ាំអាលី صلوات الله عليه والسلام មានវចនៈថាបើយើងមិនអាចរក្សារឿងសម្ងាត់របស់ខ្លួនឯងដោយមិនឲ្យគេដឹងបានទេ តើយើងសង្ឃឹមថាគេអាចរក្សារឿងសម្ងាត់របស់យើងបានដូចម្តេចទៅ បើខ្លួនយើងផ្ទាល់មិនអាចធ្វើដូច្នេះបានផងនោះ !

## ការលាយបន្លំក្នុងទំនិញ

ការលាយបន្លំគឺធ្វើឲ្យអ្វីមួយទៅជាមិនបរិសុទ្ធ ធ្វើឲ្យវាខូច[ដោយសារឆ្លង] ។

ទំនិញផ្តោតទៅលើការជួញដូរផលិតផល គ្រឿងបរិភោគ ។

ដូច្នេះ ការលាយបន្លំក្នុងទំនិញបានសេចក្តីថាធ្វើឲ្យរបស់នីមួយដែលអ្នកលក់ឲ្យគេនោះទៅជាមិនបរិសុទ្ធឬបន្ថយតម្លៃវាដោយវិធីនីមួយ ។

នេះជាការបោកប្រាស់មួយប្រភេទ ។

វាជាប្រការហាមឃាត់ព្រោះ ៖

ក). បុគ្គលបោកប្រាស់គេបានកម្រៃដោយធ្វើឲ្យគេខូចខាត ។

ខ). បុគ្គលបោកប្រាស់គេបានកម្រៃដោយពុំបានប្រកបកិច្ចការ (គឺបានមកដោយងាយៗ) ។

នៅឯទីផ្សារ ឧទាហរណ៍ថាគេមកទិញអង្ករដែលអ្នកបានថ្លឹងរួចមុនស្រេចហើយ បើភ្នែកជញ្ជីងត្រូវបន្លំធ្វើឲ្យអ្នកទិញអង្ករបានអង្ករតិច បានសេចក្ដីថាអ្នកទិញចំណាយប្រាក់ច្រើនសម្រាប់ទិញអង្ករតិច ។ លទ្ធផលគឺអ្នកបានប្រាក់ច្រើន ចំណែកឯអ្នកទិញខាតបង់ប្រាក់ ។

ចូរដឹងអំពីការបោកប្រាស់ថា ទោះបីអ្នកអាចបោកប្រាស់គេបានច្រើននាក់ក៏ដោយ ដោយប៉ិនប្រសប់យ៉ាងណាក៏ដោយ តែអ្នកមិនអាចឆបោកខ្លួនឯងឬបោកប្រាស់អល់ឡោះហ៊ូ ﷻ បានដាច់ខាត ។ បើអ្នកបោកប្រាស់អ្នកណាម្នាក់ សម្បជញ្ញៈរបស់អ្នក (ថ្នាក់ទីពីររបស់ណាហ្វ៍ស៍អ្នក) នឹងដឹងភ្លាម ។



នៅក្នុងព្រះគម្ពីរគួរអាន ស៊ូរ៉ោះតុ៍ 7 អាយ៉ាស្ទ៍ 85 អល់ឡោះហ៊ូ ﷻ ថែងអំពីព្រះវចនៈរបស់ព្រះសាស្ដាស៊្វអ៊ែប៍ ﷺ ប្រាប់ប្រជារាស្ត្រព្រះអង្គ ﷺ ថា៖

وَإِلَىٰ مَدْيَنَ أَخَاهُمْ شُعَيْبًا ۗ قَالَ يَٰقَوْمِ ٱعْبُدُوا۟ ٱللَّهَ مَا لَكُم مِّنْ إِلَٰهٍ غَيْرُهُۥ ۖ قَدْ جَآءَتْكُم بَيِّنَةٌ مِّن رَّبِّكُمْ ۖ فَأَوْفُوا۟ ٱلْكَيْلَ وَٱلْمِيزَانَ وَلَا تَبْخَسُوا۟ ٱلنَّاسَ أَشْيَآءَهُمْ وَلَا تُفْسِدُوا۟ فِى ٱلْأَرْضِ بَعْدَ إِصْلَٰحِهَا ۚ ذَٰلِكُمْ خَيْرٌ لَّكُمْ إِن كُنتُم مُّؤْمِنِينَ ﴿٨٥﴾

*85. [យើងបានបញ្ជូន]ស៊្វអ៊ែប៍មករកប្រជាជាតិម៉ាដ្ញ៉ាន់ គេជាបងប្អូនពួកគេ ។ គេបានប្រកាស[ប្រាប់ពួកគេ]ថា៖ "ប្រជារាស្ត្រអើយ ចូរអស់លោកគោរពបូជា*

*អល់ឡោះហ៍ ។ ពុំមានព្រះផ្សេងពីព្រះអង្គទេសម្រាប់អស់លោក ។ ភ័ស្តុតាងជាក់ច្បាស់មួយដែលមកពីព្រះម្ចាស់អស់លោកបានមកដល់អស់លោកហើយ ។ ដូច្នេះចូរអស់លោកវាស់ថ្លឹងឲ្យត្រឹមត្រូវ ។ ចូរអស់លោកកុំបំបាត់ទ្រព្យរបស់អ្នកដទៃឡើយ ។ ចូរអស់លោកកុំបង្កវិនាសនៅលើផែនដីឡើយ ក្រោយពីវាត្រូវបានកែឲ្យមានសណ្តាប់ធ្នាប់ហើយនោះ ។ នេះជាការប្រពៃបំផុតសម្រាប់អស់លោក បើអស់លោកមានសទ្ធាមែន ។*

ថ្ងៃជំនុំជម្រះ អ្នកត្រូវតែឆ្លើយសំណួរអល់ឡោះហ៍ﷻ ខ្លួនអ្នកផ្ទាល់នឹងត្រូវជម្រះក្តីដោយជញ្ជីងមួយដែលនឹងថ្លឹងទង្វើល្អនិងទង្វើអាក្រក់របស់អ្នក ។ **បោកប្រាស់គេជាទង្វើអាក្រក់មួយដែលមានទម្ងន់ធ្ងន់ជាងគេ ។**

## មេរៀនទី ១៧

# កំហឹង

الْغَضَب

ភាសាអារ៉ាប់ហៅកំហឹងថា ក៏ដ្ធប់ ឬ គុដ្ធប៍ ។

កំហឹងជាជម្ងឺចិត្ត ។ វាជាប្រភពបញ្ហាច្រើន យើងនឹងអធិប្បាយបំភ្លឺនៅក្នុងវគ្គតទៅនេះ ។

កំហឹងគឺអាការ "មិនពេញចិត្តជាទីបំផុត" បានសេចក្ដីថាទំនាស់ចិត្តបណ្ដាលមកពីសម្ដីឬទង្វើរបស់បុគ្គលនីមួយ ។

ពេលបុគ្គលណាមួយមានកំហឹង បុគ្គលនោះទៀបបាត់បង់ការគ្រប់គ្រងអារម្មណ៍ខ្លួនឯង ។ បុគ្គលនោះអាចទៅជាឃោរឃៅ អាចបំផ្លិចបំផ្លាញអ្វីៗបាន និងអាចនិយាយសម្ដីដែលធ្វើឲ្យស្ដាយក្រោយបានដែរ ។

ហេតុដូច្នេះឯងបានជា អាចទប់ខ្លួនបានពេលអ្នកក្រោធនោះជាប្រការសំខាន់ណាស់ ព្រោះអ្នកអាចបំផ្លិចបំផ្លាញ មិនអាចកែឡើងវិញបានទេ ដោយសម្ដីតែពីរបីម៉ាត់នូវអ្វីមួយដែលអ្នកបានចំណាយពេលច្រើនឆ្នាំដើម្បីកសាងវាឡើង ។

ព្រះបរមសាស្ដាមូហាំម៉ាដ់ﷺមានព្រះវចនៈថាៈ *"អស់លោកគិតថាគេវាស់ស្ទង់កម្លាំងអាស្រ័យលើសមត្ថភាពលើកដុំថ្ម (ធ្ងន់) តែការពិតវាអាស្រ័យលើសមត្ថភាពទប់ខ្លួនឯងពេលត្រូវកំហឹងឆេះឆួល ។"*

សឲ្យឃើញថាពិបាកទប់ខ្លួនណាស់ក្នុងពេលមានកំហឹង ។

កំហឹងប្រកបដោយគ្រោះថ្នាក់ដែរ ។ មនុស្សច្រើនទៅជាឆ្កួតពេលមានកំហឹង ដូចជាវាយដំ ស្រែកឡូឡាជាដើម ។ អ្នកនោះទៅជាឃោរឃៅ ។ បន្ទាប់មក ពេលឈប់ខឹងវិញ អ្នកនោះដឹងខ្លួនថាអ្វីដែលខ្លួនថានោះបានធ្វើឲ្យកេរ្តិ៍ឈ្មោះខ្លួនឯងខូច

បានធ្វើឲ្យមនុស្សគិតអាក្រក់អំពីខ្លួន ។ ដូច្នេះហើយបានជាព្រះសន្តអ៊ីម៉ាំអាលីصلوات الله عليه والسلام មានវចនៈថា៖ *"កំហឹងប្រៀបបាននឹងភ្លើងដែលកំពុងឆេះសន្ធោសន្ធៅ អ្នកណាទប់វាឈ្នះ អ្នកនោះពន្លត់វា អ្នកណាបណ្តោយឲ្យវាឆេះ អ្នកនោះត្រូវវាឆេះមុនគេ ។"*

ដូច្នេះ អ្នកណាមិនអាចទប់កំហឹងខ្លួនឯងបានទេ អ្នកនោះជាបុគ្គលរងគ្រោះមុនគេដោយសារទង្វើនិងសម្តីខ្លួនឯង ។

កំហឹងមិនផ្តល់ផលប្រយោជន៍ឲ្យយើងទេ ។ បុគ្គលដែលក្រោធចំណាយកម្លាំងឥតប្រយោជន៍ដើម្បីទៅជាបុគ្គលខាតបង់នៅទីបំផុត ។

តើត្រូវធ្វើអ្វីពេលយើងក្រោធ ? តើអាចទប់ខ្លួនបានដូចម្តេច ?

ដំបូងបង្អស់ត្រូវរម្ងប់អារម្មណ៍ ។

ដើម្បីនឹងអាចធ្វើដូច្នេះបាន ព្រះបរមសាស្តាមូហាំម៉ាដ់ﷺមានព្រះវចនៈថា៖ *"កំហឹងចេញមកពីស្ហៃតនលعنه اللهដែលត្រូវបង្កើតពីភ្លើង ។ គេពន្លត់ភ្លើងដោយទឹក ដូច្នេះហើយបានជារាល់ពេលដែលគេក្រោធ គេត្រូវយកទឹកវូឌុអ៍ ។"*

ទឹកវូឌុអ៍មានប្រសិទ្ធភាពធ្វើឲ្យខ្លួនស្ងប់ ធូរស្រាល ។ វាធ្វើឲ្យយើងនឹកនាដល់អល់ឡោះហ្ជ៍عزّ وجلّដែរ ដូច្នេះយើងអាចទប់ខ្លួនបាន ។

ព្រះសន្តអ៊ីម៉ាំអាលីصلوات الله عليه والسلامមានព្រះវចនៈថា៖ *"ពេលអ្នកណាមួយមានកំហឹង ចូរអ្នកនោះអង្គុយចុះបើកំពុងឈរ ។ បើកំពុងអង្គុយហើយក៏កើតមានកំហឹងឡើង ចូរអ្នកនោះផ្តេកខ្លួន ។"*

កំហឹងកើតមកពីអ្វី ?

កំហឹងមានមូលហេតុច្រើន ដូចជាការប្រកាន់ខ្លួនហួសហេតុនិងសេចក្តីមានះរឹងរូសជាដើម ។

បើអ្នកខុសគេប្រាប់កំហុសអ្នក អ្នកអាចទទួលស្គាល់កំហុសឬអាចចចេសតវ៉ាថាអ្នកត្រូវ ។ វាអាចបង្កឲ្យមានកំហឹងព្រោះអ្នកមិនព្រមទទួលស្គាល់ថាខ្លួនអ្នកខុសទេ ។

កំហឹងអាក្រក់ណាស់ វាអាចធ្វើឲ្យទង្វើល្អឯទៀតរបស់អ្នកខូចបាន ។ ព្រះសន្តអ៊ីម៉ាំអាលីعليه والسلام صلوات اللهមានវចនៈថា៖ *"កំហឹងធ្វើឲ្យទង្វើល្អខូច ដូចទឹកខ្មេះធ្វើឲ្យទឹកឃ្មុំខូចដែរ ។"*

បើអ្នកដាក់ទឹកខ្មេះមួយតក់ទៅក្នុងទឹកឃ្មុំ អ្នកធ្វើឲ្យរសជាតិទឹកឃ្មុំខូច ។ ដូចគ្នាដែរ កាលណាអ្នកក្រោធ កាលនោះអ្នកធ្វើឲ្យទង្វើល្អរបស់អ្នកខូចខាតដោយសារការប្រព្រឹត្តរបស់អ្នក ។

*"អ្នកខ្លាំងជាងគេក្នុងចំណោមអស់លោកគឺអ្នកដែលទប់ខ្លួនបានពេលក្រោធ ។ អ្នកមានសន្តោសជាងគេក្នុងចំណោមអស់លោកគឺអ្នកដែលអត់ឱន លើកលែង ពេលអ្នកនោះមានប្រៀបលើសត្រូវខ្លួន ។"*

ដូច្នេះ ទោះបីយើងមានសិទ្ធក្រោធក៏ដោយ យើងត្រូវអត់ឱនឲ្យគេ ។ អល់ឡោះហ៍ عز وجلរំលឹកយើងរឿងនេះ ព្រោះយើងទាំងអស់គ្នាបានប្រព្រឹត្តអំពើដែលព្រះអង្គ عز وجلមិនសព្វព្រះហឫទ័យ គឺ៖

*"កូនអាដាំعليه السلامអើយ ចូរពួកអ្នកនឹកដល់អញ عز وجلពេលពួកអ្នកក្រោធ ដើម្បីអញ عز وجlនឹងនឹករលឹកដល់ពួកអ្នកពេលពួកអ្នកសមនឹងរងព្រះពិរោធអញ عز وجل ហើយអញ عز وجلនឹងមិនកម្ទេចពួកអ្នកចោល ។"*

បើយើងអត់ឱនឲ្យសត្រូវយើងដោយគិតដល់អល់ឡោះហ៍ عز وجل អល់ឡោះហ៍ عز وجلក៏នឹងអត់ឱនឲ្យយើងដែរក្នុងថ្ងៃជំនុំជម្រះ អ៊ីនស្សាអ៊ុំអល់ឡោះហ៍ ។

**មេរៀនទី ១៨**

# គ្រប់អាយុ (បាលិក្ុ)

بالغ

កាលអល់ឡោះហ្ទ៍ﷻបង្កើតមនុស្ស ព្រះអង្គﷻបានធ្វើឲ្យមនុស្សធំតាមដំណាក់ការផ្សេងៗ ។

ចាំបាច់ត្រូវពឹងពាក់លើគេទាំងស្រុងពេលកើតមក មនុស្សចេះដឹងតាមលំដាប់កាលដែលខ្លួនធំដុះដាល និងដឹងបន្តិចម្តងៗថាពិភពលោកដំណើរការដូចម្តេចខ្លះ ។ បន្ទាប់មក វានឹងបានដល់លំដាប់កាលដែលគេបង្ហាត់វាឲ្យចេះដឹងរបៀបរស់នៅនិងត្រូវចេះគោរពអ្វីខ្លះ ។ គេបង្ហាត់វាឲ្យស្គាល់ប្រការល្អនិងប្រការអាក្រក់ ។ ពេលនេះវាអាចមានការទទួលខុសត្រូវនិងអាចទៅជាមនុស្សធំបាន ។ វាលែងជាកូនក្មេងហើយតែមិនទាន់ជាមនុស្សពេញវ័យទេ ។ លំដាប់កាលនេះឯងដែលកូនក្មេងបានដល់កំណាក់ការគ្រប់អាយុ (បាលិក្ុ بالغ) ឬ ពេញជំទង់ ។

តាមភាសាបរទេស គេបកស្រាយបាលិក្ុថាពេញជំទង់ តែមិនសមស្របទេ ។ បាលិក្ុមានន័យថាការទទួលខុសត្រូវ គឺទៅជាមនុស្សពេញវ័យទាំងកាយនិងទាំងចិត្តគំនិតជាមួយគ្នា ។

**កំណាក់ការគ្រប់អាយុ (បាលិក្ុ) មានសញ្ញាសម្គាល់ដូចម្តេចខ្លះ ?**

មានសញ្ញាសម្គាល់បី (សម្រាប់ក្មេងប្រុស) ។ សញ្ញានីមួយៗបញ្ជាក់ឲ្យដឹងថាក្មេងប្រុសគ្រប់អាយុឬទេ ។

១. បើក្មេងប្រុសដល់អាយុ ១៥ ឆ្នាំ (រាប់តាមប្រក្រតិទិនចន្ទគតិ) ១៤ ឆ្នាំកន្លះរាប់តាមប្រក្រតិទិនសុរិយគតិ គេចាត់ទុកក្មេងនោះថាគ្រប់អាយុ (បាលិក្ុ) ទោះបីឃើញឬមិនឃើញសញ្ញាពីរទៀតក៏ដោយ ។

២. ពេលឃើញដុះរោមរឹង (ឬក្រាស់) ត្រង់ខ្មាស ។ រោមឆ្មារ (ឬទន់) មិនមែនសញ្ញាសម្គាល់ថាគ្រប់អាយុបាលិក្ុទេ ។

៣. បើ "យល់សប្តិទទឹក"។ ក្នុងពេលដេកក្មេងយល់សប្តិនីមួយដែលបណ្តាលឲ្យចេញវត្ថុខាប់ដែលមិនមែនទឹកនោមទេ ។ វត្ថុខាប់នេះគឺទឹកកាមដែលអាចស្គាល់បានអាស្រ័យពណ៌សទឹកដោះគោនិងមានក្លិនខ្លាំង ស្រដៀងក្លិនផ្សិតចំបើង ។

សំខាន់ត្រូវដឹងថាគេត្រូវតែងូតទឹក គូស្លូល យ៉ាណាបាស្ង់ រាល់ពេលដែលចេញទឹកកាម ទោះបីដោយចេតនាក្តី អចេតនាក្តី ។ បើមិនបានងូតទឹក គូស្លូល យ៉ាណាបាស្ង់ នេះទេ គេនៅក្នុងអាការមិនបរិសុទ្ធ (យ៉ាណាបាស្ង់) មិនអាចស្ហ៍ឡាត់ ឬកាន់សីលត្រណមបានទេ ។

បើអ្នកណាមួយមិនដឹងច្បាស់ថាបាលិក្កុទេ អ្នកនោះត្រូវតែរង់ចាំទាល់តែដឹងច្បាស់ ឬទាល់តែបានឃើញសញ្ញាសម្គាល់ងទៀត ។

**គ្រប់អាយុបាលិក្កុបានសេចក្តីថាអ្វី?**

គ្រប់អាយុបាលិក្កុជាប្រក្រតីរបស់មនុស្ស ។ មិនមានតែអ្នកម្នាក់ទេ ។ ក្មេងប្រុសទាំងអស់ឆ្លងកាត់ដំណាក់ការនេះក្នុងចន្លោះអាយុ ១៣ ឆ្នាំនិង ១៥ ឆ្នាំ ។

ពេលគេគ្រប់អាយុបាលិក្កុ ទៅជាវ៉ាយ៉ិបធ្វើទង្វើទាំងអស់ដែលអ៊ិស្លាមដាក់មក ហ្វារ៉ាំធ្វើទង្វើទាំងអស់ដែលអ៊ិស្លាមហាម ។ បានសេចក្តីថា ស្ហ៍ឡាត់ ស្ហៅម៍ (កាន់សីលត្រណម) ពិធីហ្វាច្ចុំនិងឃុំមស៍ជាវ៉ាយ៉ិបទាំងអស់ ។

ប្រការផ្សេងៗទៀតដែលត្រូវដឹងគឺ ពេលគ្រប់អាយុបាលិក្កុ អ្នកនឹងមានអារម្មណ៍ខ្លះដែលមិនធ្លាប់មានកាលពីមុន ។

ខ្លួននឹងផ្លាស់ប្តូរ អ្នកនឹងផ្លាស់ប្តូរច្រើន ។ ក្រពេញ (សរីរាង្គ) អ្នកនឹងដំណើរការពេញទំហឹង បង្កើតឡើងនូវសារជាតិគីមីដែលហូរទៅតាមឈាមអ្នក ។ កោសិកាអ្នកនឹងប្រតិបត្តិការលើសពេល បញ្ជូនសញ្ញាទៅប្រាប់ខ្លួនប្រាណអ្នក

កោសិកាអ្នក ថាដល់ពេលធំហើយ ។ ខ្លួនប្រាណអ្នកនឹងផ្លាស់ប្តូរ សាច់ដុំអ្នកនឹងឡើងធំនិងខ្លាំងជាងមុន អ្នកនឹងមានរោមដុះលើមុខ លើខ្លួន លើទ្រូង ត្រង់ខ្មាសនិងក្រោមស្មា ។ អ្នកនឹងមានរាងជាបុរសជាងមុន ។

មានប្រការសំខាន់ផ្សេងៗទៀតពេលអ្នកគ្រប់អាយុបាលិគ្គឺ ណាហ្ស៍អ្នកនឹងដឹកនាំអ្នកទៅរកផ្លូវអាក្រក់តាមចំណង់អ្នក ។ ពេលអ្នកបាលិគ្គ រូបថតឬរូបភាពពាក់ព័ន្ធនឹងភេទនឹងធ្វើឲ្យអ្នកមានសម្រើប ។ ដូច្នេះ អ្នកត្រូវចៀសវាងអានឬមើលសៀវភៅឬកម្មវិធីទូរទស្សន៍ប្រភេទនេះ ថែមទាំងចៀសវាងនិយាយលេងសើចចំអាសចំអូងបណ្តាលឲ្យមានសម្រើបដែរ ។

មានទំនាក់ទំនងផ្លូវភេទជាធម្មជាតិរបស់មនុស្សក្នុងសង្គម តែត្រូវនៅក្នុងក្របខ័ណ្ឌអាពាហ៍ពិពាហ៍ ។ ត្រូវទប់តម្រេក ។ បើអ្នកបណ្តោយវា អ្នកឈ្លក់ក្នុងកាមដែលអាចគ្រប់គ្រងអ្នកបានយ៉ាងងាយ ។

បើយើងបណ្តោយឲ្យតម្រេកយើងគ្រប់គ្រងយើងបាន យើងនឹងធ្វើឲ្យវិញ្ញាណយើងខូចខាត ។ វិញ្ញាណយើងនឹងក្លាយទៅជាខ្ញុំរបស់កាម ជីវិតយើងនឹងវិនាស ។

### ហេតុអ្វីយើងបាលិគ្គ?

យើងបាលិគ្គនៅក្នុងវ័យដែលយើងទៅជាអ្នកមានការទទួលខុសក្នុងខ្លួន ។

ទទួលការខុសត្រូវអ្វី ?

ពេលយើងបាលិគ្គ ខ្លួនយើងបង្កើតកោសិកាមេជីវិតដែលត្រូវផ្ទុកនៅក្នុងទឹកកាម ។ ពេលក្មេងស្រីបាលិគ្គ ខ្លួននាងបង្កើតកោសិកាមេជីវិតមួយប្រភេទទៀតដែលហៅថាពងបុប្ផាណ្ឌ (កោសិកាញី ovule) ។ ពេលមេជីវិតជួបពងបុប្ផាណ្ឌ គេហៅថាការផ្សំឲ្យមានផល មនុស្សម្នាក់ទៀតនឹងចាប់ផ្តើមកកើតឡើង ។ កោសិកាទាំងពីរនេះនឹងរលាយចូលគ្នាទៅជាកោសិកាតែមួយគត់ ហើយធំដុះដាលទៅជាកូនក្មេងម្នាក់ កូនក្មេងនេះនឹងមានលក្ខណៈរបស់ឪពុកនិងរបស់ម្តាយ ។ ដូច្នេះ យើងបាលិគ្គដើម្បីអាចរៀបការបាននិងអាចមានកូនបាន ។ ហេតុដូច្នេះ មនុស្សជាតិនឹងគង់វង្សតទៅមុខទៀត ។

តែយើងត្រូវមានការទទួលខុសត្រូវក្នុងខ្លួន ព្រោះមានប្រការខ្លះដែលអាចធ្វើឲ្យយើងទប់ចំណង់ខ្លួនឯងមិនបាន ដូចជាមើលឆាកមិនសមរម្យក្នុងទូរទស្សន៍ អានសៀវភៅដែលធ្វើឲ្យមានសម្រើប ទៅរាំរែកងរង្គសាលឬក្នុងបុណ្យល្ងចលាក់ជាដើម ។ ប្រការទាំងអស់នេះនាំយើងទៅរកការឈ្លក់ក្នុងកាម ដូច្នេះត្រូវចៀសវាង ។

**មេរៀនទី ១៩**

# ការបណ្តោតបណ្តោយ

បណ្តោតបណ្តោយគឺបន្ធូរពេក អនុញ្ញាតឬបើកដៃឲ្យធ្វើអ្វីៗតាមចិត្តពេក ។

នេះគឺយោបល់ផ្លូវសីលធម៌ ពិបាកកំណត់ន័យ តែអាចអធិប្បាយបំភ្លឺបានដូចតទៅនេះ ។

ពេលគេថាពិភលោកប៉ែកខាងលិចអាក្រក់ ការពិតគេចង់និយាយថាខ្វះសីលធម៌ ។ ពិភពលោកប៉ែកខាងកើតចម្រើនខ្លាំងផ្នែកបច្ចេកទេស តែអកុសល មិនចម្រើនដូចគ្នាដែរទេផ្នែកសីលធម៌ ។

ពេលអ្នកដើរតាមផ្លូវ អ្នកឃើញគេស្ទើរតែមិនស្លៀកពាក់ អ្នកឃើញសៀវភៅដាក់តាំងក្នុងបង្អួចកញ្ចក់បង្ហាញរូបចំអាសចំអូង ។

ទូរទស្សន៍ក៏ដូច្នេះដែរ កម្មវិធីភាគច្រើនធ្វើឲ្យទស្សនិកជនកម្រើកអារម្មណ៍ផ្លូវភេទ ។

ពេលសង្គមប្រែក្លាយ ដល់ថ្នាក់វិស័យនីមួយៗរបស់សង្គមនោះលំអៀងទៅរកការបម្រើសម្រេករបស់មនុស្ស ជាពិសេសសម្រេកផ្លូវភេទ គេហៅសង្គមនេះថាបណ្តោតបណ្តោយឬបន្ធូរពេក ។

ក្នុងសាសនាអ៊ីស្លាម អល់ឡោះហ៊ូ ﷻ បានឲ្យមនុស្សមានគុណសម្បត្តិមួយដែលហៅ "ហ្គាយ៉ាអ៊ុ (حَيَاء)" ។ ហ្គាយ៉ាអ៊ុមានន័យថាសេចក្តីសុភាពរាបសា សេចក្តីអៀនខ្មាសនិងសេចក្តីថ្លៃថ្នូររួមគ្នា ។ គុណសម្បត្តិនេះឯងដែលរងការវាយប្រហារឥតស្រាកនៅក្នុងពិភពលោកប៉ែកខាងលិច ។

មូលហេតុនាំឲ្យងាយធ្លាក់ក្នុងអន្ទាក់នៃការបណ្តោតបណ្តោយខ្លួននោះគឺ វាធ្វើឲ្យសប្បាយកាយ វាជាប្រការមួយដែលទាក់ទាញចិត្តមនុស្សច្រើនឡើងៗ និងពិបាកចៀសវាងឬបដិសេធ ។

ពេលបុគ្គលបានដល់ដំណាក់ការមានការទទួលខុសត្រូវក្នុងខ្លួន និងគ្រប់អាយុ (បាលិក្ខ) បុគ្គលនោះផ្លាស់ប្តូរផ្លូវកាយនិងផ្លូវចិត្ត ។ បុគ្គលនោះមានតម្រេកជំពាក់ចិត្តទៅលើប្រការដែលខ្លួនមិនធ្លាប់អើពើកាលនៅក្មេង ។ ហេតុដូច្នេះឯងបានជាអ៊ីស្លាមដាក់ច្បាប់វ៉ាឃ្ជីបទៅលើបុគ្គលគ្រប់អាយុ ព្រោះបុគ្គលនោះត្រូវមានមធ្យោបាយសម្អាតឲ្យជ្រះស្អាតពីសេចក្តីកខ្វក់ ដែលជ្រាបចូលទៅក្នុងចិត្តពីខាងក្រៅ ។

បើគេមិនប្រយ័តខ្លួនទេ បើគេមិនអើពើអំពីច្បាប់ទាំងនេះទេ គេនឹងក្លាយទៅជាអសោចបន្តិចម្តងៗដូចគំនិតលាមកនោះដែរដែលជ្រាបចូលទៅក្នុងចិត្ត ទាល់តែបណ្តោយខ្លួនទាំងស្រុងទៅតាមតម្រេក បណ្តាលឲ្យជីវិតខូចឥតប្រយោជន៍ ។

ឧទាហរណ៍បណ្តែតបណ្តោយខ្លួនគឺ ស្លៀកពាក់ដោយទុកមួយប៉ែកនៃខ្លួនប្រាណនៅទទេឥតបិទបាំង នាំឲ្យអ្នកដទៃបែរមកមើល ស្លៀកពាក់រឹបឲ្យចេញរាងរៅ និយាយលេងសើចច្រឡើសបើស មើលកម្មវិធីទូរទស្សន៍ដែលធ្វើឲ្យមានតម្រេក...

ទៅកំសាន្តឯរង្គសាលជាមួយមិត្តប្រុស/ស្រី មានទំនាក់ទំនងអាវ៉ាសែ ជាឧទាហរណ៍ទូទៅក្នុងសង្គមដែលបណ្តោយដៃ ។

ចង់បានគូស្រករមិនជាប្រការអាក្រក់ឬខុសទេ តែត្រូវនៅក្រោមការគ្រប់គ្រងក្នុងក្របខ័ណ្ឌអ៊ីស្លាម ។ ដូចភ្លើងដែរ បើគេប្រើវាត្រឹមត្រូវ វាមានប្រយោជន៍ច្រើនសម្រាប់ដាំស្ល ឬសម្រាប់កម្ចាត់អាកាសរងា តែបើគេប្រមាទវានឹងឆាបឆេះខ្លាំងទាល់តែពុំអាចគ្រប់គ្រងបាន វានឹងឆេះសព្វសារពើគ្មានសល់ ។

អ្វីដែលពិបាកបំផុតគឺបណ្តោយឲ្យវិចារណញ្ញាណដឹកនាំតម្រេក មិនមែនបណ្តោយឲ្យតម្រេកដឹកនាំវិចារណញ្ញាណទេ ។

ការបណ្តែតបណ្តោយជាអច្ចន្តភាព (ប្រការជ្រុលហួសហេតុ) មួយក្នុងសង្គមដែលបន្ធូរ បណ្តោយដៃពេក ដែលនៅក្រោមតម្រេកខ្លួនឯង ។ អច្ចន្តភាពមួយទៀតគឺភាពនៅលីវ បានសេចក្តីថាមិនរៀបការសោះ គឺសម្លាប់តម្រេកតែម្តង ។

អច្ចន្តភាពទាំងពីរនេះមានកំហុសសម្រាប់អ៊ីស្លាម ។ អ៊ីស្លាមជ្រើសយកផ្លូវកណ្តាលនៃព្រហ្មចារិយភាពដែលអនុញ្ញាតឲ្យអ្នកធ្វើតាមតម្រេក តែនៅក្នុងក្របខ័ណ្ឌអាពាហ៍ពិពាហ៍ ។

បណ្តោតបណ្តោយ ព្រហ្មចារីភាព ភាពនៅលីវ

ដ្យាក្រាមខាងលើនេះបង្ហាញនូវការប្រព្រឹត្តខ្លួនជ្រុលហួសហេតុទាំងពីរ ក្នុងសង្គម (១) បណ្តោតបណ្តោយ គឺបណ្តោយឲ្យតម្រេកដឹកនាំអ្នក (២) នៅលីវ ដូចសម្លាប់តម្រេករបស់អ្នកតែម្តង ។

អ៊ីស្លាមពន្យល់ប្រាប់យើងអំពីទ្រឹស្តីព្រហ្មចារិយភាព ដែលនៅចន្លោះអច្ចន្តភាពទាំងពីរនេះ អនុញ្ញាតឲ្យយើងគ្រប់គ្រងតម្រេកយើងជាជាងកម្ចាត់តម្រេកនោះតែម្តង ។

ហេតុអ្វីសង្គមបណ្តោយដៃឬបន្ធូរខ្លាំងម្ល៉េះ ? បើគេឲ្យប្រអប់បិទជិតមួយមកអ្នកដោយប្រាប់អ្នកថាកុំបើកវាមើលអស់រយៈពេលច្រើនឆ្នាំ អ្នកនឹងចង់ដឹងថាក្នុងប្រអប់នោះមានអ្វី ។ បើទុកប្រអប់នោះកន្លែងដែលអាចមើលឃើញ ការចង់ដឹងរបស់អ្នកកាន់តែធំឡើងរាល់ថ្ងៃ ។ បើបន្ទាប់ពីនោះ គេឲ្យកូនសោកមកអ្នកដោយប្រាប់អ្នកដដែលថាកុំបើកវា អ្នកចង់បើកវាមើលស្ទើរស្លាប់ពេលមិនមានគេមើល ។

ហេតុអ្វី ? នៅក្នុងសង្គមប៉ែកខាងលិចនៃពិភពលោក តាំងពីយើងនៅតូចម្ល៉េះ យើងឃើញទិដ្ឋភាព និងឃើញលក្ខណៈទាក់ទាញចិត្តនិងបណ្តាលឲ្យស្រើបរបស់កាម ។ តែនៅក្នុងវ័យនេះគេបានប្រាប់យើងថាអ្វីៗទាំងនេះមែនសម្រាប់កូនក្មេងៗទេ ។ ពេលធំឡើង យើងបាលិគ្គ គ្រប់អាយុ យើងមានសិទ្ធិបើកប្រអប់មើល ក្នុងឧទាហរណ៍ខាងលើនេះ ។ មិនដឹងថាមានអ្វីនៅក្នុងប្រអប់នោះទេ ឬគិតថាប្រអប់នោះទុកនូវវត្ថុជាទីត្រេកត្រអាលអាចកំចាំង វាធ្វើឲ្យយើងចង់បើកវាមើលហើយពិសោធមើល ។ នេះគឺមូលហេតុនៃការបណ្តោតបណ្តោយ ។

អ្វីដែលខុសគឺមិនពិគ្រោះរឿងភេទតាមទស្សនៈសីលធម៌ ។ ភេទមិនកខ្វក់ឬអាក្រក់ទេ តែគេមិនត្រូវបង្ហាញនិងមិនត្រូវសម្ញែងទេ ។ ព្រោះសង្គមប៉ែកខាងលិចនៃពិភពលោកយល់ឃើញថាភេទជាអ្វីដែលធ្វើឲ្យរំជួលចិត្តនិងហ៊ាន គ្មានការទទួលខុសត្រូវនិងគ្មានសេចក្តីស្រឡាញ់ ។ យុវជនដែលទើបនឹងស្គាល់អារម្មណ៍រំភើបថ្មីនេះមុខជាពិសោធវាជាមិនខាន ។ វាអាចធ្វើឲ្យស្រណុកស្រួលរយៈពេលខ្លី តែពួកគេនឹងដឹងខ្លួនថាជាខ្ញុំរបស់តម្រេកភេទយ៉ាងឆាប់ៗ លែងជាម្ចាស់ ។

## មេរៀនទី ២០

# ព្រហ្មចារិយភាព

ព្រហ្មចារិយភាពមានន័យថា៖ *"ចៀសវាងអំពើអសីលធម៌និងខុសច្បាប់ ទំនាក់ទំនងផ្លូវភេទ; បរិសុទ្ធ ព្រហ្មចារិយ; និយាយស្តីសមរម្យ ទប់កាយចិត្ត មានចំណូលចិត្តឬបែបបទសាមញ្ញនិងបរិសុទ្ធ ។"* វចនានុក្រមអង់គ្លេស Concise Oxford Dictionary ។

ផ្ទុយពីការបណ្តែតបណ្តោយដែលយើងបានសិក្សាក្នុងមេរៀនមុន ។

អ៊ីស្លាមសង្កត់ធ្ងន់លើប្រហ្មចារិយភាព ចំណុចនេះឯង ក្នុងចំណោមចំណុចច្រើនទៀត ដែលត្រូវទិតៀនក្នុងពិភពលោកប៉ែកខាងលិច ។

**ហេតុអ្វីត្រូវមានព្រហ្មចារិយភាព**?

យើងត្រូវមានព្រហ្មចារិយភាពក្នុងទង្វើទាំងអស់របស់យើង ដោយមិនធ្វើអំពើអសីលធម៌និងខុសច្បាប់ និងដោយមិននិយាយស្តីអាក្រក់ ។ យើងត្រូវចាត់ទុកប្រការទាំងអស់នេះជាប្រការអាក្រក់និងត្រូវចៀសវាងវា ។

អ៊ីស្លាមបង្ហាត់បង្រៀនយើងដែរថាដរាបណាមិនទាន់បាននីកាស់ទេ ដរាបនោះទំនាក់ទំនងស្និទ្ធស្នាលរវាងបុរសស្ត្រីពីរនាក់ត្រូវហាម ។

ព្រហ្មចារិយភាពជាអំណោយរបស់អល់ឡោះហ៍ﷻ ។ វាជាសញ្ញានៃលក្ខណៈបរិសុទ្ធនិងថ្លៃថ្នូរ ។ វាជាទ្រព្យដ៏មានតម្លៃនិងផ្ទាល់ខ្លួន ។ ពេលរៀបការ បុគ្គលឈានចូលទៅក្នុងដំណាក់ការថ្មីរបស់ជីវិត ។ សម្ព័ន្ធអាពាហ៍ពិពាហ៍ត្រូវចងភ្ជាប់ដោយគូស្វាមីភរិយា រួមរស់ជាមួយគ្នាដោយបែងចែកគ្នានូវអ្វីមួយដែលផ្ទាល់ខ្លួននិងស្និទ្ធស្នាល ។ វាជួយឲ្យអាពាហ៍ពិពាហ៍តស៊ូវិបត្តិតូចធំបានដែលនឹងកើតឡើងក្នុង

អនាគត និងធ្វើឲ្យអាពាហ៍ពិពាហ៍មានចំណោរកាលយូរអង្វែង ។

បើបុគ្គលមិនរក្សាព្រហ្មចារិយភាពទេ ចាត់ទុកទំនាក់ទំនងផ្លូវភេទជាធម្មតា បុគ្គលនឹងបាត់បង់គោលដៅសំខាន់បំផុតដែលអល់ឡោះហ៊្ញ បានកំណត់ និងការរួមរស់ជាមួយគ្នារវាងបុគ្គលប្រុសស្រីពីរនាក់ ។

បើចាត់ទុកទំនាក់ទំនងផ្លូវភេទជាការកំសាន្តធម្មតា ជាមួយដៃគូឥតរើសមុខ ទំនាក់ទំនងនឹងបាត់បង់វេទនារម្មណ៍ (គឺគ្មានចិត្តមេត្តារវាងគូស្រករ) ។

អល់ឡោះហ៊្ញ ឲ្យមនុស្សមានវត្ថុធាតុច្រើនមុខ ដូចជាឲ្យខ្លួនមនុស្សមានវិញ្ញាណប្រាំគឺ កាយវិញ្ញាណ (ដឹងការប៉ះពាល់), ជីវ្ហាវិញ្ញាណ (ដឹងរសជាតិ), ចក្ខុវិញ្ញាណ (ការមើលឃើញ), សោតវិញ្ញាណ (ការស្តាប់ឮ), ឃានវិញ្ញាណ (ការធុំក្លិន) ជាដើម ។ បន្ទាប់មក ព្រះអង្គ បានបន្ថែមសម្បត្តិកាយថ្មីមួយទៀតឲ្យមនុស្ស គឺព្រះអង្គ ឲ្យមនុស្សចេះគិតនិងចេះយល់ដឹង ។

បើយើងប្រើខ្មាសយើងឥតប្រមាន ដោយប្រមាទ មិនប្រយ័តប្រយែង យើងនឹងទទួលបាននូវតម្រេកកាយ តែយើងនឹងបាត់បង់ "សេចក្តីស្រឡាញ់និងសេចក្តីស្កប់ស្កល់ផ្លូវចិត្ត" ដែលអារម្មណ៍អាចផ្តល់ឲ្យយើងបាន ។

ដូច្នេះ បើយើងបណ្តោតបណ្តោយខ្លួននិងមានទំនាក់ទំនងផ្លូវភេទភ្លាមៗពេលមានចំណង់នោះ យើងបន្ទាបសេចក្តីថ្លៃថ្នូរយើងពីថ្នាក់មនុស្សប្រកបដោយប្រាជ្ញាចុះមកកាន់ថ្នាក់សត្វ/កាយ យើងនឹងបាត់បង់ខ្លឹមសារពិតរបស់ជីវិត ។

**តើខុសអ្វីបើគ្មានព្រហ្មរិយភាព?**

គេដឹងច្បាស់ហើយថាបើអារម្មណ៍ត្រូវជំរុញឬធ្វើឲ្យកម្រើក ដោយអ្វីមួយអារម្មណ៍នោះនឹងចង់បានច្រើនទៀតពីអ្វីនោះលើកក្រោយ ដើម្បីនឹងបានទៅដល់លំដាប់ជំរុញឬកម្រើកចិត្តដូចមុនៗដែរ ។

ឧទាហរណ៍ បើខ្ញុំផឹកស្រា ខ្ញុំបាត់បង់ការគ្រប់គ្រងខ្លួនឯង ។ លើកក្រោយ ខ្ញុំនឹងផឹកស្រាច្រើនជាងមុនដើម្បីនឹងបានស្រវឹងដូចលើកមុនដែរ ។ លើកក្រោយទៀត ខ្ញុំនឹងផឹកលើសនោះទៀត...

ដូចគ្នាដែរ បើខ្ញុំផ្តោតអារម្មណ៍ទៅលើសកម្មភាពផ្លូវភេទរបស់ខ្ញុំដើម្បីលេងសប្បាយ លើកក្រោយខ្ញុំនឹងប្រព្រឹត្តច្រើនជាងមុន ទាល់តែទៅជាញៀន មិនអាចឈប់បាន ។

ដូច្នេះ បើយើងបរិសុទ្ធមានព្រហ្មចារីយភាពក្នុងទង្វើទាំងអស់របស់យើង (ជាពិសេសផ្លូវភេទ) ចាត់ទុកប្រការនេះជាប្រការ "គួរឲ្យគោរព" និងមិនប្រព្រឹត្តឥតគិតទេ យើងនឹងបានដល់លំដាប់វិន័យដែលនឹងធ្វើឲ្យយើងខ្លាំងក្លាជាងមុន យើងនឹងមានសេចក្តីប្តេជ្ញាចិត្តនិងអាចធ្វើឲ្យអ្វីដែលយើងគិតទុកក្នុងចិត្តនោះបានសម្រេច ។

**ហេតុអ្វីពិបាករក្សាព្រហ្មចរិយភាព?**

សង្គមពិភពលោកប៉ែកខាងលិចបានបាត់បង់ ទ្រឹស្តីជីវិតប្រកបដោយធម្ម ។ គេបិទភ្នែកក្នុង ផ្តោតតែលើតម្រេកកាយ ។ កាមទៅជាល្បែងកំសាន្ត ។ វាធ្វើឲ្យចំណង់កាន់តែកម្រើកខ្លាំង ធ្វើឲ្យយើងចង់ចូលរួមដែរ ។ តម្រេកស្ទើរតែទាំងអស់ត្រូវដឹកនាំទៅរកទ្រឹស្តីនេះដូចជាបុណ្យ វីដេអូ សៀវភៅអាន ទស្សនាវដ្តី វង្គសាលកុន ទូរទស្សន៍ជាដើម ។ ដូច្នេះគេអាចសួរបានថា៖ "មានមិត្តប្រុសឬមិត្តស្រី ខុសអ្វី ? បើពួកគេអាចធ្វើដូច្នេះបាន ហេតុអ្វីយើងធ្វើមិនបាន ?" អ្នកនឹងសួរបុគ្គលដែលជក់អាភៀនទេថា៖ "បើអ្នកអាចធ្វើបាន ហេតុអ្វីខ្ញុំធ្វើមិនបាន ?"

ទេ អ្នកមិនអាចធ្វើបែបនេះបានទេ ព្រោះអ្នកឃើញអ្នកនោះធ្វើឲ្យអារម្មណ៍និងខ្លួនប្រាណខ្លួនឯងខូចដោយសារធ្វើបែបនេះ ។

នេះព្រោះតែយើងមិនឃើញផលវិបត្តិក្នុងអនាគត ដោយសារតែយើងមិនបរិសុទ្ធ គ្មានព្រហ្មចារិយភាព ក្នុងសំណួរខាងលើនោះ ។ បណ្តាអ្នកដែលចាស់ជាងយើងដែលបានឃើញផលវិបត្តិនេះ បានព្រមានយើង តែយើងហៅគាត់ថា "ជនហួសសម័យ" ។ បើយើងដឹងអ្វីដែលពួកគាត់បានដឹងនោះ យើងមុខជាមិនតាម

ចំណង់យើងទេ នឹងមិនមានទំនាក់ទំនងផ្លូវភេទក្រៅក្របខ័ណ្ឌអ៊ីស្លាមទេ ។

បរិសុទ្ធ មានព្រហ្មចារិយភាព មិនបានសេចក្ដីថានៅតែក្នុងផ្ទះ ផ្ដាច់ខ្លួនពីពិភពលោកប៉ែកខាងលិចនិងមិនព្រមស្ដាប់ពួកគេនិយាយជាមួយយើងនោះទេ ។

បានសេចក្ដីថាស្ដាប់សំណូមពរទាំងអស់របស់ពួកគេ និងធ្វើអ្វីដែលល្អ មិនធ្វើអ្វីដែលអាក្រក់ ។

ទាល់តែអ្នកស្ដាប់ពួកគេ ទើបអ្នកអាចសម្រេចបានថាអ្វីល្អអ្វីក្រក់ ។

បានសេចក្ដីដែរថាមិនបណ្ដោយឲ្យចំណង់អ្នកនាំអ្នកធ្វើប្រការ ដែលអ្នកដឹងថាវាធ្វើឲ្យអ្នកមានតម្រេកផ្លូវកាយ តែវាធ្វើឲ្យអ្នកខាតបង់ខាងលំដាប់ជាន់ខ្ពស់ឯនោះ (គឺផ្នែកធម៌) ។

យើងអាចបរិសុទ្ធ មានព្រហ្មចរិយភាពបានដោយចៀសវាងនិយាយចំអាសចំអូង ដោយចៀសវាងនិយាយលេងសើចច្រឡើសបើស ដោយចៀសវាងមើលកុនដែលបង្ហាញឲ្យឃើញខ្មាសមនុស្សបណ្ដាលឲ្យមានតម្រេកផ្លូវភេទ ដោយចៀសវាងមានទំនាក់ទំនងស្និទ្ធស្នាលពេកជាមួយបុគ្គលភេទផ្ទុយពីយើង និងដោយសួរខ្លួនឯងជានិច្ចថា៖ "ខ្ញុំធ្វើដូច្នេះព្រោះតែតម្រេកខ្ញុំឲ្យខ្ញុំធ្វើដូច្នេះ ឬព្រោះតែប្រាជ្ញាខ្ញុំឲ្យខ្ញុំធ្វើដូច្នេះ ។"

បើតម្រេកយើងឲ្យយើងធ្វើដូច្នេះ ចូរយើងកុំធ្វើ ។ បើប្រាជ្ញាយើងឲ្យយើងធ្វើដូច្នេះ ចូរយើងធ្វើ ហើយយើងនឹងសប្បាយទាំងផ្លូវកាយ ទាំងផ្លូវធម្ម (ឬផ្លូវចិត្ត) ។

ផ្លូវដែលនាំទៅរកសេចក្ដីពេញចិត្តពិតប្រាកដនឹងជីវិតជាផ្លូវពិបាកណាស់ វានៅត្រង់ចន្លោះតម្រេកផ្លូវកាយនិងតម្រេកផ្លូវធម៌ (ឬផ្លូវចិត្ត) ។ វាដូចឡើងភ្នំ ទាល់តែបានទៅដល់លើកំពូលទើបអ្នកអាចមើលឃើញជុំវិញខ្លួនអ្នក និងដឹងថាអ្វីៗស្រស់ស្រាយ ។ ពេលអ្នកមើលមកក្រោម អ្នកនឹងឃើញអ្វីៗដោយទស្សនៈផ្សេង ។ ពីខាងលើ អ្នកឃើញភាពខ្វាត់ខ្វែងរបស់ជីវិត អ្នកឃើញផ្លូវដែលនាំឲ្យអ្នកដើរខុសពេលអ្នកនៅក្នុងភាពខ្វាត់ខ្វែងនោះ លេចឡើងច្បាស់ក្រឡែតនិងយ៉ាងងាយពេលនេះ ។

*sources:*
www.saba-igc.org
shia974.fr
www.madressa.net

អ៊ីម៉ាំមេម៉ាស្ហ៊ាប់ទាំង ៤ ។

| ឈ្មោះអ៊ីម៉ាំមេម៉ាស្ហ៊ាប់ | ម៉ាស្ហ៊ាប់ | ថ្ងៃកំណើត/ថ្ងៃស្លាប់ សករាជហ៊ីជ្រ៉ះត៍ | ថ្ងៃកំណើត/ថ្ងៃស្លាប់ គ្រិស្តសករាជ |
|---|---|---|---|
| អាប៊ូ ហ៊ានីហ្វាស្ង៉ | ហ៊ាណាហ្វី | 80-150 ស.ហ. | 699-767 គ.ស. |
| ម៉ាលិក | ម៉ាលីគី | 93-179 ស.ហ | 711-795 គ.ស. |
| អាស្ង៉-ស្ហាហ្វីអ៊ី | ស្ហាហ្វីអ៊ី | 150-204 ស.ហ | 767-820 គ.ស. |
| អាស្ង៉ម៉ាដ្ង ហ៊ាន់បាល់ | ហ៊ាន់បាលី | 164-241 ស.ហ. | 780-855 គ.ស. |

ព្រះសាស្ដា មូហ៊ាំម៉ាដ្ង ប្រសូត/ចូលព្រះទិវង្គត ឆ្នាំ 570-632 គ.ស. ថ្ងៃសុក្រ ទី ១៧ ខែ រ៉ប៊ីអ៊ុល អាវ៉ាល់ ឆ្នាំដំរី ។

អ៊ីម៉ាំអ្នកស្នងព្រះសាស្ដាមូហ៊ាំម៉ាដ្ង ﷺ ទាំង ១២ ។

| លំដាប់ | ឈ្មោះ | ឈ្មោះក្រៅ | ឋានន្តរស័ក្តិ | ថ្ងៃកំណើត/ថ្ងៃស្លាប់ គ.ស./ស.ហ. |
|---|---|---|---|---|
| 1 | អ៊ុលី | អាប៊ូ អាល់-ហ៊ាសាន់ | អាមីរុល-មុមីនីន | 600-661/23 មុន ស.ហ.-40 |
| 2 | ហ៊ាសាន់ | អាប៊ូ មូហ៊ាំម៉ាដ្ង | អាល់-មុជ្ដាបា | 625-670/3-50 |
| 3 | ហ៊ូសែន៍ | អាប៊ូ អ៊ុប់ឌុលឡោះហ្ង៉ | សែឃីដ្ង អាស្ង-ស្ហ៊ុហាដាអ៊ុ | 626-680/4-61 |
| 4 | អ៊ុលី ប៊ិន ហ៊ូសែន៍ | អាប៊ូ មូហ៊ាំម៉ាដ្ង | អាស់-សាជ្ជ៉យ៉ាដ្ង ស្សែនុល-អាប៊ីឌីន | 659-713/38-95 |
| 5 | មូហ៊ាំម៉ាដ្ង អាល់-បាគ្វៀរ | អាប៊ូ យ៉ាកុំហ្វារ | បាគ្វៀរ អាល់-អ៊ូលូម | 676-733/57-114 |
| 6 | យ៉ាកុំហ្វារ | អាប៊ូ អ៊ុប់ឌុលឡោះហ្ង៉ | អាស្ង-ស្ហ៊ឌិក្ហ | 702-765/83-148 |
| 7 | មូសា ប៊ិន យ៉ាកុំហ្វារ | អាប៊ូ អាល់-ហ៊ាសាន់ | អាល់-កាស្ង៊ីម | 745-799/128-183 |
| 8 | អ៊ុលី ប៊ិន មូសា | អាប៊ូ អាល់-ហ៊ាសាន់ | អារ-រីដ្ហ | 765-819/148-203 |
| 9 | មូហ៊ាំម៉ាដ្ង ប៊ិន អ៊ុលី | អាប៊ូ យ៉ាកុំហ្វារ | អាត់-តាគ្គី អាល់-យ៉ាវ៉ាដ្ង | 811-835/195-220 |
| 10 | អ៊ុលី ប៊ិន មូហ៊ាំម៉ាដ្ង | អាប៊ូ អាល់-ហ៊ាសាន់ | អាល់-ហ្ហាឌី អាន់-ណាគ្គី | 828-868/212-254 |
| 11 | ហ៊ាសាន់ ប៊ិន អ៊ុលី | អាប៊ូ មូហ៊ាំម៉ាដ្ង | អាល់-អ៊ុស់ការី | 846-874/232-260 |
| 12 | មូហ៊ាំម៉ាដ្ង ប៊ិន ហ៊ាសាន់ | អាប៊ូ ក្ហ៊ស៊ីម | អាល់-ម៉ាស្ហ៊ឌី អាល់-ហ៊ុជ្ជ៉យ៉ាស្ង ស្ហ៊ហ្ហ៊ីប អាល់-ស៊ាម៉ាន អាល់-ក្ហ៊អ៊ីម | 869/255 |